សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាប តាមបែបវិមជ្ឈការ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ជុំ ដារ៉ូ**
កញ្ញា **ស៊ីន ស្រីនីត**

ណែនាំដោយ
លោក **គាត គា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ**ជុំ ដារ៉ូ** និង**ស៊ីន ស្រីនីត** ជានិស្សិតជំនាន់ទី១៧ ជំនាញរដ្ឋបាលសាធារណៈ នៅក្នុងក្រុម P4A03 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការគោរពដឹងគុណ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

**លោកឪពុក** និង**អ្នកម្តាយ** ដែលជាអ្នកមាននូវឧបការគុណមិនអាចកាត់ថ្លៃបាន ដោយលោកបានផ្តល់នូវកំណើត ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ និងបានខិតខំទំនុកបម្រុង ផ្គត់ផ្គង់ និងលើកទឹកចិត្តកូនគ្រប់ពេលវេលាទាំងផ្នែកស្មារតី សម្ភារៈ និងផ្នែកថវិកាដើម្បីផ្តល់ជាភាពងាយស្រួលឱ្យកូនបានសិក្សារៀនសូត្រតាំងតែពីថ្នាក់ដំបូងរហូតដល់ថ្នាក់មហាវិទ្យាល័យនេះ។ មួយវិញទៀតក្នុងនាមជាប្អូន យើងខ្ញុំសូមសំដែងនូវការដឹងគុណយ៉ាងជ្រៀលជ្រៅចំពោះបងប្រុស បងស្រីទាំងអស់គ្នាដែលបានផ្តល់នូវសេចក្តីស្រឡាញ់ និងករុណាធម៌ដោយបានណែនាំ ផ្តល់ដំបូន្មាន លើកទឹកចិត្ត និងជួយជ្រោមជ្រែងប្អូនគ្រប់ពេលវេលាក្នុងដំណើរការរៀនសូត្ររបស់ប្អូនតាំងពីដើមមក។

**ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោក-លោកស្រីសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក-លោកស្រីប្រធាន អនុប្រធានការិយាល័យ និងដេប៉ាតេម៉ង់ លោក-លោកស្រីសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងផ្ទេរចំណេះដឹង និងផ្តល់នូវឱកាសនានា ព្រមទាំងបានខិតខំបំពេញកិច្ចការងារផ្សេងៗដើម្បីជួយសម្រួលដល់យើងខ្ញុំដែលជានិស្សិត។

**លោកសាស្ត្រាចារ្យ គាត គា** ជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយផ្តល់ជាគំនិត និងអនុសាសន៍ល្អៗដើម្បីកែសម្រួលនូវរាល់ចំណុចខ្វះខាតទាំងឡាយ និងរាល់កំហុសឆ្គងដែលកើតមានឡើង ព្រមទាំងតែងតែលើកទឹកចិត្ត និងជម្រុញដល់យើងខ្ញុំទាំងពីរក្នុងកិច្ចការងារសរសេរសារណាបញ្ចប់ការសិក្សានេះឱ្យទទួលបាននូវលទ្ធផលដ៏ល្អប្រសើរ។

**លោកមេឃុំ ស៊ឺ ខុន្ធី** ដែលបានផ្តល់ឱកាសដល់យើងខ្ញុំ បានចុះស្រាវជ្រាវឯកសារ និងប្រមូលទិន្នន័យយកមកសរសេរក្នុងសារណាមួយនេះ ជាពិសេសបានខ្នះខ្នែងជួយជ្រោមជ្រែង និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់ព័ត៌មាន និងផ្តល់នូវឯកសារនានាដែលទាក់ទងនឹងស្ថានភាពទូទៅជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាប។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តងទៀត និងសូមប្រសិទ្ធិពរជ័យគោរពជូនពរចំពោះអស់លោកទាំងអស់ ឱ្យជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **"ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាបតាមបែបវិមជ្ឈការ"** ត្រូវបានឧប្បត្តិកឡើងតាមរយៈការខិតខំប្រឹងប្រែងព្យាយាមរបស់យើងខ្ញុំទាំងពីរនាក់ យ៉ាងសស្រាក់សស្រាំឥតស្រាកស្រាន្តរហូតបានសម្រេចចេញជារូបរាងសារណានេះឡើង។

ជាការពិតណាស់ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មានសារៈសំខាន់ណាស់នៅក្នុងការចូលរួមចំណែកនៃការអភិវឌ្ឍសង្គមជាតិ ព្រោះបានលើកកម្ពស់ការផ្ដល់សេវាសាធារណៈ បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាពិសេសធ្វើឱ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និទ្ធនឹងគ្នាថែមទៀត មិនតែប៉ុណ្ណោះរដ្ឋាភិបាលបានយល់ច្បាស់ពីប្រជាពលរដ្ឋថាតើពួកគាត់ចង់បានអ្វី? និងមិនចង់បានអ្វី?ដើម្បីងាយស្រួលដោះស្រាយបញ្ហាជូនពួកគាត់បានទាន់ពេលវេលាផងដែរ។

វត្ថុបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើឡើងដើម្បីសិក្សាស្វែងយល់ពីរបៀបនៃការគ្រប់គ្រងដឹកនាំដំណើរការ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំតាំងយ៉ាប ថាតើដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្ដេច? ក្រោយពីការទទួលបាននូវបទពិសោធ នៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមកធ្វើឱ្យយើងបានយល់ដឹងកាន់តែស៊ីជម្រៅជាងមុនពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនៅក្នុងឃុំ សង្កាត់ជាលក្ខណៈជាក់ស្ដែងតែម្ដងដែលកន្លងមកនោះយើងធ្លាប់សិក្សាតែទៅលើទ្រឹស្ដីប៉ុណ្ណោះ។ សមិទ្ធផលមួយនេះអាចសម្រេចទៅបានអាស្រ័យដោយមានការសម្របសម្រួលជួយជ្រោមជ្រែងលើកស្ទួយពីសំណាក់ សាស្ត្រាចារ្យដឹកនាំ និងលោកគ្រូ អ្នកគ្រូ ក្នុងការផ្ដល់ជាអនុសាសន៍ណែនាំត្រួសត្រាយបង្ហាញផ្លូវក្នុងការកែសម្រួល ពាក្យពេចន៍ រចនាបទ អត្ថន័យ ខ្លឹមសារ អក្ខរាវិរុទ្ធ ដែលបានធ្វើឱ្យអត្ថបទស្រាវជ្រាវមួយនេះសម្រេចបានជាលទ្ធផលដែលអាចទទួលយកបាន។ ទោះបីជាខិតខំព្យាយាមប្រឹងប្រែងកែខៃពិនិត្យយ៉ាងហ្មត់ចត់ច្បាស់លាស់សាចុះសាឡើងម្ដងហើយម្ដងទៀតយ៉ាងណាក៏ដោយ ក៏មិនគេចផុតពីការខុសឆ្គង ល្មៀងសេចក្ដី អត្ថន័យ អក្ខរស មិនសមទំនងចន្លោះប្រហោងនៅក្នុងទំព័រណាមួយជាក់ជាមិនខានឡើយ។ អាស្រ័យហេតុនេះយើងខ្ញុំទាំងពីរនាក់នឹងរង់ចាំទទួលនូវរាល់ការរិះគន់ការផ្ដល់មតិយោបល់ក្នុងន័យស្ថាបនា និងការកែលម្អដោយក្ដីសោមនស្សរីករាយពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត មិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ ជាពិសេសពីសំណាក់គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃដើម្បីធ្វើការកែលម្អឱ្យមានភាពល្អប្រសើរឡើង។

ជាចុងក្រោយយើងខ្ញុំសង្ឃឹម និងជឿជាក់ថា កិច្ចការសារណាស្រាវជ្រាវមួយនេះនឹងអាចក្លាយជាការចូលរួមចំណែកមួយនៃចំណេះដឹងដល់មិត្តនិស្សិតទាំងឡាយ ជាពិសេសគឺអ្នកដែលមានបំណងចង់សិក្សាស្រាវជ្រាវនូវប្រធាននេះបន្តទៅទៀត ព្រមទាំងជាទិន្នន័យជំនួយស្មារតីបន្ថែមសម្រាប់ការជួយបង្ហាញផ្លូវដល់មិត្តនិស្សិត និងសិស្សប្អូនជំនាន់ក្រោយៗ។

# មាតិកា

ទំព័រ

**បញ្ជីអក្សរកាត់** ........ IV

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ដែនកំណត់ និងទំហំនៃការស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃសារណា ........ ៤

## ជំពូកទី១
## ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់

**១.១. ការគ្រប់គ្រងរដ្ឋបាល** ........ ៥

១.១.១. និយមន័យគ្រប់គ្រង ........ ៥

១.១.២. និយមន័យរដ្ឋបាល ........ ៥

១.១.៣. និយមន័យវិមជ្ឈការ ........ ៦

១.១.៤. ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ ........ ៧

១.១.៥. ការអនុវត្តវិមជ្ឈការ ........ ៧

១.១.៦. ហេតុផលនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ........ ៨

**១.២. ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ........ ៨

១.២.១. ការផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចនានា ........ ៩

១.២.២. ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ ........ ៩

១.២.៣. ធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋាន ........ ១០

**១.៣. ការរៀបចំរដ្ឋបាលឃុំ សង្កាត់** ........ ១០

១.៣.១. រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ ........ ១០

១.៣.២. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ១១

១.៣.៣. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ១៣
**១.៤. កិច្ចការរដ្ឋបាលឃុំ សង្កាត់** ...... ១៧
១.៤.១. លិខិតរដ្ឋបាលឃុំ សង្កាត់ ...... ១៧
១.៤.២. ការគ្រប់គ្រងទ្រព្យសម្បត្តិ ...... ១៨
១.៤.៣. ការគ្រប់គ្រងឯកសារឃុំ សង្កាត់ ...... ១៩
១.៤.៤. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ...... ២០
**១.៥. តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់** ...... ២៣
១.៥.១. អំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ...... ២៣
១.៥.២. តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់ ...... ២៤
១.៥.៣. ព្រំដែននៃអំណាច ...... ២៤
**១.៦. ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់** ...... ២៥
១.៦.១. អត្ថន័យនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ...... ២៥
១.៦.២. គោលការណ៍សំខាន់ៗនៃការកសាងផែនការឃុំ សង្កាត់ ...... ២៥
១.៦.៣. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ ...... ២៦

## ជំពូកទី២
## ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាប

**២.១. ស្ថានភាពទូទៅ** ...... ៣០
២.១.១. ស្ថានភាពភូមិសាស្ត្រ ...... ៣០
២.១.២. ស្ថានភាពប្រជាសាស្ត្រ ...... ៣០
**២.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំតាំងយ៉ាប** ...... ៣១
២.២.១. សមាសភាពក្រុមប្រឹក្សាឃុំ ...... ៣១
២.២.២. គណៈកម្មការនានារបស់ឃុំ ...... ៣២
២.២.៣. ហិរញ្ញវត្ថុរបស់ឃុំ ...... ៣៥
**២.៣. ការអភិវឌ្ឍឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ** ...... ៣៧
២.៣.១. ផែនការអភិវឌ្ឍន៍ឃុំ ...... ៣៧
២.៣.២. កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ ...... ៤២

២.៣.៣. គម្រោង សកម្មភាពដែលមានថវិកាគាំទ្រ ........ ៤៦
២.៣.៤. គម្រោង សកម្មភាពដែលមិនទាន់មានថវិកាគាំទ្រ ........ ៤៧
២.៣.៥. សមិទ្ធផលនានា ........ ៤៩

## ជំពូកទី៣
## បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម** ........ ៥២
៣.១.១. ស្ថានភាពសេដ្ឋកិច្ច ........ ៥២
៣.១.២. ស្ថានភាពសង្គមកិច្ច ........ ៥៤
៣.១.៣. ស្ថានភាពនៃការគ្រប់គ្រងធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........ ៥៦
៣.១.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ ........ ៥៧
៣.១.៥. ស្ថានភាពគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៥៧
**៣.២. ដំណោះស្រាយ** ........ ៥៨
៣.២.១. ពង្រឹងវិស័យសេដ្ឋកិច្ច ........ ៥៨
៣.២.២. ពង្រឹងវិស័យសង្គមកិច្ច ........ ៥៩
៣.២.៣. ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........ ៦១
៣.២.៤. ពង្រឹងការគ្រប់គ្រងគ្រោះមហន្តរាយ ........ ៦២
៣.២.៥. បង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៦២
**៣.៣. ទិសដៅនាពេលអនាគត** ........ ៦៣
៣.៣.១. ការបណ្តុះបណ្តាលធនធានមនុស្ស ........ ៦៣
៣.៣.២. ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ ........ ៦៤
៣.៣.៣. ការបង្កើនថវិកាឃុំ ........ ៦៤
**សេចក្តីសន្និដ្ឋាន** ........ ៦៦
**អនុសាសន៍** ........ ៦៨
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

## បញ្ជីអក្សរកាត់

- គ.ក.ន.ក ៖ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- គ.ផ.ថ ៖ គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់
- ស.ជ.ណ ៖ សេចក្តីជូនដំណឹង

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ស្ថិតនៅក្នុងចក្ខុវិស័យនៃការគ្រប់គ្រង និងដឹកនាំប្រទេសដើម្បីឆ្ពោះទៅរកវឌ្ឍនភាពដូចបណ្ដាប្រទេសជឿនលឿននៅលើពិភពលោក រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅទៅលើវិស័យសំខាន់ៗមួយចំនួនរួមមានដូចជា ១.ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ២. ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៣.ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ ៤.កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។ ក្នុងនោះផងដែរកំណែទម្រង់រដ្ឋបាលសាធារណៈដែលស្ថិតក្នុងចំណោមកំណែទម្រង់សំខាន់ៗទាំងបួន គឺជាផ្នែកមួយនៃគោលនយោបាយយុទ្ធសាស្ត្រចតុកោណកោណរបស់រាជរដ្ឋាភិបាលកន្លងទៅ ដែលត្រូវបានរៀបចំឡើងដើម្បីកសាងរដ្ឋបាលសាធារណៈឱ្យកាន់តែមានភាពឆ្លើយតប ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ដែលបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង និងធ្វើយ៉ាងណាសំដៅឆ្លើយតបទាន់ពេលវេលានៃតម្រូវការរបស់ប្រជាពលរដ្ឋតាមរយៈការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋជាពិសេសដើម្បីធ្វើការជំរុញ និងពន្លឿនកំណើនសេដ្ឋកិច្ចជាតិឱ្យមានសន្ទុះខ្លាំងក្លាទៅមុខ។

ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជាបានធ្វើការរៀបចំដាក់ចេញឱ្យអនុវត្តនូវប្រព័ន្ធរដ្ឋបាលថ្មីមួយតាមបែបវិមជ្ឈការដែលជាការផ្ទេរនូវសិទ្ធិអំណាចមួយចំនួនពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការគ្រប់គ្រង និងផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់នីមួយៗដែលរដ្ឋមិនអាចផ្តល់ជូនបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនោះ។ ក្នុងន័យនេះរាជរដ្ឋាភិបាលបានសម្រេចអនុម័តបង្កើតច្បាប់មួយចំនួនដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិរួមមានដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បង្កើតឡើងនៅឆ្នាំ២០០១, ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ២០០១ ហើយក្រោយមកទៀតក៏បានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងក្របខ័ណ្ឌទូទាំងប្រទេសនៅឆ្នាំ២០០២ផងដែរ។

ជាការពិតណាស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាអាជ្ញាធរវិមជ្ឈការដែលត្រូវបានទទួលស្គាល់ថាជាតំណាងរបស់រដ្ឋមួយដែលមានទីតាំងនៅតាមមូលដ្ឋាននានាទូទាំងប្រទេស។ មិនតែប៉ុណ្ណោះក្រុមប្រឹក្សាឃុំ សង្កាត់គឺជាសេនាធិការរបស់រាជរដ្ឋាភិបាល ហើយរដ្ឋមានភាពស្និទ្ធស្នាលជាមួយអាជ្ញាធររបស់ខ្លួនថែមទៀតផង។

ចាប់តាំងពីឆ្នាំ២០០១មក ឃុំ សង្កាត់បានក្លាយខ្លួនទៅជាភ្នាក់ងារវិមជ្ឈការដោយស្ថិតក្រោមការគ្រប់គ្រងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ឃុំ សង្កាត់មានស្វ័យភាពផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងដោយខ្លួនឯង ប៉ុន្តែត្រូវស្ថិតនៅក្រោមការពិនិត្យដោយប្រយោលពីស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋលើកិច្ចការមួយចំនួន

ដែលចាំបាច់តាមរយៈច្បាប់ និងលិខិតបទដ្ឋាននានាបានផ្តល់ឱ្យឃុំ សង្កាត់មានសមត្ថកិច្ច និងតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ទន្ទឹមនឹងនេះក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាអ្នកដែលយល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋជាងគេ និងដឹងច្បាស់ថាត្រូវកសាងអ្វីខ្លះដែលជាកង្វះខាត ឬជួសជុលអ្វីនៅមូលដ្ឋានរបស់ខ្លួនដើម្បីបង្កភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋ។ ម្យ៉ាងវិញទៀតបើយើងពិនិត្យទៅលើការធ្វើកំណែទម្រង់រដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការនោះយើងឃើញថាប្រជាពលរដ្ឋទទួលបាននូវអត្ថប្រយោជន៍ជាច្រើន និងការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការរបស់ពួកគាត់ ជាពិសេសថែមទាំងអាចចូលរួមកាត់បន្ថយនូវភាពក្រីក្រ និងនាំឱ្យមានការអភិវឌ្ឍដល់ប្រទេសជាតិថែមទៀតផង។ កំណែទម្រង់ប្រព័ន្ធវិមជ្ឈការនេះ គឺមានគោលបំណងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។

ដោយឡែកការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនៅឃុំតាំងយ៉ាប នៅមិនទាន់មានដំណើរការរលូននោះទេ ព្រោះជាក់ស្តែងការគ្រប់គ្រងរដ្ឋបាលឃុំនេះហាក់ដូចជាមិនទាន់បានឆ្លើយតបទៅនឹងតម្រូវការដែលប្រជាពលរដ្ឋចង់បាននៅឡើយ។ យើងសង្កេតឃើញថា ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នៅមានបញ្ហារាំងស្ទះមួយចំនួនចំពោះកិច្ចដំណើរការនៃការអនុវត្ត។ អាស្រ័យហេតុនេះយើងនឹងធ្វើការសិក្សាស្រាវជ្រាវទៅលើកិច្ចដំណើរការនៃការគ្រប់គ្រងរដ្ឋបាលរបស់ឃុំខាងលើដោយផ្ទាល់ថា តើមានដំណើរប្រព្រឹត្តទៅយ៉ាងដូចម្តេច?

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាបតាមបែបវិមជ្ឈការ" នេះបានចោទជាចំណោទបញ្ហាមួយចំនួនដូចខាងក្រោម៖

១. តើការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាប មានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. តើក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ? ហើយបានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានកម្រិតណា?

៣. តើមានបញ្ហាប្រឈមអ្វីខ្លះដែលជាកត្តានាំឱ្យមានការរាំងស្ទះដល់ការអភិវឌ្ឍឃុំ សង្កាត់?

៤. តើឃុំត្រូវមានដំណោះស្រាយយ៉ាងណាខ្លះដើម្បីធ្វើការកែលម្អ និងដោះស្រាយបញ្ហាប្រឈមទាំងអស់នោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទ បានក្តោបរួមទៅលើការស្វែងយល់បន្ថែមនៃចំណេះដឹង និងចងក្រងទុកជាឯកសារសម្រាប់កត់ត្រា ឆ្លុះបញ្ចាំងនូវចំណុចខ្លាំង ចំណុចខ្សោយជាការចាំបាច់ ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងឃុំ សង្កាត់នីមួយៗ ជាពិសេសជំរុញឱ្យមានការអភិវឌ្ឍឃុំ សង្កាត់មានភាពរីកចម្រើន និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឃុំប្រកបដោយភាពល្អប្រសើរ។

គោលបំណងដែលជំរុញឱ្យមានការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះគឺៈ

១. ដើម្បីសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់អំពីតថភាពជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

២. ដើម្បីសិក្សាស្វែងយលអំពីដំណើរការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

៣. ដើម្បីសិក្សាស្វែងយល់ពីដំណើរការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់

៤. ដើម្បីសិក្សាស្វែងយល់អំពីដំណើរការអភិវឌ្ឍរបស់ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅក្នុងរបបគំហើញខាងលើនេះ យើងនឹងយកមកប្រើប្រាស់ដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាតមួយចំនួនដែលជាកត្តារាំងស្ទះដល់ដំណើរការនៃការគ្រប់គ្រង និងការអភិវឌ្ឍរបស់ឃុំតាំងយ៉ាប

៥. ដើម្បីស្វែងយល់បន្ថែមពីរបៀបនៃការគ្រប់គ្រងចំណូល និងចំណាយនៃប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ។

## ៤. ដែនកំណត់ និងទំហំនៃការស្រាវជ្រាវ

ចំពោះដែនកំណត់ និងទំហំនៃការស្រាវជ្រាវទៅលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាបតាមបែបវិមជ្ឈការនេះ មានវិសាលភាពគ្របដណ្តប់តែទៅលើសកម្មភាពការងាររបស់រដ្ឋបាលឃុំតាំងយ៉ាប ស្ថិតនៅក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលជាទីតាំងត្រូវធ្វើការសិក្សាស្រាវជ្រាវ។ ក្នុងនោះផងដែរយើងខ្ញុំបានកំណត់រយៈពេលនៃការអនុវត្តការងារស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤ តាមការកំណត់។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការលើកយកនូវប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាបតាមបែបវិមជ្ឈការ" មកធ្វើការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សាផ្នែករដ្ឋបាលសាធារណៈ ព្រោះថាការសិក្សាតែទៅលើទ្រឹស្តីមួយមុខវាមិនទាន់គ្រប់គ្រាន់នៅឡើយទេ គឺទាមទារឱ្យមានការអនុវត្តជាក់ស្តែងទៀតទើបល្អប្រសើរ នេះគឺជាឱកាសដ៏ល្អក្នុងការចុះទៅសិក្សាស្រាវជ្រាវដោយផ្ទាល់ដល់ទីកន្លែង ដើម្បីទទួលបាននូវបទពិសោធថ្មីៗ បន្ថែមពីការសិក្សាទ្រឹស្តីនៅក្នុងសាលា។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះបានផ្តល់ឱ្យយើងខ្ញុំក្នុងការសិក្សាដើម្បីពិភាក្សាមូលមតិយោបល់ ទស្សនៈ ការយល់ឃើញទៅវិញទៅមក សំខាន់ជាងនេះទៅទៀតនោះគឺទទួលបាននូវចំណេះដឹង និងបទពិសោធថ្មីៗផ្សារភ្ជាប់ទៅនឹងការងាររដ្ឋបាលនៅមូលដ្ឋានដែលជាផ្នែកមួយដ៏សំខាន់ក្នុងការសិក្សាលើមុខជំនាញរដ្ឋបាលសាធារណៈនេះ។ លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវជាចំណេះដឹង និងបទពិសោធដ៏ល្អប្រសើរសម្រាប់ខ្លួនឯងផ្ទាល់ និងសង្គមជាតិទាំងមូលតាមរយៈការកែលម្អនូវចំណុចខ្វះខាតផ្សេងៗ ដើម្បីជំរុញឱ្យមានការអភិវឌ្ឍនៅមូលដ្ឋាន ជាពិសេសគឺទុកជាឯកសារសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយបានអាន និងបានស្វែងយល់ផងដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាបតាមបែបវិមជ្ឈការ" គឺគ្រាន់តែជាសារណាបញ្ចប់ការសិក្សាប៉ុណ្ណោះ ដូច្នេះយើងសិក្សាស្រាវជ្រាវ និងដកស្រង់លើកយកនូវឯកសារដែលមានស្រាប់ដូចជា ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា សៀវភៅរបាយការណ៍ ឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ និងស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណេតជាដើម។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានខិតខំស្វែងរកឯកសារនៅតាមទីកន្លែងនានាដូចជានៅតាមបណ្ណាល័យ បណ្ណាគារ តូបលក់សៀវភៅមួយចំនួន ដើម្បីយកមកធ្វើជាឯកសារយោងឱ្យបានទូលំទូលាយ។ មិនត្រឹមតែប៉ុណ្ណោះ យើងខ្ញុំបានសម្រេចចិត្តចុះសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមទៀតនៅទីតាំងដែលបានកំណត់ ស្ថិតនៅក្នុងឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវតែម្តង។ ការចុះទៅដល់មូលដ្ឋានផ្ទាល់បែបនេះគឺដើម្បីជួបសម្ភាសន៍ជាមួយនឹងលោកមេឃុំ ស្មៀនឃុំ ព្រមទាំងប្រជាពលរដ្ឋ ដើម្បីបានយល់កាន់តែច្បាស់ពីដំណើរការការងារ និងតថភាពជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងស្នើសុំឯកសារទិន្នន័យព័ត៌មានពិតប្រាកដយកមកចងក្រងធ្វើជាសារណានេះឡើង។ ការប្រមូលឯកសារទិន្នន័យព័ត៌មានជាច្រើនប្រភពមកនេះ គឺដើម្បីធ្វើការសិក្សាប្រៀបធៀប និងឆ្លុះបញ្ចាំងរវាងទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ជាមួយនឹងការងារជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលនៅក្នុងឃុំតាំងយ៉ាប។

## ៧. រចនាសម្ព័ន្ធនៃសារណា

ក្នុងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងឃុំតាំងយ៉ាប បានបែងចែកចេញជា ៣ ជំពូកដូចខាងក្រោមនេះ៖

**សេចក្តីផ្តើម៖** យើងខ្ញុំនឹងនិយាយអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី១៖** ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់ យើងនឹងនិយាយអំពីការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ទិសដៅ ការរៀបចំ និងការគ្រប់គ្រងរដ្ឋបាល កិច្ចការរដ្ឋបាល និងតួនាទីភារកិច្ចឃុំ សង្កាត់ជាដើម។

**ជំពូកទី២៖** ដំណើរការគ្រប់គ្រងរដ្ឋបាលក្នុងឃុំតាំងយ៉ាប ដែលយើងនិយាយអំពីស្ថានភាពភូមិសាស្ត្រប្រជាសាស្ត្រ ការរៀបចំរដ្ឋបាលឃុំ សង្កាត់ និងផែនការអភិវឌ្ឍឃុំតាំងយ៉ាប។

**ជំពូកទី៣៖** យើងនិយាយអំពីបញ្ហាប្រឈម និងដំណោះស្រាយ ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច រួមទាំងស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងបញ្ហាមួយចំនួនទៀតដែលរដ្ឋបាលថ្នាក់ជាតិបានដាក់មក។

# ជំពូកទី១
# ការគ្រប់គ្រង និងការប្រព្រឹត្តទៅ
# នៃរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី១
# ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់

## ១.១. ការគ្រប់គ្រងរដ្ឋបាល

### ១.១.១. និយមន័យគ្រប់គ្រង

ពាក្យថាគ្រប់គ្រង ឬគ្របគ្រង ត្រូវបានផ្សំឡើងរវាងពាក្យ២គឺ គ្រប់ឬគ្រប+គ្រង

- គ្រប (កិរិយាសព្ទ) បិទខ្ទប់ពីលើ។ ឧទាហរណ៍ គ្រប់ឆ្នាំងឱ្យជិត គ្របពាងឱ្យជិត
- គ្រប (នាមសព្ទ) ប្រដាប់សម្រាប់បិទខ្ទប់ពីលើ។ ឧទាហរណ៍ គ្របពាង គ្របបាត្រ
- គ្រប់ (គុណសព្ទ) ពេញត្រឹម របស់នេះគ្រប់ចំនួនគ្មានខ្វះ
- គ្រង (កិរិយាសព្ទ) ចាំថែរក្សា រក្សាជាជំនួស
- គ្រង (សង្ឃសព្ទ) ស្លៀកដណ្តប់ត្រៃចីវរ។ ឧទាហរណ៍ លោកសង្ឃគ្រងចីវរ។

ដូចនេះពាក្យថាគ្រប់គ្រង យើងអាចឱ្យនិយមន័យជារួមថា គឺជាដំណើរការនៃការអនុវត្ត ចាត់ចែង និង គ្រប់គ្រងការងារដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័នណាមួយដោយមានទំនួលខុសត្រូវខ្ពស់ដើម្បីធ្វើឱ្យការងារនោះមានប្រសិទ្ធភាពល្អប្រសើរឆ្លើយតបទៅនឹងការរំពឹងទុក។

ពាក្យថា គ្រប់គ្រង មានន័យថា បីបាច់ ថែរក្សា ថែទាំដោយទទួលរងបន្ទុក រងខុសត្រូវលើខ្លួន។[1]

### ១.១.២. និយមន័យរដ្ឋបាល

រដ្ឋបាល (Administration) ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើន ប៉ុន្តែនៅក្នុងទីនេះ យើងសូមលើកយកអត្ថន័យបី មកធ្វើការបង្ហាញគឺ៖

#### ១.១.២.១. អត្ថន័យអក្សរសាស្ត្រ

រដ្ឋបាល មកពីពាក្យថា រដ្ឋ+បាល

រដ្ឋ (ជាពាក្យបាលី) មានន័យថា ដែន ប្រទេស អ្នកនៅដែន រាស្ត្រ ប្រជាជន។[2] ឧទាហរណ៍ រដ្ឋកិច្ច រដ្ឋធម្មនុញ្ញ រដ្ឋាភិបាល ជាដើម។ល។

បាល (ជាពាក្យបាលី) មានន័យថា ការថែរក្សា ការគ្រប់គ្រង។ ជារួមមករដ្ឋបាលមានន័យថា អ្នករក្សាដែន ឬប្រទេស។[3] ឧទាហរណ៍ ក្រសួង រាជការកាន់កាប់កិច្ចការក្នុងប្រទេសជាគូគ្នានឹងតុលាការ មន្ត្រីខាងរដ្ឋបាល គ្របខណ្ឌខាងរដ្ឋបាល។

---

[1] សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ (ភ្នំពេញ៖ ពុទ្ធសាសនាបណ្ឌិត្យឆ្នាំ១៩៦៧),១៥០

[2] សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ (ភ្នំពេញ៖ ពុទ្ធសាសនាបណ្ឌិត្យឆ្នាំ១៩៦៧),៩៧៥

[3] សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ (ភ្នំពេញ៖ ពុទ្ធសាសនាបណ្ឌិត្យឆ្នាំ១៩៦៧),៩៧៦

**១.១.២.២. អត្ថន័យតាមបែបសម្ភារៈ**

រដ្ឋបាល មានន័យថាសកម្មភាពគ្រប់គ្រង។ ឧទាហរណ៍ៈ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមប្រឹក្សាសាលាខេត្ត មេឃុំ ទទួលបន្ទុកគ្រប់គ្រងនៅក្រសួង នៅសាលាខេត្ត នៅសាលាឃុំ។[4]

**១.១.២.៣. អត្ថន័យតាមបែបអង្គការ**

រដ្ឋបាល សំដៅលើអង្គការគ្រប់គ្រងពោលគឺបណ្តុំនៃមន្ត្រីរាជការ ដែលបំពេញសកម្មភាពគ្រប់គ្រង។ ឧទាហរណ៍ៈ ក្រុមប្រឹក្សារាជធានី ក្រសួង។[5]

សរុបមក រដ្ឋបាល គឺបណ្តុំនៃមន្ត្រីរាជការ (អង្គការគ្រប់គ្រង) ដែលបំពេញការងារប្រចាំថ្ងៃពីការងារធំដល់តូចពាក់ព័ន្ធនឹងការបម្រើប្រយោជន៍សាធារណៈ (សកម្មភាពគ្រប់គ្រង)។[6]

**១.១.៣. និយមន័យវិមជ្ឈការ**

វិមជ្ឈការ មានន័យថារាជរដ្ឋាភិបាលបានប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនមូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ។[7]

ដូច្នេះ រដ្ឋត្រូវតែប្រគល់អំណាចមួយចំនួនទៅឱ្យឃុំ សង្កាត់សម្រាប់សម្រេចកិច្ចការមូលដ្ឋានខ្លួនឯងផ្ទាល់ដោយមិនចាំបាច់សុំការអនុញ្ញាតពីអាជ្ញាធរថ្នាក់កណ្តាលឡើយដោយគ្រាន់តែមានការត្រួតពិនិត្យតាមនីត្យានុកូលភាពលើសេចក្តីសម្រេចរបស់រដ្ឋតែប៉ុណ្ណោះ។ តាមរយៈឃុំ សង្កាត់ទទួលបាននូវអំណាចការទទួលខុសត្រូវ មួយចំនួនដែលប្រគល់ឱ្យដោយច្បាប់ និងមានមធ្យោបាយមួយចំនួនគឺជាថវិការបស់ឃុំ សង្កាត់ដោយផ្ទាល់ ឬធនធានដែលមាននៅក្នុងឃុំ សង្កាត់ ដើម្បីអនុវត្តកម្មវិធីរបស់ខ្លួនដែលហៅថា "វិមជ្ឈការ" ។

របៀបគ្រប់គ្រងផ្តល់ឋានៈដល់មូលដ្ឋាននូវបុគ្គលភាពច្បាប់ទទួលស្គាល់។ អំណាចកណ្តាលមិនត្រូវបានផ្តុំនៅក្នុងដៃរដ្ឋតែម្នាក់ឯងនោះទេពោលគឺជាការប្រគល់អំណាចទៅឱ្យថ្នាក់ក្រោមតាមរយៈច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានបង្កើតឱ្យឃុំ សង្កាត់ដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែល

---

4 លោក ធន សុងឃុយ មេរៀនស្តីពីនីតិរដ្ឋបាលទូទៅ,១

5 លោក ធន សុងឃុយ មេរៀនស្តីពីនីតិរដ្ឋបាលទូទៅ,១

6 លោក ធន សុងឃុយ មេរៀនស្តីពីនីតិរដ្ឋបាលទូទៅ,១

7 ក្រសួងមហាផ្ទៃ, ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការ, ឆ្នាំ២០១៧

ទទួលបាននូវសិទ្ធិអំណាចនៅក្នុងការអនុវត្តការងារ និងសម្រេចកិច្ចការដោយភាពជាម្ចាស់ការ និងទទួលខុសត្រូវដោយអនុវត្តតាមលទ្ធិប្រជាធិបតេយ្យដោយមានប្រជាពលរដ្ឋចូលរួម។

**១.១.៤. និដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ**

ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ ហើយប្រជាពលរដ្ឋត្រូវបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវឱ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ ដូច្នេះក្រុមប្រឹក្សានេះជាតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវបានផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។[8] ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្តល់ការទទួលខុសត្រូវ និងភារកិច្ចជាច្រើនដែលខុសប្លែកទាំងស្រុងពីការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់កាលពីមុនការបោះឆ្នោតឆ្នាំ២០០២។ ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់គឺអភិវឌ្ឍឃុំ សង្កាត់ លើកកម្ពស់សុខុមាលភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនថែមទៀតផង។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឱ្យបានថាសហគមន៍នៅមូលដ្ឋានបានចូលរួមយ៉ាងពេញលេញ និងសកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសេចក្តីសម្រេចនានាដែលមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជា សេចក្តីសម្រេចលើការប្រើប្រាស់ធនធានសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួនជាដើម។ ការធ្វើសេចក្តីសម្រេចដែលមានការចូលរួមពីប្រជាពលរដ្ឋទើបសេចក្តីសម្រេចនោះទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ក្រុមប្រឹក្សាឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកា ទ្រព្យសម្បត្តិ និងបុគ្គលិកផ្ទាល់ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។បន្ថែមលើនេះក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានស្មៀនមួយរូបដែលត្រូវតែងតាំងដោយក្រសួងមហាផ្ទៃ។

**១.១.៥. ការអនុវត្តវិមជ្ឈការ**

ព្រះរាជាណាចក្រកម្ពុជាបានកំណត់យកនូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ឃុំ សង្កាត់ជារដ្ឋបាលមួយដែលមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជាប្រចាំជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានដែនដីរបស់ខ្លួន។ រដ្ឋបាលថ្នាក់ឃុំ សង្កាត់កើតចេញដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងឃុំសង្កាត់ដែលបានធ្វើការបោះឆ្នោតជ្រើសរើសជាតំណាង ដូច្នេះប្រជាពលរដ្ឋជាម្ចាស់លើរដ្ឋបាលនោះ។ ការធ្វើវិមជ្ឈការនៅឃុំ សង្កាត់ធ្វើឱ្យលទ្ធិប្រជាធិបតេយ្យបានចាក់ឫសកាន់តែរឹងមាំថែមទៀត ដោយសារឃុំ សង្កាត់មានសិទ្ធិ និងអំណាចក្នុងការគ្រប់គ្រង និងចាត់ចែងការងារដោយសេរីត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។ ទោះបីជាជួបប្រទះនូវការលំបាកខាងផ្នែកហិរញ្ញវត្ថុឬមធ្យោបាយសម្ភារៈយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលបានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាលដើម្បី

[8] មាត្រា១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

រៀបចំកសាងប្រព័ន្ធគ្រប់គ្រងវិមជ្ឈការ ជំរុញការស្តារ និងអភិវឌ្ឍសង្គមមួយប្រកបដោយស្ថេរភាព និងវឌ្ឍនភាព ឆ្ពោះទៅកាន់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

វិមជ្ឈការជាទម្រង់បែបបទមួយដែលជំរុញលទ្ធិប្រជាធិបតេយ្យក្នុងការទទួលខុសត្រូវ និងកាត់បន្ថយនូវអំពើពុករលួយជាដើម។ ការជំរុញឱ្យមានការអភិវឌ្ឍដោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋនេះគឺដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅទីជនបទ។

វិមជ្ឈការអាចធ្វើទៅបានគឺអាស្រ័យទៅលើកត្តាធនធានមនុស្ស កត្តាធនធានហិរញ្ញវត្ថុ និងបទពិសោធ។ ធ្វើដូច្នេះ ដើម្បីធ្វើឱ្យការអនុវត្តនូវការគ្រប់គ្រងមូលដ្ឋានឃុំ សង្កាត់មានការទទួលខុសត្រូវដោយផ្ទាល់ ក្នុងការប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួន និងបង្កលក្ខណៈឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមបែបប្រជាធិបតេយ្យ សំដៅដល់ការបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋឱ្យមានភាពល្អប្រសើរឡើង។

### ១.១.៦. ហេតុផលនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

ប្រទេសដែលអនុវត្តតាមគោលការណ៍វិមជ្ឈការ នាំមកនូវភាពរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក៏ដូចជាការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងដោះស្រាយនូវបញ្ហាការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើងដោយផ្តោតការយកចិត្តទុកដាក់ទៅលើការទទួលខុសត្រូវផ្ទាល់នៅមូលដ្ឋាន។ វិមជ្ឈការឃុំ សង្កាត់នេះគឺត្រូវបានអ្នកនយោបាយទាំងឡាយផ្តួចផ្តើមឡើង និងអនុម័តយល់ព្រមអំពីកំណែទម្រង់វិមជ្ឈការនេះហើយរាជរដ្ឋាភិបាលបានខិតខំធ្វើកំណែទម្រង់ការគ្រប់គ្រងវិមជ្ឈការនៅឃុំ សង្កាត់ដើម្បីទទួលបាននូវសមិទ្ធផលជាច្រើនដូចជាកាត់បន្ថយនូវភាពមិនអើពើចំពោះការអភិវឌ្ឍនៅមូលដ្ឋាន ជំរុញឱ្យមានការចូលរួម និងសកម្មភាពរួបរួមផ្សេងៗរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យកាន់តែខ្លាំងឡើង។ ពង្រឹងការឆ្លើយតបឱ្យបានឆាប់រហ័ស និងយល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ។ បង្កើននូវលំហូរព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឱ្យគម្រោងអភិវឌ្ឍន៍មានចីរភាព ពង្រឹងនូវតម្លាភាព ជំរុញការទទួលខុសត្រូវកាន់តែខ្ពស់ និងធ្វើឱ្យសម្រេចបាននូវកិច្ចព្រមព្រៀងថ្មីៗជាពិសេសធ្វើឱ្យកម្មវិធីអភិវឌ្ឍន៍កាន់តែរលូនជាងមុន កាត់បន្ថយសកម្មភាពពុករលួយ និងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន។

## ១.២. ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ការធ្វើវិមជ្ឈការ គឺដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។ លើសពីនេះទៅទៀតដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាពិសេសធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាឱ្យនៅជិតប្រជាពលរដ្ឋ និងយល់ច្បាស់អំពីតម្រូវការរបស់ពួកគាត់។

### ១.២.១. ការផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចនានា

តាមរយៈប្រព័ន្ធអភិបាលកិច្ចនៅមូលដ្ឋានឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូបរួមមាន បុរស ស្ត្រី ចាស់ ក្មេង ជនងាយរងគ្រោះ។ល។ មានសិទ្ធិ និងចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ឃុំ សង្កាត់នៃដំណើរការអភិវឌ្ឍមូលដ្ឋានដូចជា ការបញ្ចេញមតិ និងរួមចំណែកតាមមធ្យោបាយផ្សេងៗ។ ម្យ៉ាងទៀតប្រជាពលរដ្ឋមានសិទ្ធិលើកឡើងអំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួនតាមរយៈនីតិវិធី និងយន្តការដែលបានកំណត់ក្នុងក្របខ័ណ្ឌវិមជ្ឈការ លិខិតបទដ្ឋាន និងសេចក្តីណែនាំនានា។ ប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលពួកគាត់គិតថាអាចតំណាងឱ្យផលប្រយោជន៍របស់ពួកគាត់បានល្អប្រសើរបំផុត និងអាចបង្កើតទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការងារដែលពាក់ព័ន្ធនឹងការអភិវឌ្ឍឃុំ សង្កាត់។ ជាងនេះទៅទៀតប្រជាពលរដ្ឋអាចលើកឡើងពីបញ្ហា និងផលប្រយោជន៍របស់ពួកគាត់ជាមួយសមាជិកក្រុមប្រឹក្សា ដើម្បីឱ្យសមាជិកក្រុមប្រឹក្សាលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ឬតាមរយៈការចាត់ចែងកិច្ចការប្រចាំថ្ងៃរបស់រដ្ឋបាលឃុំ សង្កាត់ដោយមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ស្មៀនឃុំ សង្កាត់។ ជាពិសេសតាមដានត្រួតពិនិត្យការអនុវត្តគម្រោងនៅមូលដ្ឋាន ការផ្តល់សេវា ការអនុវត្តសកម្មភាពនានានៅក្នុងមូលដ្ឋានរបស់ខ្លួន និងការទទួលបានព័ត៌មានផ្សេងៗដែលពួកគាត់ចង់ដឹងគឺមានលក្ខណៈងាយស្រួល និងសុក្រឹត។ ការផ្តល់ឱកាសដល់ប្រជាពលរដ្ឋចូលរួមពេញលេញគឺជាភារកិច្ចយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយការចូលរួមនេះអាចជួយឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ស្វែងយល់ពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងធ្វើការឆ្លើយតបឱ្យចំគោលដៅ ប្រសិនបើប្រជាពលរដ្ឋបានចូលរួមគឺពួកគាត់នឹងមានអារម្មណ៍ថា ខ្លួនបានចូលរួមក្នុងការទទួលខុសត្រូវចំពោះការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន ដូចនេះរាល់សេចក្តីសម្រេចចិត្តលើគម្រោងអភិវឌ្ឍន៍ស្ទើរតែទាំងអស់គឺទទួលបាននូវប្រសិទ្ធភាព និងប្រសិទ្ធផល។

### ១.២.២. ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ

វិមជ្ឈការត្រូវបានចាត់ទុកថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញអភិបាលកិច្ចល្អហើយអភិបាលកិច្ចល្អគឺជាការអនុវត្តការងារឱ្យបានសម្រេចទៅនឹងទិដ្ឋភាពសំខាន់ៗមួយចំនួនដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញការងារដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលបានកំណត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យដោយប្រជាពលរដ្ឋរបស់ខ្លួន ដូចនេះអ្វីដែលក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេច និងអនុវត្តគឺត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះមុខប្រជាពលរដ្ឋរបស់ខ្លួន មានន័យថាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើផែនការឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋត្រូវ ផ្តល់ព័ត៌មានពីរបៀបប្រើប្រាស់ធនធានដែលខ្លួនមាន និងត្រូវធានាថាធនធានទាំងនោះពិតជាត្រូវបានប្រើប្រាស់ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ពិសេសជាងនេះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតម្លាភាពនៅក្នុងការងារដែលខ្លួនបានបំពេញទាំងអស់ ហើយត្រូវជម្រាបជូនសាធារណជនពីកិច្ចការនានាដែលខ្លួនបានពិភាក្សា ឬសេចក្តីសម្រេចដែលខ្លួនបានធ្វើ

ដូចជា ការផ្សព្វផ្សាយដល់សាធារណជនតាមគ្រប់មធ្យោបាយ និងការទទួលមតិយោបល់របស់សាធារណជនអំពីការកសាងផែនការអភិវឌ្ឍន៍ និងការរៀបចំថវិកាឃុំ សង្កាត់ ការផ្សព្វផ្សាយជាសាធារណៈអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈការបិទផ្សាយនៅលើក្ដារខៀនព័ត៌មានឃុំ សង្កាត់ឬតាមមធ្យោបាយផ្សេងៗទៀតនៅមូលដ្ឋាន ទើបការអនុវត្តទទួលបានលទ្ធផលល្អប្រសើរ ហើយការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាសមាសធាតុយ៉ាងសំខាន់មួយនៅក្នុងអភិបាលកិច្ចល្អ។

### ១.២.៣. ធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្ដល់សេវាជាមូលដ្ឋាន

ក្រុមប្រឹក្សាឃុំ សង្កាត់ស្ថិតនៅកៀកកិតជាមួយនឹងប្រជាពលរដ្ឋ ហើយអាចដឹងច្បាស់អំពីសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ។ ម្យ៉ាងទៀតក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំផែនការ និងកម្មវិធីដើម្បីលើកកម្ពស់ និងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់យ៉ាងមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ប្រជាពលរដ្ឋអាចពិនិត្យមើលការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ថាតើការប្រើប្រាស់ធនធានទាំងនោះពិតជាបម្រើឱ្យផលប្រយោជន៍របស់ខ្លួនដែរឬទេ? ប្រសិនបើប្រជាពលរដ្ឋបានចូលរួមនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងការអនុវត្តគម្រោងនានានៅមូលដ្ឋានរបស់ខ្លួន នោះនឹងធ្វើឱ្យពួកគាត់កាន់តែទទួលខុសត្រូវច្រើនថែមទៀតនៅក្នុងការអនុវត្តផែនការទាំងនោះ។

## ១.៣. ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.៣.១. រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំនីមួយៗមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួន ដោយផ្អែកតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំមានសមាជិកពី៥ទៅ១១រូប ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន។[9] ចំនួនជាក់ស្ដែងនៃសមាជិកក្រុមប្រឹក្សាឃុំត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំនីមួយៗមានប្រធាន១រូបដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ ហើយប្រធានក្រុមប្រឹក្សាឃុំគឺជាមេឃុំ ឬចៅសង្កាត់។[10] ឃុំនីមួយៗមានមេឃុំម្នាក់។ ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសធ្វើជាមេឃុំដោយផ្អែកតាមលទ្ធផលនៃការបោះឆ្នោត។ មេឃុំមានជំនួយការ២រូប គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២។[11] មេឃុំនីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗក្នុងឃុំរបស់ខ្លួន។[12] មេឃុំ អាចចាត់តាំងបង្កើតគណៈកម្មាធិការនានាដើម្បី

[9] មាត្រា១២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[10] មាត្រា២៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[11] មាត្រា២៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[12] មាត្រា៣០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

ផ្តល់យោបល់ និងជួយកិច្ចការបានតាមការចាំបាច់។[13] ឃុំនីមួយៗមានស្មៀន១រូបដែលត្រូវបានតែងតាំង និងបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ។[14]

តារាងរចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់




### ១.៣.២. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់។[15] ការបោះឆ្នោតនេះត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដោយការបោះឆ្នោតទូទៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នាគឺប្រព្រឹត្តទៅនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់។ កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[16] នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល៩ខែយ៉ាងតិចមុនថ្ងៃបោះឆ្នោត។

[13] មាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[14] មាត្រា២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[15] មាត្រា២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៥

[16] មាត្រា៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៥

### ១.៣.២.១. ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត

បេក្ខជនដែលមានបំណងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ស្តីពីគណបក្សនយោបាយ។[17]បន្ទាប់មកគណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលទទួលបានការផ្ទេរសិទ្ធិ ទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច៩០ថ្ងៃមុនថ្ងៃបោះឆ្នោតដោយមានភ្ជាប់មកជាមួយនូវបញ្ជីរាយនាមបេក្ខជនដែលមានចំនួនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

**ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖**

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាន និងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។[18]

**បេក្ខជនដែលត្រូវហាមមិនឱ្យឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួមមាន៖**

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង
- ព្រះសង្ឃ ឬបុព្វជិតសាសនា
- ស្មៀនឃុំ សង្កាត់។[19]

[17] មាត្រា៣៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៥

[18] មាត្រា៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៥

[19] មាត្រា៣៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៥

### ១.៣.៣. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងពីការបោះឆ្នោត ដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ និងមានស្វ័យភាពក្នុងការដឹកនាំ និងគ្រប់គ្រងការងារអភិវឌ្ឍន៍មូលដ្ឋាន តែក្រុមប្រឹក្សាឃុំ សង្កាត់ ជាផ្នែកមួយនៃអំណាចនីតិប្រតិបត្តិរបស់រដ្ឋដែលមានន័យថាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានជាធរមាន។

#### ១.៣.៣.១. ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់

ប្រធានក្រុមប្រឹក្សាឃុំ មានតួនាទីដូចខាងក្រោម៖

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិច១ដងក្នុងមួយខែ
- ធានាថាកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

#### ១.៣.៣.២. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

#### ១.៣.៣.៣. មេឃុំ ចៅសង្កាត់

ឃុំ សង្កាត់នីមួយៗមានមេឃុំ ឬចៅសង្កាត់ម្នាក់។ បុរស និងស្ត្រីអាចត្រូវបានជ្រើសរើសឱ្យធ្វើជាមេឃុំ ឬចៅសង្កាត់។ មេឃុំ ឬចៅសង្កាត់ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ធានាថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកាហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានុក្រមពេលខ្លួនអវត្តមាន។

### ១.៣.៣.៤. ជំទប់ទី១ ចៅសង្កាត់រងទី១

ជំទប់ទី១ ឬចៅសង្កាត់រងទី១ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្ដីទីក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

### ១.៣.៣.៥. ជំទប់ទី២ ចៅសង្កាត់រងទី២

ជំទប់ទី២ ឬចៅសង្កាត់រងទី២ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្ដាប់ធ្នាប់សាធារណៈ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្ដីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

### ១.៣.៣.៦. គណៈកម្មាធិការនានា

មេឃុំ ចៅសង្កាត់ អាចចាត់តាំងគណៈកម្មាធិការផ្ដល់យោបល់។ គណៈកម្មាធិការនេះមានសមាជិកយ៉ាងតិច ៣នាក់ (អាចយកក្នុងចំណោមក្រុមប្រឹក្សាឃុំ) ដើម្បីផ្ដល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនានាមានតួនាទីភារកិច្ចដូចជា៖

- ផ្ដល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជាការកសាងផែនការ និងថវិកា
- រាយការណ៍អំពីការវិវឌ្ឍន៍ការងារប្រចាំខែរបស់ខ្លួន
- ផ្ដល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធទៅនឹងការងារជាសមត្ថកិច្ចរបស់ខ្លួន។

### ១.៣.៣.៧. ស្មៀនឃុំ សង្កាត់

ឃុំ សង្កាត់នីមួយៗមានស្មៀន១រូប ដែលត្រូវបានតែងតាំង និងបម្រើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋបាលក្រសួងមហាផ្ទៃ។[20] ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ មានន័យថា ថ្វីត្បិតតែស្មៀនឃុំ សង្កាត់ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តការងារស្មៀនឃុំ សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ជាអ្នក ៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានាបំពេញតួនាទី និងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់

[20] មាត្រា២៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្របទៅនឹងលក្ខខណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ឬគណៈកម្មាធិការ លើកលែងតែបានទទួលការអនុញ្ញាតឱ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឱ្យមានក្តារខៀនព័ត៌មានមួយឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់សម្រាប់ឱ្យសាធារណជនទូទៅបានដឹងនូវព័ត៌មានទាំងនោះ។

***ភារកិច្ចជាច្រើនទៀតរបស់ស្មៀនឃុំ សង្កាត់ត្រូវបានកំណត់ នៅក្នុងប្រកាសលេខ១៣២៩ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់ក្រសួងមហាផ្ទៃស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់។***

### ១.៣.៣.៨. បុគ្គលិកឃុំ សង្កាត់

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួនបាន ប៉ុន្តែបុគ្គលិកប្រភេទនេះជាបុគ្គលិកផ្ទាល់។ បុគ្គលិកឃុំ សង្កាត់មានភារកិច្ចជួយកិច្ចការតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។[21]

### ១.៣.៣.៩. មេភូមិ និងជំនួយការមេភូមិ

#### ក. មេភូមិ

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- តំណាងឱ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់
- បង្កើនការពិគ្រោះយោបល់ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍៖

[21] មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- ផ្ដល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ
- ផ្ដល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ
- ផ្ដល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់អំពី៖

  + តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

  + ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន

  + ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន។

- ត្រូវធ្វើសេចក្ដីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវធានាផ្ដល់ព័ត៌មានជាឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ឯកសារព័ត៌មានទាំងនោះអាចរួមមានព័ត៌មានស្ដីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

**បញ្ជាក់៖**

☞ មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ។

☞ មេភូមិពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ។

☞ ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ។

**ខ. ជំនួយការមេភូមិ**

- **អនុប្រធានភូមិ** ទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមានដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជំងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី១ថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់។
- **សមាជិកភូមិ** ទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ។

**បញ្ជាក់៖** ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី។

## ១.៤. កិច្ចការរដ្ឋបាលឃុំ សង្កាត់

### ១.៤.១. លិខិតរដ្ឋបាលឃុំ សង្កាត់

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើជាផ្លូវការរួមមាន ដីកា សេចក្តីសម្រេច លិខិតស្នើ សេចក្តីជូនដំណឹង ឬលិខិតជូនដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីកាអមជាដើម។

#### ១.៤.១.១. ដីកាឃុំ សង្កាត់

ដីកាឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានរដ្ឋបាលកំណត់នូវបទបញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើងសំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅនៅក្នុងឃុំ សង្កាត់ដោយស្មើភាពមិនរើសអើង និងសម្រាប់គ្រប់កិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទីមុខងារ និងសិទ្ធិអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។ ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់(ការប្រជុំសាមញ្ញ ឬវិសាមញ្ញ) ដែលមានចំនួនច្រើនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

#### ១.៤.១.២. សេចក្តីសម្រេចឃុំ សង្កាត់

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានរដ្ឋបាលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើតការតែងតាំង ការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទីមុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចអញ្ជើញសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំបាន មេឃុំឬចៅសង្កាត់អាចចេញសេចក្តីសម្រេចដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះបាន។

#### ១.៤.១.៣. លិខិតរដ្ឋបាលផ្សេងៗទៀត

ក្រៅពីដីកា និងសេចក្តីសម្រេចឃុំ សង្កាត់ នៅមានលិខិតរដ្ឋបាលមួយចំនួនផ្សេងទៀតដូចជា៖

**លិខិតស្នើ:** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃសេចក្តីត្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់ រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

**សេចក្តីជូនដំណឹង:** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គល ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល មានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬការឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងឱ្យសាធារណជនបានដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។

**លិខិតអញ្ជើញ:** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ឱ្យចូលរួមក្នុងសកម្មភាពឃុំ សង្កាត់ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គល ឬស្ថាប័នទាំងនោះ ដោយមានបញ្ជាក់ឈ្មោះ ឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ។

**លិខិតបញ្ជាបេសកកម្ម:** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ ឱ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះត្រូវមានភ្ជាប់ជាមួយទិដ្ឋាការធ្វើដំណើរ។ ទិដ្ឋាការ ធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទ សម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្ម យកទៅចុះទិដ្ឋាការនៅទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ច ដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងឮអំពីការចេញដំណើរ និងការមកដល់ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ នៅពេលត្រឡប់មកវិញអ្នកដែលត្រូវបានចាត់តាំងនោះត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឱ្យបានជ្រាបអំពីលទ្ធផល ឬបញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម។

**របាយការណ៍:** គឺជាសេចក្តីរាយការណ៍អំពីសកម្មភាពដំណើរការ និងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ឬក្រុមណាមួយដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញឬបានចាត់តាំងឱ្យទៅបំពេញបេសកកម្ម ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។ ទម្រង់របាយការណ៍ប្រចាំខែ និងទម្រង់របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ (សេចក្តីជូនដំណឹងលេខ ១៧១ ស.ជ.ណ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤)។

**កំណត់ហេតុ:** គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងការឯកភាពលើសកម្មភាពដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយ ដែលបានកើតឡើងជាក់ស្តែងដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

**លិខិតផ្ទេរសិទ្ធិ:** គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិទៅឱ្យជំទប់ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទីក្នុងអំឡុងពេលដែលមេឃុំ ឬចៅសង្កាត់ អវត្តមាន។

**ដីកាអម:** គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើអមភ្ជាប់ជាមួយសំណុំលិខិតដែលត្រូវផ្ញើចេញទៅឱ្យអង្គភាពក្រសួង ស្ថាប័នណាមួយដោយមានកត់ត្រាឈ្មោះនិងចំនួនលិខិត (ឯកសារ) លើដីកាអមនោះ។ ឃុំ សង្កាត់ប្រើដីកាអម ដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់បានផ្ញើចេញ។

### ១.៤.២. ការគ្រប់គ្រងទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់មាន ៣ ប្រភេទគឺ ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលផ្ទេរសិទ្ធិឱ្យកាន់កាប់ ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯង និងទ្រព្យសម្បត្តិដែលបានមកពីអំណោយនានា។[22]

[22] មាត្រា៤៩ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

**ការកត់ត្រាចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ** ទ្រព្យសម្បត្តិ និងសម្ភារបរិក្ខារទាំងអស់របស់ឃុំ សង្កាត់ ត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវ។ បញ្ជីសារពើភ័ណ្ឌគ្រប់គ្រងទ្រព្យសម្បត្តិ និងសម្ភារបរិក្ខានេះត្រូវរក្សាទុកឱ្យបានល្អប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពយ៉ាងតិចក្នុងរយៈពេលមួយឆ្នាំម្តង។ ការកត់ត្រាទ្រព្យសម្បត្តិត្រូវបញ្ចូលនូវព័ត៌មានដូចជាលេខរៀង ឬលេខកូដ យថាប្រភេទ កាលបរិច្ឆេទផ្ទេរសិទ្ធិឱ្យកាន់កាប់បរិមាណ និងតម្លៃទីតាំងដែលទ្រព្យសម្បត្តិនោះទុកដាក់ ឬប្រើប្រាស់។[23] សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**ការលក់ដូរ និងការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ** ឃុំ សង្កាត់ពុំមានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលប្រគល់ឱ្យដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ។ ប៉ុន្តែឃុំ សង្កាត់អាចធ្វើការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលបានមកពីអំណោយបាន ដោយគោរពទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយ និងឃុំ សង្កាត់។ សម្រាប់ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯងផ្ទាល់ និងទ្រព្យសម្បត្តិផ្សេងទៀតដែលជាអំណោយគ្មានលក្ខខណ្ឌការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

- មេឃុំ ចៅសង្កាត់ត្រូវបង្កើតគណៈកម្មការចំពោះកិច្ចមួយដើម្បីត្រួតពិនិត្យលើការលក់ដូររបស់ផ្សេងៗ ឬផ្ទេរទ្រព្យសម្បត្តិ។ គណៈកម្មការនេះត្រូវដឹកនាំដោយមេឃុំ ចៅសង្កាត់ និងមានសមាជិកក្រុមប្រឹក្សា ១រូប និង ១រូបទៀតជាគណនេយ្យករឃុំ សង្កាត់នៅរតនាគារខេត្ត ក្រុង ស្មៀនឃុំ សង្កាត់ត្រូវធ្វើជាលេខាធិការ។
- ដំណើរការលក់ដូរឬផ្ទេរត្រូវធានាឱ្យមានតម្លាភាពនិងបើកទូលាយឱ្យមានការប្រកួតប្រជែងគ្នាពិតប្រាកដ។
- ក្នុងការលក់ឬផ្ទេរ ក្រុមប្រឹក្សាឃុំត្រូវសម្រេចតាមអនុសាសន៍នៃគណៈកម្មការចំពោះកិច្ច។
- ចំនួនទឹកប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិត្រូវរក្សាទុកក្នុងគណនីរបស់ឃុំនៅរតនាគារខេត្តក្រុង។[24]

### ១.៤.៣. ការគ្រប់គ្រងឯកសារឃុំ សង្កាត់

ឃុំ សង្កាត់ គឺជាម្ចាស់លើរាល់លិខិតនិងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់កម្មសិទ្ធិលើតែមប្រិ៍ ត្រាឃុំ សង្កាត់ ព្រមទាំងឧបករណ៍ផ្សេងៗទៀតទាំងអស់

[23] មាត្រា៥០ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

[24] មាត្រា៥៣ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

របស់ឃុំ សង្កាត់។[25]ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម តែមប្រើ ត្រាឱ្យបានត្រឹមត្រូវ និងគង់វង្ស។[26] ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយមានសណ្ដាប់ធ្នាប់ និងសុវត្ថិភាព។

### ១.៤.៤. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចចំនួន១ដងក្នុងមួយខែ ហើយការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើឡើងជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។ ក្រៅពីកិច្ចប្រជុំជាសាធារណៈនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចប្រជុំជាសម្ងាត់បានដែរ។

#### ១.៤.៤.១. លក្ខណៈនៃការប្រជុំក្រុមប្រឹក្សា

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួន១ដងក្នុងមួយខែ។ ក្នុងករណីចាំបាច់ក្រុមប្រឹក្សាអាចធ្វើការប្រជុំពិសេស ដើម្បីពិភាក្សាលើបញ្ហាទាំងឡាយណាដែលក្រុមប្រឹក្សាបានកំណត់ថាជាកិច្ចការពិសេស ឬកិច្ចការបន្ទាន់ចាំបាច់។ រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការជំនួយការត្រូវធ្វើឡើងជាសាធារណៈ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ឱ្យមានកិច្ចប្រជុំជាសម្ងាត់ ដើម្បីពិភាក្សាបញ្ហាដូចជាការដាក់វិន័យ ឬបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បញ្ហាសន្តិសុខក្នុងឃុំ សង្កាត់ ការរៀបចំសំណុំរឿងដើម្បីតវ៉ាឬការពារក្តីអ្វីមួយ និងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងកិត្តិយសបុគ្គលជាដើម។ នៅក្នុងកិច្ចប្រជុំសម្ងាត់មានតែក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់តែប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងអង្គប្រជុំ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួនឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសរើសយកន្លែងណាមួយក្នុងឃុំសង្កាត់របស់ខ្លួនដើម្បីប្រជុំ។[27]

#### ១.៤.៤.២.ការត្រៀមរៀបចំកិច្ចប្រជុំ

**លិខិតអញ្ជើញ៖** មេឃុំ ចៅសង្កាត់ត្រូវតែធានាថាលិខិតអញ្ជើញត្រូវបានរៀបចំ និងផ្ញើជូនដល់អ្នកដែលត្រូវចូលរួមប្រជុំគ្រប់គ្នាទាំងអស់មុនពេលប្រជុំ។ នៅក្នុងលិខិតអញ្ជើញត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីពេលវេលា ទីកន្លែង និងបញ្ហាសំខាន់ៗដែលត្រូវពិភាក្សា ឬជម្រាបនៅពេលប្រជុំ។

**ការបង្កើតរបៀបវារៈប្រជុំ៖** គ្រប់ការប្រជុំទាំងអស់ត្រូវតែមានរបៀបវារៈ។ ហើយត្រូវផ្ញើជូនដល់អ្នកចូលរួម

---

[25] មាត្រា៩ នៃអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ ស្ដីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

[26] មាត្រា៩ នៃអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ ស្ដីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

[27] មាត្រា២១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១

ជាមុន។ ជាការប្រសើរអ្នកចូលរួមមានឱកាសចូលរួមក្នុងការរៀបចំរបៀបវារៈ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងមួយភាគបីអាចបន្ថែម ប្រធានបទផ្សេងទៀតដែលស្ថិតនៅក្នុងចំណោមអំណាច និងមុខងាររបស់ខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**ការផ្សព្វផ្សាយអំពីកិច្ចប្រជុំដល់សាធារណជន៖** កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំត្រូវផ្សព្វផ្សាយជាសាធារណៈ ដោយបិទផ្សាយជាសាធារណៈនៅលើក្ដារខៀនព័ត៌មានឃុំ សង្កាត់ និងនៅកន្លែងសាធារណៈក្នុងភូមិទាំងអស់។

### ១.៤.៤.៣. ការប្រព្រឹត្តទៅនៃកិច្ចប្រជុំ

**សមាជិករបស់អង្គប្រជុំ:** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សា និងអាចអនុវត្តបានលុះត្រាតែមានការអនុញ្ញាតជាមុន។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិបញ្ចេញមតិ និងនិយាយដោយគ្មានការភ័យខ្លាចការរំខានឬការបំភិតបំភ័យឡើយ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ស្ដីទីត្រូវដឹកនាំរាល់កិច្ចប្រជុំ។ ស្មៀនឃុំ សង្កាត់ និងបុគ្គលិកដទៃទៀតរបស់ឃុំ សង្កាត់មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សានេះ។[28] ប្រជាពលរដ្ឋមានសិទ្ធិចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់លើកលែងតែកិច្ចប្រជុំដែលធ្វើជាសម្ងាត់។

ស្មៀនឃុំ សង្កាត់ និងប្រជាពលរដ្ឋមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការសម្រេចចិត្ត និងការបោះឆ្នោតក្នុងអង្គប្រជុំឡើយ។[29]

| ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមយ៉ាងតិច |
|---|---|
| ៥ រូប | ៣ រូប |
| ៧ រូប | ៤ រូប |
| ៩ រូប | ៥ រូប |
| ១១ រូប | ៦ រូប |

**កូរ៉ុមនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់៖** កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ប្រព្រឹត្តទៅបានលុះត្រាណាតែមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់លើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួមក្នុងកិច្ចប្រជុំនោះ។[30]

[28] មាត្រា១៥ នៃប្រកាសលេខ ១៣២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្ដីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់

[29] មាត្រា៣០ នៃអនុក្រឹត្យស្ដីពីការផ្ទេរមុខងារការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់,ឆ្នាំ២០០២

[30] មាត្រា២២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១

**សកម្មភាពសំខាន់នៅក្នុងកិច្ចប្រជុំ៖** កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយដូចខាងក្រោម៖

- បញ្ជាក់អះអាងថាជាកិច្ចប្រជុំប្រព្រឹត្តទៅដោយស្របច្បាប់
- ពិនិត្យ និងអនុម័តរបៀបវារៈនៃកិច្ចប្រជុំ
- ពិនិត្យ និងអនុម័តកំណត់ហេតុនៅក្នុងកិច្ចប្រជុំលើកមុន ប្រធានក្រុមប្រឹក្សាត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ
- ពិភាក្សាតាមរបៀបវារៈនីមួយៗ ដូចជាពិនិត្យឯកសារ និងលិខិតផ្សេងៗដែលបានដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេច
- ព្រមទាំងបញ្ហាផ្សេងៗ។

**ការដឹកនាំកិច្ចប្រជុំ៖** ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថាកិច្ចប្រជុំត្រូវប្រព្រឹត្តទៅមានលក្ខណៈប្រជាធិបតេយ្យមានសណ្តាប់ធ្នាប់ល្អ និងគ្មានការរំខាន។

អ្នកដឹកនាំកិច្ចប្រជុំល្អត្រូវបំពេញកិច្ចការមួយចំនួនដូចខាងក្រោម៖

- ធានាថាអ្នកចូលរួមគ្រប់រូបមានសិទ្ធិបញ្ចេញមតិ ហើយមតិរបស់ពួកគេត្រូវបានគេពិចារណា
- ធានាថាស្ត្រី និងបុរសមានឱកាសស្មើគ្នាក្នុងការបញ្ចេញមតិ
- សម្របសម្រួលការពិភាក្សាដោយលើកបញ្ហានៅក្នុងរបៀបវារៈមកពិនិត្យម្តងមួយ ហើយពិភាក្សាបញ្ហានោះយ៉ាងល្អិតល្អន់
- បោះឆ្នោតលើបញ្ហាណាដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មិនឯកភាពគ្នា
- ប្រើប្រាស់ពេលវេលាដែលមានឱ្យបានល្អ ដើម្បីកុំឱ្យកិច្ចប្រជុំចំណាយពេលវេលាច្រើនជាងការចាំបាច់
- ធានាថាប្រជាពលរដ្ឋដែលបានអញ្ជើញមកចូលរួមនៅក្នុងការពិភាក្សាលើបញ្ហាជាក់លាក់មួយ និងមានឱកាសសួរសំណួរ។

**ការធ្វើសេចក្តីសម្រេចចិត្ត៖** សមាជិកក្រុមប្រឹក្សាគ្រប់រូប មានសិទ្ធិបោះឆ្នោតនៅក្នុងគ្រប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់។ ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ។ សំឡេងគាំទ្រ និងសំឡេងមិនគាំទ្រត្រូវប្រកាសឱ្យដឹងភ្លាមហើយកត់ត្រាទុកនៅក្នុងកំណត់ហេតុប្រជុំ។ ស្មៀនឃុំ សង្កាត់ និងបុគ្គលិកផ្សេងទៀត ដែលចូលរួមប្រជុំមិនអាចបោះឆ្នោតបានទេ។

សេចក្តីសម្រេចនៃអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ អាចចាត់ទុកជាបានការលុះត្រាសេចក្តីសម្រេចនោះ ត្រូវបានអនុម័តដោយសំឡេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល។ ចំពោះសេចក្តីសម្រេចលើកិច្ចការផ្សេងពីនេះអាចចាត់ទុកជាបានការ លុះត្រាតែមានសំឡេងគាំទ្រភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាដែលមានវត្តមាន។

### ១.៤.៤.៤. កិច្ចការក្រោយពេលប្រជុំ

**កំណត់ហេតុប្រជុំ៖** ស្មៀនឃុំ សង្កាត់ជាអ្នកទទួលខុសត្រូវលើការសរសេរកំណត់ហេតុអង្គប្រជុំដោយពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់រូបនឹងត្រូវទទួលបានកំណត់ហេតុដែលបានចុះហត្ថលេខាដោយប្រធានអង្គប្រជុំចំនួន១ច្បាប់ម្នាក់សម្រាប់កិច្ចប្រជុំលើកក្រោយៗទៀត កំណត់ហេតុអង្គប្រជុំត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា កាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ សមាសភាពអ្នកចូលរួម របៀបវារៈនៃអង្គប្រជុំ សេចក្តីសម្រេច ព្រមទាំងបញ្ហានានាដែលបានលើកឡើងនៅក្នុងអង្គប្រជុំ និងពេលវេលាបិទអង្គប្រជុំ។

**ការផ្សព្វផ្សាយពីលទ្ធផលនៃកិច្ចប្រជុំដល់សាធារណជន៖** សាធារណជនត្រូវទទួលបានព័ត៌មានស្តីពីសេចក្តីសម្រេចទាំងអស់ដែលក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេច។ រាល់សេចក្តីសម្រេចទាំងអស់នោះត្រូវបិទផ្សាយនៅលើក្តារខៀនព័ត៌មានឃុំ សង្កាត់មិនឱ្យលើសពី៤៨ម៉ោង បន្ទាប់ពីកិច្ចប្រជុំ។ ស្មៀនឃុំ សង្កាត់ត្រូវរៀបចំសង្ខេបលទ្ធផលនៃកិច្ចប្រជុំសម្រាប់ផ្សព្វផ្សាយដល់សាធារណជន ហើយដាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេច។

**ការអនុវត្តសេចក្តីសម្រេចរបស់អង្គប្រជុំ៖** សេចក្តីសម្រេចតបអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តនៅក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនបន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម។

## ១.៥. តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[31]

ផ្អែកតាមបទបញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឱ្យនូវតួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

### ១.៥.១. អំណាចរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

- **អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់** ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទីមុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់

[31] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១

ដែនដីរបស់ខ្លួនប៉ុណ្ណោះ។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ក្នុងស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ។ បើដីកាណាមួយ ដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹងត្រូវបានចាត់ទុកជាមោឃៈដាច់ខាត។

- **អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់** មានន័យថារដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិអនុវត្តសេចក្ដីសម្រេចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ អំណាច ប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឱ្យទៅមេឃុំ ចៅសង្កាត់ ជាអ្នកអនុវត្តក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

### ១.៥.២. តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទី២ប្រភេទគឺៈ តួនាទីបម្រើកិច្ចការមូលដ្ឋាន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ។[32]

➢ **ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន** រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចៈ

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនជាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

➢ **ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋៈ** រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្ត។ ឧទាហរណ៍ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាដើម។

### ១.៥.៣. ព្រំដែននៃអំណាច

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ។ នេះមានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទបញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

---

[32] មាត្រា៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យដូចជា ព្រៃឈើ ប្រៃសណីយ៍និងទូរគមនាគមន៍ ការពារជាតិ សន្តិសុខជាតិ រូបិយវត្ថុ នយោបាយក្រៅប្រទេស គោលនយោបាយសារពើពន្ធ និងវិស័យផ្សេងៗទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។[33]

## ១.៦. ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

### ១.៦.១. អត្ថន័យនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

#### ១.៦.១.១. ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់មានរយៈពេលប្រាំឆ្នាំ ដូចអាណត្តិក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលឃុំ សង្កាត់ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការ និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព។

#### ១.៦.១.២. កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គឺជាការធ្វើឱ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទៅជាគម្រោងសកម្មភាព ឬសេវាកម្មជាក់ស្តែង ដោយមានភ្ជាប់នូវចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍសម្រាប់រយៈពេលបីឆ្នាំ។ កម្មវិធីវិនិយោគនេះត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

### ១.៦.២. គោលការណ៍សំខាន់ៗនៃការកសាងផែនការឃុំ សង្កាត់

ការកសាងផែនការឃុំ សង្កាត់ត្រូវផ្អែកតាមគោលការណ៍សំខាន់ៗ ដូចខាងក្រោម ៖

- **ការចែករំលែកព័ត៌មាន៖** ក្នុងដំណើរការកសាងផែនការត្រូវមានការចែករំលែកព័ត៌មានរវាងរដ្ឋបាលថ្នាក់ផ្សេងៗគ្នារវាងប្រជាពលរដ្ឋ រវាងការិយាល័យ អង្គភាព អង្គការជាតិ អន្តរជាតិ និងដៃគូនានា ព្រមទាំងវិស័យឯកជនដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- **តម្លាភាព៖** ការកសាងផែនការត្រូវធ្វើឡើងស្របតាមបែបបទ នីតិវិធី គោលការណ៍ណែនាំ មិនមានការលាក់លៀមគ្រប់អ្នកពាក់ព័ន្ធបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានា ហើយព័ត៌មានជុំវិញការធ្វើសេចក្តីសម្រេចចិត្តនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។
- **សង្គតិភាព និងសុខដុមនីយកម្ម៖** ផែនការត្រូវរៀបចំឡើងមានលំដាប់លំដោយត្រឹមត្រូវ ស៊ីសង្វាក់ និងមានលក្ខណៈសមស្របសម្រាប់គ្រប់អ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សាឃុំ សង្កាត់។ ផែនការឃុំ សង្កាត់ត្រូវស្របទៅនឹងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងផែនការអភិវឌ្ឍន៍ក្រុង ស្រុក។

---

[33] មាត្រា៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- **ការចូលរួមពិគ្រោះយោបល់ជាទូទៅ៖** ក្នុងដំណើរការកសាងផែនការ ត្រូវមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- **ការឆ្លើយតបនឹងតម្រូវការ៖** ផែនការឃុំ សង្កាត់ ពិសេសចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ឬគម្រោងវិនិយោគ ត្រូវតែឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ៖** ក្នុងដំណើរការកសាង និងអនុវត្តផែនការត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សា ដោយក្រុមប្រឹក្សា និងគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ (គ.ផ.ថ) ត្រូវធ្វើសេចក្តីសម្រេចអំពីការអភិវឌ្ឍមូលដ្ឋានដោយឈរលើតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងត្រូវផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីហេតុផលនៃការធ្វើសេចក្តីសម្រេចរបស់ខ្លួនចំពោះការអភិវឌ្ឍមូលដ្ឋានទាំងនោះ ព្រមទាំងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋអំពីការសម្រេចរបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីការសម្រេចទាំងនេះ។
- **ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម៖** ក្នុងដំណើរការកសាង និងអនុវត្តផែនការត្រូវធានានូវប្រសិទ្ធភាព និងត្រូវចូលរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ដើម្បីធានាឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវកំណត់ឱ្យបាននូវតម្រូវការដែលមានអាទិភាពខ្ពស់បំផុត និងត្រូវសម្រេចប្រើប្រាស់ធនធានសម្រាប់ឆ្លើយតបចំពោះតម្រូវការជាអាទិភាពទាំងនេះ ប្រកបដោយការសន្សំសំចៃខ្ពស់ ដោយត្រូវធ្វើយ៉ាងណាឱ្យការចំណាយតិចបំផុត និងទទួលផលបានច្រើនបំផុតតាមដែលអាចធ្វើបាន។
- **ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន៖** ក្នុងដំណើរការកសាង និងអនុវត្តផែនការឃុំ សង្កាត់ត្រូវចូលរួមចំណែកក្នុងការការពារធនធានធម្មជាតិ និងបរិស្ថាន សំដៅធានាបាននូវនិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន ពោលគឺមិនបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានក្នុងឃុំ សង្កាត់ឡើយ។
- **ការធានាសមធម៌៖** ក្នុងដំណើរការកសាង និងអនុវត្តផែនការឃុំ សង្កាត់ត្រូវធានាឱ្យមានការចូលរួម និងផ្តល់ផលប្រយោជន៍ដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសស្ត្រី កុមារ ជនក្រីក្រ ជនពិការ ក្រុមជនភាគតិច និងជនងាយរងគ្រោះដែលមាននៅក្នុងឃុំ សង្កាត់។

### ១.៦.៣. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

យន្តការដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់គឺ៖

#### ១.៦.៣.១. ក្រុមប្រឹក្សាឃុំ សង្កាត់

- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដោយធានាឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋពិសេសស្ត្រី កុមារ ជនពិការ យុវជន និងជនងាយរងគ្រោះជាដើម។

- ពិនិត្យ និងអនុម័តរាល់ការធ្វើវិសោធនកម្មផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការសម្រេចបាននូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**១.៦.៣.២. មេឃុំ ចៅសង្កាត់**

- ដឹកនាំការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់
- ដឹកនាំការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត។

**១.៦.៣.៣. គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់(គ.ផ.ថ)**

- ជួយមេឃុំ ចៅសង្កាត់ ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដោយអនុវត្តតាមបែបបទនីតិវិធីដូចមានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ និងសង្កាត់។

យន្តការទាំងបីខាងលើ គឺជាយន្តការស្នូលក្នុងការចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ដើម្បីធានាឱ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់មានគុណភាព ចាំបាច់ត្រូវមានយន្តការគាំទ្រដែលរួមមាន ៖

**ក. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក)**

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការប្រមូលវិភាគព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងបញ្ហា តម្រូវការរបស់នារី និងកុមារ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ទាក់ទាញការគាំទ្រ ដើម្បីឱ្យអ្នកពាក់ព័ន្ធនានាពិសេសស្ត្រី ជនពិការ យុវវ័យ និងជនងាយរងគ្រោះនានាបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការអភិវឌ្ឍមូលដ្ឋាន
- ចូលរួមផ្តល់ព័ត៌មាន និងជំរុញឱ្យមានការយកចិត្តទុកដាក់លើបញ្ហាស្ត្រី កុមារ និងជនងាយរងគ្រោះនានាដែលមានក្នុងដែនសមត្ថកិច្ចខ្លួននៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- សហការបំពេញការងារតាមសំណូមពរពី គ.ផ.ថ ដើម្បីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

### ខ. មន្ទីរផែនការរាជធានី ខេត្ត

- គាំទ្របច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដូចជាការងារស្រង់ទិន្នន័យពីមូលដ្ឋានភូមិ ឃុំ សង្កាត់ ការងារចងក្រងកម្រងព័ត៌មានស្ថានភាពឃុំ សង្កាត់ប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងព័ត៌មានផ្សេងៗទៀត។
- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត និងទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេសតាមដាន និងវាយតម្លៃលទ្ធផលអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- សហការផ្តល់ការគាំទ្របច្ចេកទេសអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងបុគ្គលិកសំខាន់ៗរបស់ឃុំ សង្កាត់តាមសំណើពីអ្នកពាក់ព័ន្ធ។

### គ. ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត

- ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដោយមានកិច្ចសហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត មន្ទីរផែនការរាជធានី ខេត្ត និង/ឬអង្គភាពជំនាញក្នុងករណីចាំបាច់
- ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ទុកជាឯកសារ
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

### ឃ. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ឬការិយាល័យផែនការ និងអភិវឌ្ឍន៍

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការវិភាគ វាយតម្លៃ និងរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ជួយទីចាត់ការផែនការ និងវិនិយោរាជធានី ខេត្ត ដើម្បីពិនិត្យ និងលើកយោបល់ជូនអភិបាលរាជធានី ខេត្ត អំពីការធ្វើអនុលោមភាពផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ជួយអភិបាលក្រុង (សង្កាត់ក្នុងក្រុង) អំពីការធ្វើអនុលោមភាពផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

- សម្របសម្រួល និងប្រមូលឯកសារ ដើម្បីបញ្ជូនទៅអង្គភាពពាក់ព័ន្ធ
- សិក្សា វាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងតម្រូវការគាំទ្រនានា
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់
- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ខ. ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ**

- ជួយសម្របសម្រួល និងជំរុញអាជ្ញាធរភូមិ ឃុំ សង្កាត់ ក្នុងការស្រង់ទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់
- ជួយ គ.ផ.ថ ក្នុងការវិភាគព័ត៌មានស្ថានភាព និងពិន្ទុវិស័យទិន្នន័យភូមិ ឃុំ សង្កាត់។

**ច. មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានាថ្នាក់រាជធានី ខេត្ត**

- ទទួលខុសត្រូវផ្តល់ជំនួយបច្ចេកទេសដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួនដល់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដូចជាយេនឌ័រ ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះដែលសល់ពីសង្គ្រាម ពិការភាព។ល។

**ឆ. អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា**

- ចូលរួមជាតំណាងឱ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ដូចជាតំណាងឱ្យស្ត្រី កុមារ យុវជន ជនក្រីក្រ ជនជាតិដើមភាគតិច។ល។
- ចូលរួមផ្តល់ចំណេះដឹង និងគំនិតផ្សេងៗក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ រួមទាំងចូលរួមក្នុងការពិភាក្សា និងពិគ្រោះឃុំ សង្កាត់។

**ជ. ប្រជាពលរដ្ឋ**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ត្រូវចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីកំណត់យោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល បញ្ហា និងតម្រូវការអាទិភាពនានាក្នុងសហគមន៍ និងមូលដ្ឋានខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់សាមីខ្លួននីមួយៗ។

# ជំពូកទី២
# ដំណើរការគ្រប់គ្រងរដ្ឋបាល
# ឃុំតាំងយ៉ាប

# ជំពូកទី២
# ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំ តាំងយ៉ាប

## ២.១. ស្ថានភាពទូទៅ

### ២.១.១. ស្ថានភាពភូមិសាស្ត្រ

ឃុំតាំងយ៉ាប ជាឃុំមួយក្នុងចំណោមឃុំទាំង១៣ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលស្ថិតនៅប៉ែកខាងលិចឈៀងខាងជើងទីរួមស្រុកចម្ងាយ១៣គីឡូម៉ែត្រ និងស្ថិតនៅទិសឧត្តរនៃទីរួមខេត្តមានចម្ងាយ៣៥គីឡូម៉ែត្រ មានផ្ទៃដីសរុបចំនួន ១៦,០១គីឡូម៉ែត្រការ៉េ ក្នុងនោះដីលំនៅដ្ឋានមានចំនួន ១៨១,៩៦ហិកតា ដីគមនាគមន៍មានចំនួន ១៩,៣៧ហិកតា ដីវស្សាមានចំនួន ៨៩៨ហិកតា ដីប្រាំងមានចំនួន ៣៩,៨៥ហិកតា ដីដំណាំ១៣,៧៦ហិកតា បឹង ព្រៃក និងដីធារាសាស្ត្រ ៤៣៥,៧៦ហិកតា វត្ត សាលារៀន និងស្ថាប័នផ្សេងៗ១២,៣៥ហិកតា។[34]

ឃុំតាំងយ៉ាបមានភូមិទាំងអស់ចំនួន១២ភូមិដែលមានដូចជា ភូមិត្រពាំងទា ភូមិព្រៃចំបក់ ភូមិត្រពាំងស្តុក ភូមិស្នួលខ្ពស់ ភូមិក្រាំងអំពិល ភូមិក្រាំងចំរើន ភូមិជំរៅ ភូមិកែវចំរើន ភូមិសំបូរ ភូមិអង់រវាយ ភូមិច្រនៀងខ្ពស់ និងភូមិល្វេស។ ឃុំតាំងយ៉ាបមានព្រំប្រទល់៖

- ខាងលិច ទល់នឹងឃុំស្លា និងឃុំរវៀង ស្រុកសំរោង
- ខាងកើត ទល់នឹងឃុំក្តាញ់
- ខាងជើង ទល់នឹងឃុំត្នោត ស្រុកបាទី
- ខាងត្បូង ទល់នឹងឃុំព្រៃផ្តៅ។[35]

### ២.១.២. ស្ថានភាពប្រជាសាស្ត្រ

ឃុំតាំងយ៉ាបមានប្រជាជនសរុបចំនួន ៩ ៥២៤នាក់ និងមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ២ ៣១៣គ្រួសារ ដែលក្នុងនោះស្រីមានចំនួន ៤ ៩១៤នាក់ និងប្រុសមានចំនួន ៤ ៦១០នាក់ ។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១ឆ្នាំដល់១៧ឆ្នាំមានចំនួន២៣% ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំដល់៦០ឆ្នាំមានចំនួន៦០% ប្រជាពលរដ្ឋដែលមានអាយុចាប់ពី៦១ឆ្នាំឡើងទៅមានចំនួន១៧% មេគ្រួសារជាស្ត្រីមានចំនួន២០% កំណើនប្រជាពលរដ្ឋប្រចាំឆ្នាំ ២,៧៥% អត្រាភាពក្រីក្រ ០,៧៩%។[36]

ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមានចំនួន ៦ ៦៥៧នាក់ ក្នុងនោះស្រីមានចំនួន ៣ ០២៣នាក់ និងប្រុសមានចំនួន ៣ ៦៣៤នាក់។ ការប្រកបរបរសម្រាប់ចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុង

[34] ស្ថិតិផ្ទៃដីក្នុងឃុំតាំងយ៉ាប ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៤

[35] ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០២៣-២០២៧)ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

[36] តារាងសង្ខេបទិន្នន័យចម្បងរបស់ឃុំតាំងយ៉ាប គិតត្រឹមថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

ឃុំតាំងយ៉ាបភាគច្រើនគឺការធ្វើកសិកម្មដាំដុះស្រូវនៅរដូវវស្សាដែលក្នុងនោះបើយើងគិតជាតួរលេខគឺមុខរបរកសិកម្មជាចម្បងមានចំនួន៩០% បន្ថែមលើការងារធ្វើស្រែវស្សា ប្រជាពលរដ្ឋភាគច្រើនមានការប្រកបរបរសិប្បកម្មជាចម្បងមួយទៀតផងដែរគឺការតម្បាញហូលដែលគិតជាតួរលេខមានចំនួន៩០%ចំណែកប្រជាពលរដ្ឋដែលប្រកបរបរផ្នែកសេវាកម្មចម្បងមានចំនួន១០%។[37] ទាំងនេះគឺជាការបរិយាយអំពីសមិទ្ធផលការងារប្រចាំឆ្នាំទី២នៃអាណត្តិទី៥របស់ក្រុមប្រឹក្សាឃុំ ដើម្បីឆ្លើយតបនូវគោលដៅអភិវឌ្ឍរយៈពេល៥ឆ្នាំ (២០២២-២០២៧)តាមរយៈការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំ។

## ២.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំតាំងយ៉ាប

### ២.២.១. សមាសភាពក្រុមប្រឹក្សាឃុំ

យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៣៨៦០ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រុមប្រឹក្សាឃុំតាំងយ៉ាបនៅក្នុងអាណត្តិទី៥ មានសមាជិកចំនួន ០៧រូប ក្នុងនោះមានស្ត្រី ០១រូប ដូចមានរាយនាមខាងក្រោម៖

១. លោក ស៊ឺ វុទ្ធី ជាប្រធានក្រុមប្រឹក្សាឃុំ
២. លោក ងន សេងអាយ ជាសមាជិកក្រុមប្រឹក្សាឃុំ
៣. លោក មៀច ស្រ៊ាន ជាសមាជិកក្រុមប្រឹក្សាឃុំ
៤. លោក សុខ ញ៉ ជាសមាជិកក្រុមប្រឹក្សាឃុំ
៥. លោក សុខ គីឡុង ជាសមាជិកក្រុមប្រឹក្សាឃុំ
៦. កញ្ញា ម៉ែន សុធា ជាសមាជិកក្រុមប្រឹក្សាឃុំ
៧. លោក ឈិត ណាត ជាសមាជិកក្រុមប្រឹក្សាឃុំ

យោងតាមប្រកាសដែលទទួលស្គាល់សមាសភាពជាមេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម៖

១. លោក ស៊ឺ វុទ្ធី ជាមេឃុំ
២. លោក ងន សេងអាយ ជាជំទប់ទី១
៣. លោក មៀច ស្រ៊ាន ជាជំទប់ទី២ ។[38]

[37] តារាងសង្ខេបទិន្នន័យចម្បងរបស់ឃុំតាំងយ៉ាប គិតត្រឹមថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

[38] ប្រកាសក្រសួងមហាផ្ទៃលេខ៣៨៦០ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

## ២.២.២. គណៈកម្មការនានារបស់ឃុំ

### ២.២.២.១. គណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំតាំងយ៉ាប

គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំតាំងយ៉ាប មានសមាសភាពចំនួន ២១រូប រួមទាំងមេភូមិ ១២រូប ដឹកនាំដោយប្រធានមួយរូបជាមេឃុំ និងមានសមាជិកចំនួន ២០រូបទៀតដែលមានរាយនាមដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក ស៊ី វុទ្ធី | មេឃុំ | ប្រធាន |
| ២. លោក ងន សេងអាយ | ជំទប់ទី១ | សមាជិកអចិន្ត្រៃយ៍ |
| ៣. លោក មៀច ស្រ៊ាន | ជំទប់ទី២ | សមាជិក |
| ៤. លោក សុខ គីឡុង | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក |
| ៥. លោក ឈិត ណាត | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក |
| ៦. កញ្ញា ម៉ែន សុធា | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក |
| ៧. លោក ហាក់ ស្រៀង | ចាស់ព្រឹទ្ធាចារ្យ | សមាជិក |
| ៨. លោក ទូច ស្រ៊ុម | ចាស់ព្រឹទ្ធាចារ្យ | សមាជិក |
| ៩. លោក ទូច សំអ៊ុន | ស្មៀនឃុំ | លេខាកត់ត្រា |
| ១០. លោក ម៉ឹង ជ្រុន | ប្រធានភូមិត្រពាំងទា | សមាជិក |
| ១១. លោក ទេព សំអាន | ប្រធានភូមិសំបួរ | សមាជិក |
| ១២. លោក ឌៀប រិន | ប្រធានភូមិព្រៃចំបក់ | សមាជិក |
| ១៣.លោក គង់ សាវុធ | ប្រធានភូមិត្រពាំងស្គុក | សមាជិក |
| ១៤. លោក បេន រិន | ប្រធានភូមិស្នួលខ្ពស់ | សមាជិក |
| ១៥. លោក សុខ រ៉ុង | ប្រធានភូមិក្រាំងអំពិល | សមាជិក |
| ១៦. លោកស្រី សែម អាន | ប្រធានភូមិក្រាំងចំរើន | សមាជិក |
| ១៧. លោក កាន់ ហ៊ី | ប្រធានភូមិជំផៅ | សមាជិក |
| ១៨. លោក ម៉ុក សុខ | ប្រធានភូមិកែវចំរើន | សមាជិក |
| ១៩. លោក មុំ រ៉េត | ប្រធានភូមិអង់រវាយ | សមាជិក |
| ២០. ឧបាសក ហ៊ីង ង៉ែត | ប្រធានភូមិច្រនៀងខ្ពស់ | សមាជិក |
| ២១. ឧបាសក ថៅ ហុងលី | ប្រធានភូមិរលួស | សមាជិក |

គណៈកម្មាធិការកសាងផែនការ និងថវិកា មានតួនាទីភារកិច្ចជួយមេឃុំ៖

- ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំឱ្យស្របតាមខ្លឹមសារស្មារតីប្រកាសរបស់អន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការ លេខ២៤២៣ប្រ.កចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។
- ពិនិត្យ និងពិភាក្សារៀបចំកសាងផែនការថវិកាឃុំ ឱ្យស្របតាមខ្លឹមសារស្មារតីអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលស្ដីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលបានកំណត់។[39]

**២.២.២.២. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំតាំងយ៉ាប**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារមានសមាសភាពចំនួន១៩រូប ដឹកនាំដោយប្រធាន១រូបជាមេឃុំ និងមានសមាសភាពចំនួន ១រូបទៀតជាអនុប្រធាន និងជាសមាជិកដែលមានរាយនាមដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក ស៊ី វុទ្ធី | មេឃុំ | ជាប្រធាន |
| ២. លោក មៀច ស្រ៊ាន | ជំទប់ទី២ | ជាអនុប្រធាន |
| ៣. កញ្ញា ម៉ែន សុធា | ទទួលបន្ទុកកិច្ចការនារី និងកុមារ | សមាជិកអចិន្ត្រៃយ៍ |
| ៤. លោក ទូច សំអ៊ីន | ស្មៀនឃុំ | សមាជិក |
| ៥. លោក ស៊ុន សារ៉ាក់ | នាយប៉ុស្ដិ៍នគរបាល | សមាជិក |
| ៦. លោក ណៃ ធី | នាយកសាលាបឋមសិក្សាភ្នំចចក | សមាជិក |
| ៧. លោក សន សំបូរ | ប្រធានមណ្ឌលសុខភាពឃុំតាំងយ៉ាប | សមាជិក |
| ៨. លោក ម៉ឹង ជ្រុន | ប្រធានភូមិត្រពាំងទា | សមាជិក |
| ៩. លោក ឡៀប រិន | ប្រធានភូមិព្រៃចំបក់ | សមាជិក |
| ១០. លោក គង់ សារុធ | ប្រធានភូមិត្រពាំងស្លុក | សមាជិក |
| ១១. លោក បេន រិន | ប្រធានភូមិស្នួលខ្ពស់ | សមាជិក |
| ១២. លោក សុខ រ៉ុង | ប្រធានភូមិក្រាំងអំពិល | សមាជិក |
| ១៣. លោកស្រី សែម អាន | ប្រធានភូមិក្រាំងចំរើន | សមាជិក |
| ១៤. លោក កាន់ ហ៊ី | ប្រធានភូមិជំរៅ | សមាជិក |
| ១៥. លោក ម៉ុក សុខ | ប្រធានភូមិកែវចំរើន | សមាជិក |

[39] សេចក្ដីសម្រេចលេខ០២/២៣សសរ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំតាំងយ៉ាប

| | | |
|---|---|---|
| ១៦. លោក ទេព សំអាន | ប្រធានភូមិសំបូរ | សមាជិក |
| ១៧. លោក មុំ ផេត | ប្រធានភូមិអង់រវាយ | សមាជិក |
| ១៨. លោក ហ៊ីង ង៉េត | ប្រធានភូមិច្រនៀងខ្ពស់ | សមាជិក |
| ១៩. លោក ថៅ ហុងលី | ប្រធានភូមិរលួស | សមាជិក |

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានភារកិច្ចដូចខាងក្រោម ៖

- ទទួលខុសត្រូវក្នុងកិច្ចការនារី និងកុមារ ត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមរាល់កិច្ចការពិភាក្សា ឬប្រជុំគណៈកម្មការនានា និងប្រជុំរបស់ក្រុមប្រឹក្សា
- ជាជំនួយការឱ្យក្រុមប្រឹក្សា លើកិច្ចការនារី និងកុមារក្នុងឃុំ
- ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធស្តីពីលទ្ធផលការងារប្រចាំខែដែលអនុវត្តបាន។[40]

**២.២.២.៣. គណៈកម្មការលទ្ធកម្ម**

គណៈកម្មការលទ្ធកម្មឃុំតាំងយ៉ាប មានសមាសភាពចំនួន ៥រូប ដឹកនាំដោយប្រធាន ១រូបជាមេឃុំ និងមានសមាភាពចំនួន ៤រូប ទៀតដែលមានរាយនាមដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក ស៊ី វុទ្ធី | មេឃុំ | ជាប្រធាន |
| ២. លោក ងន សេងអាយ | ក្រុមប្រឹក្សាឃុំ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៣. លោក សុខ គីឡុង | ក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៤. លោក ឈិត ណាត | ក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥. លោក ទូច សំអ៊ីន | ស្មៀនឃុំ | ជាលេខាធិការ |

គណៈកម្មការលទ្ធកម្មឃុំតាំងយ៉ាបមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជួយមេឃុំ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់ឃុំ ត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ
- ត្រូវអនុវត្តវិធីសាស្ត្រកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ តាមអភិក្រមមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ
- ជួយមេឃុំក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់ឃុំ។[41]

[40] សេចក្តីសម្រេចលេខ០០៩/២២ សសរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារឃុំតាំងយ៉ាបសម្រាប់អាណត្តិទី៥

[41] សេចក្តីសម្រេចលេខ០៣/២០២៣ ស.ជ.ណ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មការលទ្ធកម្ម ឃុំតាំងយ៉ាប

**២.២.២.៤. កិច្ចប្រជុំរបស់គណៈកម្មាធិការ**

ជាគោលការណ៍កិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំ ត្រូវអនុវត្តដូចកិច្ចប្រជុំក្រុមប្រឹក្សាឃុំដែរ ប៉ុន្តែមានចំណុចពិសេសមួយចំនួនដូចខាងក្រោម៖

របៀបវារៈសម្រាប់កិច្ចប្រជុំរបស់គណៈកម្មាធិការផ្តល់យោបល់ ត្រូវរៀបចំដោយស្មៀនឃុំដោយមានការពិគ្រោះយោបល់ជាមួយមេឃុំ និងប្រធានគណៈកម្មាធិការ។ ប្រសិនបើសមាជិកគណៈកម្មាធិការច្រើនជាងមួយភាគបីមានបំណងពិភាក្សាលើបញ្ហាដែលស្ថិតនៅក្នុងការងាររបស់គណៈកម្មាធិការ បញ្ហានោះត្រូវដាក់ចូលក្នុងរបៀបវារៈ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការ ត្រូវធ្វើសេចក្តីដោយសេចក្តីព្រមព្រៀងឯកភាពគ្នាតាមរយៈការលើកដៃចំពោះការធ្វើសេចក្តីសម្រេច។ ប្រសិនបើពុំមានការព្រមព្រៀងឯកភាពគ្នាទេ គណៈកម្មាធិការត្រូវធ្វើការបោះឆ្នោត។ គណៈកម្មាធិការត្រូវធ្វើការរាយការណ៍អំពីសេចក្តីសម្រេចរបស់ខ្លួនជូនក្រុមប្រឹក្សា ឬជូនមេឃុំ ដូចដែលបានបញ្ជាក់នៅក្នុងតួនាទី និងភារកិច្ចរបស់ខ្លួន។

**២.២.៣. ហិរញ្ញវត្ថុរបស់ឃុំ**

**២.២.៣.១. ការរៀបចំ និងអនុម័តថវិកាឃុំ**

គម្រោងថវិការបស់ឃុំតាំងយ៉ាប ត្រូវបានរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ និងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ រួចទើបបញ្ជូនទៅក្រុមប្រឹក្សាឃុំដើម្បីធ្វើការពិនិត្យ និងអនុម័ត។ ជាទូទៅក្រុមប្រឹក្សាឃុំត្រូវអនុម័តគម្រោងថវិកានៃកិច្ចប្រជុំសាធារណៈឱ្យបានមុនថ្ងៃ៣១ ខែតុលា។[42]

ជាក់ស្តែងឃុំតាំងយ៉ាប មុននឹងរៀបចំអនុម័តថវិកានេះផងដែរ ឃុំតែងធ្វើការប្រឹក្សាយោបល់ពីប្រជាពលរដ្ឋអំពីតម្រូវការរបស់ពួកគាត់ ថាតើពួកគាត់ចង់បានអ្វីខ្លះដើម្បីងាយស្រួលរៀបចំថវិកាឱ្យបានសមស្របទៅតាមទិសដៅដែលប្រជាពលរដ្ឋនៅក្នុងឃុំចង់បាន។ ហើយជារៀងរាល់ឆ្នាំដំណើរការរៀបចំថវិកាត្រូវបានកំណត់គោលដៅឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដើម្បីជួយផ្តល់មតិយោបល់ព្រមទាំងផ្តិតមេដៃបញ្ជាក់ពីការចូលរួមរបស់ខ្លួន។ ប៉ុន្តែជារឿយៗក្រោយពេលប្រកាសផ្សាយឱ្យមានការចូលរួមប្រជុំពីសំណាក់ប្រជាពលរដ្ឋ ឃើញថាពួកគាត់ហាក់ដូចជាមិនសូវចាប់អារម្មណ៍យកចិត្តទុកដាក់ និងពុំសូវឱ្យតម្លៃពីការចូលរួមរបស់ខ្លួនឡើយដោយហេតុថាប្រជាពលរដ្ឋគាត់ផ្តល់ភាពចាំបាច់ទៅលើការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃជាជាងការចូលរួមប្រជុំនេះ ចំណែកឯអ្នកខ្លះទៀតយល់ថា ការចូលរួមលុះត្រាតែបានអំណោយទើបគាត់រីករាយនឹងអញ្ជើញទៅចូលរួម។

ចំពោះការរៀបចំគម្រោងថវិកាសម្រាប់ឆ្នាំ២០២៤របស់ឃុំតាំងយ៉ាបគឺឃុំបានរៀបចំថវិកាចំនួន ៣៦៥ ៤០៨ ៩៦៣ រៀល[43] សម្រាប់ការធ្វើវិនិយោគនៅក្នុងឃុំ និងសម្រាប់បំពេញនូវតម្រូវការផ្សេងៗទៀតរបស់ប្រជាពលរដ្ឋនៅក្នុង

[42] អនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

[43] អនុស្សរណៈស្តីពីគម្រោងថវិការឃុំតាំងយ៉ាបឆ្នាំ២០២៤ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

មូលដ្ឋាន។ បន្ទាប់ពីការអនុម័តគម្រោងថវិកានៅថ្នាក់ឃុំរួចរាល់ហើយ មេឃុំក៏បញ្ជូនគម្រោងថវិកានោះទៅកាន់អភិបាលនៃគណៈអភិបាលខេត្តតាកែវ។ ក្រោយពេលអភិបាលខេត្តឯកភាពលើគម្រោងថវិកានេះហើយ លោកក៏បញ្ជូនសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកឱ្យមេឃុំវិញ ហើយដើម្បីបញ្ជាក់ពីការទទួលស្គាល់លើគម្រោងថវិកាដែលសេចក្ដីជូនដំណឹងនេះក៏មានចម្លងជូន និងភ្ជាប់ជាមួយគម្រោងថវិកាទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគាខេត្តតាកែវផងដែរ។

### ២.២.៣.២. ចំណូលចំណាយថវិកាក្នុងឃុំ

#### ក. ចំណូល

- ចំណូលចរន្ត = ៩១០ ០៧៥ ៣២៣រៀល (ប្រាំបួនរយដប់លានប្រាំពីរម៉ឺនប្រាំពាន់បីរយម្ភៃបីរៀល)
- ចំណូលមូលធន =៤០៣ ៦៧៥ ៣២៣រៀល (បួនរយបីលានប្រាំមួយសែនប្រាំពីរម៉ឺនប្រាំពាន់បីរយម្ភៃបីរៀល)
- សរុប = ១៣១៣ ៧៥០ ៦៤៦រៀល (មួយពាន់បីរយដប់បីលាន ប្រាំពីរសែនប្រាំម៉ឺនប្រាំមួយរយសែសិបប្រាំមួយរៀល)។[44]

#### ខ. ចំណាយ

- ចំណាយចរន្ត = ៩១០ ០៧៥ ៣២៣រៀល (ប្រាំបួនរយដប់លានប្រាំពីរម៉ឺនប្រាំពាន់បីរយម្ភៃបីរៀល)
- ចំណាយមូលធន = ៣៥៤ ២៤៦ ៤៤០រៀល (បីរយហាសិបបួនលានពីរសែនបួនម៉ឺនប្រាំមួយពាន់បួនរយសែសិបរៀល)
- សរុប =១២៦៤ ៣២១ ៧៦៣រៀល (មួយពាន់ពីររយហុកសិបបួនលានបីសែនពីរម៉ឺនមួយពាន់ប្រាំពីររយហុកសិបបីរៀល)។[45]

#### គ. ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាឃុំ និងមន្ត្រីភូមិ

យោងតាមអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ស្ដីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ដូចតទៅ៖

- ប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំ = ១ ២៤០ ០០០រៀល ក្នុងមួយខែ
- ជំទប់ទី១ = ៩៣០ ០០០រៀល ក្នុងមួយខែ
- ជំទប់ទី២ = ៩៣០ ០០០រៀល ក្នុងមួយខែ

[44] អនុស្សរណៈស្ដីពីគម្រោងថវិការឃុំតាំងយ៉ាបឆ្នាំ២០២៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២

[45] អនុស្សរណៈស្ដីពីគម្រោងថវិការឃុំតាំងយ៉ាបឆ្នាំ២០២៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២

- សមាជិកក្រុមប្រឹក្សាឃុំ = ៨២០ ០០០រៀល ក្នុងមួយខែ
- មេភូមិ = ៥១០ ០០០រៀល ក្នុងមួយខែ
- អនុប្រធានភូមិ = ៣៩០ ០០០រៀល ក្នុងមួយខែ
- សមាជិក = ៣៦០ ០០០រៀល ក្នុងមួយខែ។

ដោយឡែកចាប់ពីខែមេសា ឆ្នាំ២០២៤ របបប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិក្រុមប្រឹក្សាឃុំ និងមន្ត្រីភូមិ ត្រូវអនុវត្តតាមអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ត្រូវបានកំណត់ដូចតទៅ៖

- ប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំ = ១ ៣២០ ០០០រៀល ក្នុងមួយខែ
- ជំទប់ទី១ = ៩៨០ ០០០រៀល ក្នុងមួយខែ
- ជំទប់ទី២ = ៩៨០ ០០០រៀល ក្នុងមួយខែ
- សមាជិកក្រុមប្រឹក្សាឃុំ = ៨៧០ ០០០រៀល ក្នុងមួយខែ
- មេភូមិ = ៥៥០ ០០០រៀល ក្នុងមួយខែ
- អនុប្រធានភូមិ = ៤៣០ ០០០រៀល ក្នុងមួយខែ
- សមាជិកភូមិ = ៤០០ ០០០រៀល ក្នុងមួយខែ។

## ២.៣. ការអភិវឌ្ឍឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

### ២.៣.១. ផែនការអភិវឌ្ឍន៍ឃុំ

ផែនការអភិវឌ្ឍន៍ឃុំ គឺមានអាណត្តិ៥ឆ្នាំ ដូចគ្នាទៅនឹងអាណត្តិរបស់ក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍន៍ឃុំ ដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហាតម្រូវការ និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះសំដៅឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព។

#### ២.៣.១.១. ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ

ក្រុមប្រឹក្សាឃុំ សង្កាត់ជារដ្ឋបាលដែលនៅដាច់ឆ្ងាយពីរដ្ឋបាលកណ្តាល ប៉ុន្តែជារដ្ឋបាលដែលនៅកៀកកិតជាប់ជាមួយនឹងប្រជាពលរដ្ឋជាងរដ្ឋបាលដទៃទៀត ហើយក៏បានដឹងច្បាស់ពីតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក៏ដូចជាស្ថានភាពនៃមូលដ្ឋានរបស់ឃុំ សង្កាត់ផ្ទាល់ផងដែរ។ ដូច្នេះ ការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗត្រូវតែពឹងផ្អែកលើវិធានការ និងការរៀបចំគម្រោងនានារបស់ឃុំ សង្កាត់នីមួយៗស្របតាមលទ្ធភាពផ្ទាល់ខ្លួនរបស់ឃុំ សង្កាត់នោះ។

ការរៀបចំអនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយគោលបំណងនៃការបង្កើតផែនការអភិវឌ្ឍន៍នេះគឺដើម្បីកំណត់នូវទស្សនៈវិស័យកម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។ ថ្វីបើឃុំ សង្កាត់ ត្រូវបានកំណត់ឱ្យរៀបចំនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយខ្លួនឯង និងទៅតាម

លទ្ធភាពនៃឃុំ សង្កាត់រៀងៗខ្លួនក៏ដោយ តែផែនការអភិវឌ្ឍន៍នេះត្រូវស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិផងដែរ។ ផែនការអភិវឌ្ឍន៍គឺពិតជាមានសារៈសំខាន់ណាស់ដែលក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវតែរៀបចំ និងអនុម័តហើយធ្វើការកែសម្រួលនូវទិន្នន័យថ្មីៗដែលមានការប្រែប្រួលជារៀងរាល់ឆ្នាំនៅពេលស្ថិតិក្នុងអាណត្តិឬក្នុងឆ្នាំទី១ នៃអាណត្តិក្រុមប្រឹក្សាដែលទើបនឹងជាប់ឆ្នោត។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់មកជាមួយផង។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រ និងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការនោះ។ ករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមច្បាប់នោះទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងធ្វើការណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតម្រូវឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានច្បាប់ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ២.៣.១.២. វិធីសាស្ត្ររៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំមាន៣ជំហានគឺ៖

ជំហានទី១៖ ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ

ជំហានទី២៖ ការរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ

ជំហានទី៣៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ។

**ជំហានទី១៖ ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ**

- **ប្រជុំនៅឃុំលើកទី១**

គ.ផ.ថ ជួបប្រជុំនៅឃុំដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ ឯកសារព័ត៌មានស្ថានភាពឃុំ និងទិន្នន័យឬព័ត៌មាន ឬប្រើឧបករណ៍វិភាគផ្សេងៗក្នុងការកំណត់អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយនានា ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា។

- **ប្រជុំតាមភូមិនីមួយៗ**
  - តំណាងភូមិដែលជាសមាជិក គ.ផ.ថ ត្រូវស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយទាំងឡាយដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន
  - នៅក្នុងការប្រជុំតាមភូមិនេះ តំណាង គ.ផ.ថ ត្រូវ៖
    - បង្ហាញអំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយដល់ប្រជាពលរដ្ឋដែលបានចូលរួម
    - ពិភាក្សា និងធ្វើសុពលភាពបញ្ហា ទីតាំងនៃបញ្ហា មូលហេតុបញ្ហា តម្រូវការ និងដំណោះស្រាយ

- បែងចែកអ្នកចូលរួមជាក្រុមដើម្បីពិភាក្សា និងកំណត់អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ ឧបសគ្គ និងដំណោះស្រាយបន្ថែម។

➢ **ប្រជុំនៅឃុំលើកទី២**

បន្ទាប់ពីប្រជុំនៅតាមភូមិរួចមក គ.ផ.ថ ជួបប្រជុំនៅឃុំដើម្បីបូកសរុបបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា។ គ.ផ.ថ ស្រង់លទ្ធផលនៃការពិនិត្យ ពិភាក្សាទាំងនេះចូលក្នុងតារាងបូកសរុបបញ្ហា តម្រូវការ និងដំណោះស្រាយរបស់ឃុំ។

**ជំហានទី២៖ ការរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ**

គឺដើម្បីរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ ដែលឆ្លុះបញ្ចាំងពីតម្រូវការអភិវឌ្ឍន៍របស់មូលដ្ឋាន និងស្របតាមគោលនយោបាយជាតិ។ សកម្មភាពសំខាន់ៗមានដូចតទៅ៖

➢ **ការរៀបចំស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ឃុំ៖**

ផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាព គ.ផ.ថ ឃុំត្រូវសរសេរបរិយាយអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ឃុំ ដោយឆ្លុះបញ្ចាំងអំពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ។

➢ **ការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ៖**

ផ្អែកលើការពិភាក្សា និងរៀបចំចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ

បន្ទាប់ពីកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ហើយ គ.ផ.ថ ត្រូវស្រង់ចូលក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំតាមលំដាប់លំដោយ។

➢ **ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ៖**

ដោយផ្អែកតាមតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ មេឃុំ ដោយមានស្មៀន និងសមាជិក គ.ផ.ថ ឃុំ ជាជំនួយការត្រូវរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំដោយកំណត់អំពី ៖

- ក្របខ័ណ្ឌវិនិយោគ
- ក្របខ័ណ្ឌផ្តល់សេវា
- ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា។

➢ **ការពិនិត្យ និងសម្រេចក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន៖**

មេឃុំ ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួននូវសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដើម្បីពិនិត្យ និងសម្រេច។

ប្រធានក្រុមប្រឹក្សាឃុំ កោះប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងសម្រេចក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន។ ឯកសារទាំងនេះគឺជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

- **ការរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ៖**

គ.ជ.ថ ត្រូវរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ ដែលរួមមាន៖

- ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍
- ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន។

ក្រុមប្រឹក្សាឃុំ ទទួលខុសត្រូវតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន៖

- ជាប្រចាំឆ្នាំ តាមរយៈការរៀបចំ និងការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- នៅពាក់កណ្ដាលអាណត្តិរបស់ក្រុមប្រឹក្សា
- នៅក្នុងរយៈពេលប្រាំមួយខែ មុនពេលបញ្ចប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ។

- **ការចងក្រងសេចក្ដីព្រាងសៀវភៅផែនការអភិវឌ្ឍន៍៖**

បន្ទាប់ពីរៀបចំព័ត៌មាន និងតារាងនានាខាងលើហើយ គ.ជ.ថ ឃុំត្រូវរៀបចំចងក្រងសេចក្ដីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ឃុំដោយផ្អែកតាមមាតិកាដែលបានកំណត់។

- **កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ឃុំ៖**

មេឃុំ ត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ដោយ៖

- បង្ហាញក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ស្នើសុំឱ្យអ្នកចូលរួមផ្ដល់យោបល់ទៅលើក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន
- គ.ជ.ថ និងស្មៀនឃុំ បូកសរុបយោបល់ដែលទទួលបានពិនិត្យ ពិចារណា និងកែសម្រួលសេចក្ដីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍមូលដ្ឋាន។

- **ការពិនិត្យ និងផ្ដល់យោបល់៖**

គ.ជ.ថ ដាក់ជូនមេឃុំ នូវសេចក្ដីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍមូលដ្ឋានដែលបានកែសម្រួលទៅតាមយោបល់ដែលទទួលបានពីកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យ និងផ្ដល់យោបល់។

មេឃុំ ពិនិត្យ និងផ្ដល់យោបល់ទៅលើសេចក្ដីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដែលបានកែសម្រួល។

គ.ជ.ថ កែសម្រួលសេចក្ដីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន ទៅតាមមតិយោបល់របស់មេឃុំ ហើយដាក់ជូនក្រុមប្រឹក្សាឃុំពិនិត្យ និងអនុម័ត។

**ជំហានទី៣៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ**

➢ **ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ៖**

**កិច្ចប្រជុំក្រុមប្រឹក្សាឃុំ**

បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ ប្រធានក្រុមប្រឹក្សាឃុំត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ឃុំ។ បន្ទាប់ពីកិច្ចប្រជុំក្រុមប្រឹក្សា មេឃុំត្រូវណែនាំឱ្យ គ.ផ.ថ ពិនិត្យ និងកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ។

**ការពិនិត្យអនុលោមភាព**

មេឃុំត្រូវចាត់ចែងបញ្ជូនសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ឃុំដែលបានកែសម្រួល ទៅអភិបាលខេត្ត ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។

អភិបាលខេត្ត ត្រូវរកជំនួយបច្ចេកទេសពីបណ្តាមន្ទីរ អង្គភាព ឬការិយាល័យពាក់ព័ន្ធនានា ដើម្បីជួយទីចាត់ការផែនការ និងវិនិយោគក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ។ ការពិនិត្យ និងផ្តល់អនុលោមភាពមានរយៈពេល៤៥ថ្ងៃ ដោយគិតពីថ្ងៃដែលបានទទួលការស្នើសុំការពិនិត្យ និងផ្តល់យោបល់ពីមេឃុំ។ ក្នុងរយៈពេល៤៥ថ្ងៃ បើគ្មានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីអភិបាលខេត្ត នោះត្រូវបានចាត់ទុកថាអភិបាលខេត្តបានឯកភាពលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំដែលបានដាក់ស្នើសុំការពិនិត្យ និងផ្តល់អនុលោមភាព។

គ.ផ.ថ និងស្មៀនឃុំពិនិត្យពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំទៅតាមមតិយោបល់របស់អភិបាលខេត្ត។ ក្នុងករណីមានការស្នើកែតម្រូវ មេឃុំត្រូវដាក់ចំណុចដែលបានកែនោះ ជូនក្រុមប្រឹក្សាឃុំពិនិត្យ និងអនុម័តឡើងវិញ។

**សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ឃុំ**

បន្ទាប់ពីទទួលបានការផ្តល់អនុលោមភាព និងការកែសម្រួលតាមមតិយោបល់របស់អភិបាលខេត្ត គ.ផ.ថ ត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ឃុំ។

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ឃុំ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាឃុំ។

➢ **ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍ឃុំ៖**

១. មេឃុំត្រូវរៀបចំបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ឃុំ និងបែងចែក ផ្សព្វផ្សាយជាសាធារណៈ និងតម្កល់ទុកនៅរដ្ឋបាលឃុំ រដ្ឋបាលស្រុក រដ្ឋបាលខេត្ត មន្ទីរផែនការខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

មេឃុំ ត្រូវណែនាំឱ្យមានការផ្សព្វផ្សាយខ្លឹមសារផែនការអភិវឌ្ឍន៍ឃុំឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ និងអ្នកពាក់ព័ន្ធដូចជា ផ្សព្វផ្សាយក្នុងកិច្ចប្រជុំនានាក្នុងវេទិកាសាធារណៈ តាមសារព័ត៌មាន វិទ្យុ និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន។ល។

### ២.៣.១.៣. ការអនុវត្តផែនការអភិវឌ្ឍន៍

ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ ផ្អែកលើការពិនិត្យតម្រូវការជាអាទិភាព មូលដ្ឋានរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំលើគម្រោងរូបវន្ត និងអរូបវន្ត ស្របតាមថវិកាដែលមាន និងគោលនយោបាយរបស់ជាតិក្រោយការអនុលោមភាពពីអភិបាលនៃគណៈអភិបាលខេត្ត។

នៅពេលអនុវត្តគម្រោង ក្រុមប្រឹក្សាឃុំត្រូវធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់ពិសេសអ្នកទទួលផលពីគម្រោងបានចូលរួមយ៉ាងពេញលេញនៅក្នុងការរៀបចំគម្រោង និងការត្រួតពិនិត្យការអនុវត្តគម្រោងដែលមានក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ។ មេឃុំត្រូវធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មដើម្បីអនុវត្តគម្រោងទាំងអស់ និងសកម្មភាពនានាឱ្យស្របទៅតាមនីតិវិធីដែលបានកំណត់។ មុននឹងធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មសម្រាប់អនុវត្តគម្រោងណាមួយ មេឃុំ ត្រូវស្វែងរកការបញ្ជាក់ផ្នែកបច្ចេកទេសពីមន្ទីរជំនាញ ឬអង្គភាពពាក់ព័ន្ធជុំវិញខេត្ត តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។

### ២.៣.១.៤. ការត្រួតពិនិត្យ និងវាយតម្លៃ

ក្រុមប្រឹក្សាឃុំបានយកចិត្តទុកដាក់ទៅលើការអនុវត្តផែនការអភិវឌ្ឍន៍នៃគម្រោងនីមួយៗដោយយកចិត្តទុកដាក់ហើយក៏មានអង្គភាព អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា ជួយគាំទ្រវាល់គម្រោងហើយបានវាយតម្លៃលទ្ធផលគម្រោងដែលអនុវត្តកន្លងមកបានល្អប្រសើរ ឆ្លើយតបទៅនឹងគោលបំណង និងគោលដៅដែលក្រុមប្រឹក្សាចង់បាន។

ក្រុមប្រឹក្សាឃុំតែងតែចុះតាមដាន ត្រួតពិនិត្យរាល់ការអនុវត្តគម្រោងនានា តាំងពីចាប់ផ្ដើមនៃការបើកការដ្ឋានរហូតដល់ការបិទគម្រោង។ ក្រុមប្រឹក្សាឃុំបានប្រជុំវាយតម្លៃទៅលើគម្រោងនានាដែលបានអនុវត្តប្រកបដោយគុណភាពល្អ ឆ្លើយតបទៅនឹងគោលដៅ គោលបំណង និងចក្ខុវិស័យដែលក្រុមប្រឹក្សាអាចយកបាន។

## ២.៣.២. កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ

### ២.៣.២.១. ក្របខ័ណ្ឌវិនិយោគ

ក្របខ័ណ្ឌវិនិយោគ គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីវិនិយោគឃុំតាំងយ៉ាប។ ក្រុមប្រឹក្សាឃុំតាំងយ៉ាបដែលមានគណៈកម្មាធិការកសាងផែនការ និងថវិកាជាជំនួយបានយកចិត្តទុកដាក់គិតគូរ និងរៀបចំអំពីគោលបំណងសំខាន់ៗ ដើម្បីធ្វើការអភិវឌ្ឍមូលដ្ឋាននាពេលខាងមុខ ដោយផ្អែកទៅលើផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(២០២៣-២០២៧)ជាឯកសារគោល និងជាត្រីវិស័យសម្រាប់ឱ្យក្រុមប្រឹក្សាឃុំអនុវត្តតាមរយៈការរៀបចំ និងការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំនីមួយៗរបស់ឃុំ។ នៅពេលពិនិត្យលើបញ្ហា និងតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញការរៀបចំគម្រោងវិនិយោគប្រចាំឆ្នាំរបស់ឃុំ ត្រូវឆ្លងកាត់ការពិភាក្សាគ្នាឱ្យបានល្អិតល្អន់ដើម្បីជ្រើសរើស និងចាត់អាទិភាពគម្រោងសម្រាប់យកទៅអនុវត្តឱ្យចំគោលដៅតាមការជាក់ស្តែងនៅក្នុងមូលដ្ឋានផ្ទាល់ថា តើអ្វីដែលជា

បញ្ហាប្រឈមហើយចាំបាច់ត្រូវធ្វើការដោះស្រាយជាមុនឱ្យស្របទៅនឹងប្រភពធនធានដែលឃុំមាន និងទុនពីខាងក្រៅដែលបានមកពីការជួយឧបត្ថម្ភពីសំណាក់មន្ទីរជំនាញ អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា ជួយគាំទ្រដល់គម្រោងកម្មវិធីវិនិយោគនេះនៅពេលសមាហរណកម្មផែនការឃុំ និងគម្រោងខ្លះទៀតជួយគាំទ្រនៅក្រោយពេលសមាហរណកម្មផែនការផងដែរ។ ជាមួយគ្នានេះដែរ ឃុំត្រូវកោះប្រជុំពេញអង្គក្រុមប្រឹក្សា ដើម្បីសម្រេចជ្រើសរើសគម្រោងដែលនៅសេសសល់គ្មានការសន្យាគាំទ្រ និងសម្រាប់ប្រើប្រាស់មូលនិធិឃុំ ទុនចូលរួមពីប្រជាពលរដ្ឋ និងថវិកាផ្សេងៗទៀតរបស់ឃុំ ដែលទទួលបានពីមជ្ឈដ្ឋានខាងក្រៅ ត្រូវបញ្ចូលក្នុងតារាងថវិកាវិនិយោគតាមប្រភពតារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ។

### ២.៣.២.២. វិធីសាស្ត្ររៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ជា៣ជំហានមានដូចជា៖

ជំហានទី១៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ជំហានទី២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ជំហានទី៣៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ។

**ជំហានទី១៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

➢ **ប្រជុំនៅឃុំលើកទី១**

គ.ផ.ថ ជួបប្រជុំដើម្បីពិនិត្យ និងវិភាគស្ថានភាពទូទៅនៅក្នុងឃុំ។ ក្រៅពី គ.ផ.ថ អ្នកចូលរួមផ្សេងៗទៀតរួមមាន ស្មៀន មេភូមិ ឬតំណាងភូមិ ជនបង្គោល ក្រុមការងារគណនេយ្យភាពសង្គម(បើមាន) ក្រុមយុវជន តំណាងការិយាល័យជំនាញ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានាតាមការស្ម័គ្រចិត្ត។

- គ.ផ.ថ រៀបចំតារាងបញ្ហា តម្រូវការ និងដំណោះស្រាយ។
- មេភូមិនីមួយៗស្រង់យកបញ្ហា តម្រូវការ និងដំណោះស្រាយ ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន។

➢ **ប្រជុំនៅតាមភូមិ**

មេភូមិត្រូវរៀបចំប្រជុំភូមិដើម្បីបង្ហាញ និងពិគ្រោះយោបល់អំពីបញ្ហា តម្រូវការ និងដំណោះស្រាយជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន។

➢ **ប្រជុំនៅឃុំលើកទី២**

- ផ្អែកតាមលទ្ធផលនៃការប្រជុំភូមិ គ.ផ.ថ បូកសរុប ផ្ទៀងផ្ទាត់ និងកែសម្រួលតារាងបញ្ហាតម្រូវការ និងដំណោះស្រាយដែលជាលទ្ធផលនៃការប្រជុំនៅឃុំលើកទី១

- គ.ផ.ថ បំប្លែងបញ្ហាតម្រូវការ និងដំណោះស្រាយទាំងនោះទៅជាគម្រោងសកម្មភាព និងចាត់អាទិភាពគម្រោងសកម្មភាពទាំងនេះ
- គ.ផ.ថ ពិចារណា និងកំណត់សកម្មភាពនានានៃការអនុវត្តមុខងារ កាតព្វកិច្ចដែលរដ្ឋបាលឃុំទទួលបាន និង/ឬគម្រោងនានាដែលត្រូវប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ
- គ.ផ.ថ ក៏ត្រូវពិចារណា និងកំណត់គម្រោងជាអាទិភាពដែលសល់ពីឆ្នាំកន្លងទៅផងដែរ
- គ.ផ.ថ ស្រង់សកម្មភាពគម្រោងទាំងនេះចូលតារាងតម្រូវការគម្រោង សកម្មភាពអាទិភាព តាមផ្នែក និងតាមលំដាប់លំដោយអាទិភាពផ្អែកតាមការណែនាំរបស់ក្រុមការងារកសាងផែនការស្រុក គ.ផ.ថ ត្រូវរៀបចំទម្រង់ទី១របស់ស្រុក ចំពោះគម្រោងទាំងឡាយណាដែលរដ្ឋបាលឃុំ ត្រូវស្នើសុំបញ្ចូលក្នុងកម្មវិធីវិនិយោគស្រុក ហើយផ្ញើទម្រង់ទី១នេះទៅស្រុកតាមកាលបរិច្ឆេទកំណត់។

**ជំហានទី២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

➢ **ការពិនិត្យគម្រោង និងសកម្មភាពអាទិភាពឡើងវិញ**

បន្ទាប់ពីកិច្ចប្រជុំផ្សព្វផ្សាយនៅថ្នាក់ស្រុក គ.ផ.ថ ត្រូវពិនិត្យមើលឡើងវិញនូវតម្រូវការគម្រោង សកម្មភាពអាទិភាពរបស់ឃុំ ដែលបានរៀបចំក្នុងជំហានទី១ ដើម្បី៖

- កំណត់យកគម្រោងសកម្មភាពណាដែលនៅតែមានតម្រូវការជាអាទិភាព
- ដកចេញនូវគម្រោងសកម្មភាពណាដែលលែងមានតម្រូវការចាំបាច់។

➢ **ការត្រៀមរៀបចំចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក**

បន្ទាប់ពីទទួលបានព័ត៌មានអំពីលទ្ធភាពថវិកា គ.ផ.ថ ពិនិត្យ និងសម្រេចជាបណ្តោះអាសន្នក្នុងការជ្រើសរើសគម្រោងសកម្មភាព អាទិភាពសម្រាប់ប្រើប្រាស់ថវិកានេះដោយជ្រើសរើស៖

- គម្រោង ឬសកម្មភាពសម្រាប់ប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ ដោយផ្អែកតាមអាទិភាពនៃសំណើគម្រោងក្នុងផ្នែកនីមួយៗ
- គម្រោង ឬសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារជាកាតព្វកិច្ច
- គម្រោងអាទិភាពនានាសម្រាប់ប្រើប្រាស់មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

បន្ទាប់មក គ.ផ.ថ រៀបចំតារាងតម្រូវការគម្រោង សកម្មភាពអាទិភាព ដោយបំពេញបន្ថែមនូវប្រភពថវិកា។ បន្ទាប់ពីរៀបចំតារាងរួច គ.ផ.ថ រៀបចំតារាងលទ្ធផលនៃការអនុវត្តគម្រោងក្នុងឆ្នាំថវិកា។

មេឃុំផ្ញើតារាងទៅមន្ទីរផែនការខេត្តសម្រាប់សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ស្រុក។

➢ **ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក**

មេឃុំ ចាត់ចែងសម្រាប់ការចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុកដូចខាងក្រោម៖

- ចាត់តំណាងប្រតិភូចូលរួម៖ មេឃុំ ស្មៀន សមាជិក ក្រុមប្រឹក្សា១ឬ២រូប និងមេភូមិមួយចំនួនតាមការចាំបាច់
- រៀបចំឯកសារបិទបង្ហាញ៖ ផែនទីភូមិសាស្ត្រ សេដ្ឋកិច្ច ចាត់តំណាង១រូបចាំបំភ្លឺខ្លឹមសារតារាងនានាដែលបានបិទបង្ហាញក្នុងសិក្ខាសាលា

ត្រៀមឯកសារសម្រាប់កិច្ចព្រមព្រៀងបណ្ដោះអាសន្ន។ តំណាងប្រតិភូ១រូប (ធម្មតាគឺមេឃុំ) ឡើងបង្ហាញបំភ្លឺខ្លឹមសារអត្ថន័យដើម្បីសុំការគាំទ្រថវិកា និងបច្ចេកទេស។

➢ **ការងារក្រោយពីសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក**

គ.ផ.ថ ពិនិត្យ និងកែសម្រួលផ្នែកតាមលទ្ធផលសិក្ខាសាលាសមាហរណកម្ម ព្រមទាំងឯកភាពគ្នាក្នុងការប្រើប្រាស់មូលនិធិរបស់ឃុំ (បើមានការផ្លាស់ប្តូរ) សម្រាប់អនុវត្តគម្រោងសកម្មភាពអាទិភាពដែលគ្មានការសន្យាគាំទ្រ។

មេភូមិនីមួយៗត្រូវស្រង់យកឈ្មោះគម្រោងសកម្មភាពដែលស្ថិតនៅក្នុងភូមិរបស់ខ្លួន ដើម្បីយកទៅបង្ហាញ និងពិភាក្សាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងភូមិខ្លួន។ មេភូមិបូកសរុបមតិយោបល់ហើយដាក់ជូន គ.ផ.ថ ពិនិត្យ ពិចារណា និងកែតម្រូវ។

➢ **ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ**

- គ.ផ.ថ រៀបចំតារាងតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

➢ **ការចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

- គ.ផ.ថ រៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំស្របតាមមាតិកាដែលបានកំណត់។

**ជំហានទី៣៖ ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

➢ **កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគ**

បន្ទាប់ពីបានសេចក្តីព្រាងកម្មវិធីវិនិយោគ ប្រធានក្រុមប្រឹក្សាឃុំត្រូវកោះប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគ។ បន្ទាប់ពីកិច្ចប្រជុំក្រុមប្រឹក្សា គ.ផ.ថ ត្រូវ៖

- កែតម្រូវកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ
- តាក់តែងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- ដាក់ជូនប្រធានក្រុមប្រឹក្សាឃុំនូវសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដែលបានកែតម្រូវរួច និងសេចក្តីព្រាងសេចក្តីសម្រេចដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគនេះដើម្បីពិនិត្យ និងចុះហត្ថលេខា។

➢ **ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគ**

**ការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគ៖** មេឃុំត្រូវរៀបចំបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ។

**ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគ៖** សៀវភៅកម្មវិធីវិនិយោគឃុំ ត្រូវតម្កល់ទុកនៅសាលាឃុំ ការិយាល័យផែនការ និងគាំទ្រឃុំ ឬការិយាល័យផែនការ និងអភិវឌ្ឍ ទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ទីរផែនការខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។

មេឃុំត្រូវណែនាំឱ្យមានការផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ និងអ្នកពាក់ព័ន្ធដូចជាផ្សព្វផ្សាយក្នុងកិច្ចប្រជុំនានា ក្នុងវេទិកាសាធារណៈ តាមសារព័ត៌មាន វិទ្យុ និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន។ មេឃុំ ត្រូវរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគម្រោងប្រើប្រាស់មូលនិធិឃុំ ស្រុក ខេត្ត និងគម្រោងប្រើប្រាស់ប្រភពមូលនីធិផ្សេងទៀតដែលត្រូវអនុវត្តក្នុងដែនដីរដ្ឋបាលឃុំ ដើម្បីឱ្យប្រជាពលរដ្ឋក្នុងឃុំបានដឹង។

### ២.៣.២.៣. គម្រោង និងសកម្មភាពវិនិយោគរបស់ឃុំ

ក្រុមប្រឹក្សាឃុំតាំងយ៉ាបអាណត្តិទី៥ បានសហការយ៉ាងជិតស្និតជាមួយគណៈកម្មាធិការកសាងផែនការ និងថវិកា និងប្រជាពលរដ្ឋក្នុងឃុំទាំងមូល ដើម្បីអភិវឌ្ឍមូលដ្ឋានដោយមានគោលបំណងខ្ពស់ដូចជាការបង្កើនទិន្នផលស្រូវ កែលម្អប្រព័ន្ធធារាសាស្ត្រ កែលម្អផ្លូវលំ បង្កើនការផ្សព្វផ្សាយ និងលើកកម្ពស់សុខភាពអនាម័យ លើកកម្ពស់ការអប់រំ លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន អំពីច្បាប់ផ្សេងៗ អំពីសិទ្ធិសេរីភាពរស់នៅ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។[46]

ដើម្បីសម្រេចទិសដៅអភិវឌ្ឍន៍ទាំងនេះបាន ឃុំត្រូវប្រឹងប្រែងទំនាក់ទំនងយ៉ាងជិតស្និតជាមួយមន្ទីរជំនាញជុំវិញខេត្ត អង្គភាព អង្គការនានា និងសប្បុរសជនក្នុងនិងក្រៅប្រទេស ដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួនដូចជា ដីខ្សោះជីជាតិ បច្ចេកទេសកសិកម្ម បច្ចេកទេសចិញ្ចឹមសត្វ ការដាំដំណាំរួមផ្សំគឺនៅមានកម្រិត។ ចំពោះផ្លូវគមនាគមន៍ក៏ជួបការលំបាក រីឯការងារអប់រំ ក៏ដូចជាការងារសុខាភិបាល គឺនៅមានកង្វះខាតសម្ភារៈ និងបច្ចេកទេសជំនាញមិនទាន់ស៊ីជម្រៅល្អ។ ចំណែកផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសាធារណៈក៏នៅជួបការលំបាកដោយប្រទេសយើងបានឆ្លងកាត់សង្គ្រាមជាច្រើនជំនាន់ ដូចនេះការអនុវត្តច្បាប់ និងការគោរពច្បាប់គឺពុំទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ។[47]

### ២.៣.៣. គម្រោង សកម្មភាពដែលមានថវិកាគាំទ្រ

តាមរយៈកិច្ចប្រជុំកន្លងមក ក្រុមប្រឹក្សាឃុំបានរៀបចំគម្រោងវិនិយោគមួយចំនួនដែលមានថវិកាគាំទ្រឃុំលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ គម្រោងវិនិយោគទាំងនោះមានដូចជា៖

[46] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

[47] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

- **ផ្នែកសេដ្ឋកិច្ច៖** ការចាក់ផ្លូវបេតុងអាមេក្នុងភូមិជំពៅ មានប្រវែង២៤៨ម៉ែត្រ ចំណាយ១២៣ ០០០ ០០០រៀល។ ជួសជុលផ្លូវចាក់គ្រោះធម្មជាតិក្នុងភូមិព្រៃចំបក់ មានប្រវែង២ ០២០ម៉ែត្រ ចំណាយអស់ ៥០ ០០០ ០០០រៀល។ ថែទាំផ្លូវក្នុងភូមិត្រពាំងទា មានប្រវែង៧០០ម៉ែត្រ ចំណាយអស់ ២០ ០០០ ០០០រៀល។[48]
- **ផ្នែកសង្គមកិច្ច៖** ផ្សព្វផ្សាយកញ្ចប់ព័ត៌មានសិទ្ធិ និងស្តង់ដាសម្រាប់ប្រជាពលរដ្ឋក្នុងឃុំ ប្រជុំចំនួន២លើកក្នុងមួយឆ្នាំ ចំណាយអស់ ២៤០ ០០០រៀល។ កិច្ចប្រជុំដាក់ពិន្ទុជាមួយអ្នកផ្តល់សេវាក្នុងឃុំ ប្រជុំចំនួន២លើកក្នុងមួយឆ្នាំ ចំណាយទឹកប្រាក់ចំនួន ១៨០ ០០០រៀល។ កិច្ចប្រជុំដាក់ពិន្ទុជាមួយអ្នកទទួលសេវាក្នុងឃុំ ប្រជុំចំនួន១លើកក្នុងមួយឆ្នាំ ចំណាយទឹកប្រាក់ចំនួន ៣០០ ០០០រៀល។ កិច្ចប្រជុំរួមជាមួយប្រជាពលរដ្ឋ និងអ្នកផ្តល់សេវាក្នុងឃុំ ប្រជុំចំនួន១លើកក្នុងមួយឆ្នាំ ចំណាយអស់២៤០ ០០០រៀល។ បណ្តុះបណ្តាលគណៈកម្មាធិការ JAAPក្នុងឃុំ ប្រជុំចំនួន១លើកក្នុងមួយឆ្នាំ ចំណាយទឹកប្រាក់ ១២០ ០០០រៀល។[49]
- **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់៖** ផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ចំនួន១០ភូមិ ធ្វើឡើងចំនួន៥០វគ្គក្នុងមួយឆ្នាំ ចំណាយអស់ទឹកប្រាក់ចំនួន ៣ ០០០ ០០០រៀល។[50]

### ២.៣.៤. គម្រោង សកម្មភាពដែលមិនទាន់មានថវិកាគាំទ្រ

ចំពោះគម្រោង សកម្មភាពដែលមិនទាន់មានថវិកាគាំទ្រគឺស្ថិតនៅក្នុងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលរួមមានដូចតទៅ៖

- **ផ្នែកសេដ្ឋកិច្ច៖** ជួសជុលផ្លូវទូទាំងឃុំ ប្រវែង១០ ០០០ម៉ែត្រ ដោយអនុវត្តក្នុងរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបមានចំនួន ៨ ៨១៥នាក់ អ្នកទទួលផលស្រីមានចំនួន ៤ ២៣៧នាក់ និងចំណាយប៉ាន់ស្មានចំនួន ៣០០ ០០០ ០០០រៀល។ ដាក់លូកាត់ផ្លូវទូទាំងឃុំចំនួន១២កន្លែង ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន៨ ៨១៥នាក់ អ្នកទទួលផលស្រីមានចំនួន ៤ ២៣៧នាក់និងចំណាយប៉ាន់ស្មានចំនួន៧២ ០០០ ០០០រៀល។ សង់ផ្លូវក្រាលកៅស៊ូទូទាំងឃុំប្រវែង៤ ០០០ម៉ែត្រ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៤ ៧២០នាក់ អ្នកទទួលផលស្រីចំនួន ២ ៦៧២នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ៨៨០ ០០០ រៀល។ ស្ពារប្រឡាយទូទាំងឃុំ ប្រវែង ៤ ២០០ម៉ែត្រ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលសរុបចំនួន ៤ ៧២០ នាក់ អ្នកទទួលផលស្រីចំនួន ២ ៦៧២នាក់ និងចំណាយប៉ាន់ស្មានចំនួន ១៦៨ ០០០ ០០០រៀល។ បណ្តុះបណ្តាលបច្ចេកទេសកសិកម្មទូទាំងឃុំចំនួន១២វគ្គ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលសរុបចំនួន៣៥០នាក់ អ្នកទទួលផលស្រីចំនួន ១៥០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ធ្វើជីធម្មជាតិទូទាំងឃុំចំនួន

[48] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,តារាង២.៣

[49] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,តារាង២.៣

[50] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,តារាង២.៣

១២វគ្គ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលសរុបចំនួន ៣៥០នាក់ អ្នកទទួលផលស្រីចំនួន ១៥០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ សង់ស្ពានីយ៍បូមទឹកភូមិស្នួលខ្ពស់ចំនួន ១កន្លែង ដោយអនុវត្ត រយៈពេល ៣ឆ្នាំ អ្នកទទួលផលសរុបចំនួន៨ ៨១៥នាក់ អ្នកទទួលផលស្រីចំនួន ៤ ២៣៧នាក់ និងចំណាយប៉ាន់ស្មាន ចំនួន ១៨០ ០០០ ០០០រៀល។ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វទូទាំងឃុំ ចំនួន១២វគ្គ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលសរុបចំនួន ៣៥០នាក់ អ្នកទទួលផលស្រីចំនួន ១៥០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ផ្តល់ពូជស្រូវផ្ការំដួលទូទាំងឃុំចំនួន ១២តោន ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលសរុប ចំនួន៣៥០នាក់ អ្នកទទួលផលស្រីចំនួន១៥០នាក់ និងចំណាយប៉ាន់ស្មានចំនួន២ ០០០ ០០០រៀល។[51]

- **ផ្នែកសង្គមកិច្ច៖** ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារទូទាំងឃុំចំនួន១២វគ្គ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៦០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ អប់រំសុខភាពអនាម័យទូទាំងឃុំចំនួន១២វគ្គ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផល ផ្ទាល់សរុបចំនួន ៣៦០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ សង់បង្គន់អនាម័យទូទាំងឃុំចំនួន១២កន្លែង ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៧០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ផ្សព្វផ្សាយ ច្បាប់ភូមិបាលទូទាំងឃុំចំនួន១២វគ្គ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៧០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ចាក់វ៉ាក់សាំងការពារ សត្វទូទាំងឃុំចំនួន១ ២០០ក្បាល ដោយអនុវត្តក្នុងរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបមានចំនួន ៤ ១៦០នាក់ អ្នកទទួលផលស្រីមានចំនួន ២ ១៥០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ផ្សព្វផ្សាយលក្ខណៈ សម្បត្តិភូមិ ឃុំមានសុវត្ថិភាព ទូទាំងឃុំចំនួន១២វគ្គ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៦០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ផ្សព្វផ្សាយ ការអប់រំសុខភាពស្ត្រីមានផ្ទៃពោះ និងកុមារ ទូទាំងឃុំចំនួន១២វគ្គ ក្នុងរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុប មានចំនួន ៣៦០នាក់ ក្នុងនោះស្រីមានចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន២ ០០០ ០០០រៀល។ ជួយ កុមារពិការក្រីក្រគ្មានទីពឹងទូទាំងឃុំចំនួន ៣៦នាក់ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៦នាក់ អ្នកទទួលផលស្រីចំនួន ១៨នាក់ និងចំណាយប៉ាន់ស្មានចំនួន ១ ៤០០ ០០០រៀល។ ផ្តល់អាហារបំប៉ន ដល់កុមារក្រីក្រគ្មានទីពឹងទូទាំងឃុំចំនួន ៣៦នាក់ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៦នាក់ អ្នកទទួលផលស្រីចំនួន ១៨នាក់ និងចំណាយប៉ាន់ស្មានចំនួន ១ ៤០០ ០០០ រៀល។[52]

---

[51] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,តារាង២.៤

[52] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,តារាង២.៤

• **ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖** ការដាំកូនឈើទូទាំងឃុំចំនួន ១ ២០០ដើម ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ២ ៥៦០នាក់ អ្នកទទួលផលស្រីមានចំនួន ១ ៥៣១នាក់ និងចំណាយប៉ាន់ស្មានចំនួន ៦ ០០០ ០០០រៀល។ ផ្សព្វផ្សាយច្បាប់បរិស្ថានទូទាំងឃុំចំនួន ១២វគ្គ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៦០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ បង្កើតទីតាំងចាក់សំរាមនៅភូមិសំបូរចំនួន ១កន្លែង ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៥៦៧នាក់ អ្នកទទួលផលស្រីចំនួន ៣៩១នាក់ និងចំណាយប៉ាន់ស្មានចំនួន ៨ ០០០ ០០០រៀល។ ដាក់លូរំដោះទឹកស្អុយនៅភូមិសំបូរ និងភូមិកែវចំរើន មានប្រវែង ២០០០ម៉ែត្រ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៦១៥នាក់ អ្នកទទួលផលស្រីចំនួន ២៧៦នាក់ និងចំណាយប៉ាន់ស្មានចំនួន ១៥០ ០០០ ០០០រៀល។[53]

• **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖** ផ្សព្វផ្សាយច្បាប់រដ្ឋបាលទូទាំងឃុំចំនួន ១២វគ្គ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៤ ៧២០នាក់ អ្នកទទួលផលស្រីចំនួន ២ ៦៧២នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ផ្សព្វផ្សាយច្បាប់នេសាទទូទាំងឃុំចំនួន១២វគ្គ ដោយអនុវត្តរយៈពេល៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៩០នាក់ អ្នកទទួលផលស្រីចំនួន ១៣២នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌទូទាំងឃុំចំនួន១២វគ្គ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៦០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០ ០០០រៀល។ ផ្សព្វផ្សាយច្បាប់បង្ក្រាបល្បែងស៊ីសងទូទាំងឃុំចំនួន ១២វគ្គ ដោយអនុវត្តរយៈពេល ៣ឆ្នាំ អ្នកទទួលផលផ្ទាល់សរុបចំនួន ៣៦០នាក់ អ្នកទទួលផលស្រីចំនួន ១៧០នាក់ និងចំណាយប៉ាន់ស្មានចំនួន ២ ០០០.០០០រៀល។[54]

### ២.៣.៥. សមិទ្ធផលនានា

នៅក្នុងឃុំតាំងយ៉ាប តាំងពីអាណត្តិទី១ រហូតមកដល់អាណត្តិទី៥នេះ បានអភិវឌ្ឍ និងកសាងសមិទ្ធផលនានាជាច្រើននៅក្នុងមូលដ្ឋានឃុំរបស់ខ្លួន សម្រាប់បំពេញតម្រូវការរបស់ប្រជាពលរដ្ឋ និងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើងបន្ថែមទៀត។ នៅឃុំតាំងយ៉ាបទាំងមូលមានភូមិចំនួន១២ ហើយមានសមិទ្ធផលនានាជាច្រើនដូចជា ផ្លូវថ្នល់ សាលារៀន ស្ពាន ប្រឡាយទឹក វត្តអារាម បណ្តាញអគ្គីសនី។ល។

សមិទ្ធផលនៃការអភិវឌ្ឍមូលដ្ឋានពីឆ្នាំ២០០៣ រហូតមកដល់បច្ចុប្បន្ន(២០២៤) ដោយការអនុវត្តគោលនយោបាយវិមជ្ឈការ ឃុំតាំងយ៉ាបសម្រេចបាននូវសមិទ្ធផលធំៗមានរួមមានដូចតទៅ៖

[53] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,តារាង២.៤

[54] កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,តារាង២.៤

- ឆ្នាំ២០០៣ ធ្វើលូកាត់ផ្លូវចំនួន៤កន្លែង ក្នុងភូមិរលួស ជំរៅ ក្រាំងអំពិល ត្រពាំងទា ដោយចំណាយទឹកប្រាក់ចំនួន ៧ ០៤០ ០០០ រៀល
- ឆ្នាំ២០០៤ ក្រាលថ្មផេះផ្លូវលំនៅភូមិប្រនៀងខ្ពស់ និងរលួស ប្រវែង១៧៦០ម៉ែត្រ ដោយចំណាយទឹកប្រាក់ចំនួន ២៤ ៥៣៣ ៣០០រៀល
- ឆ្នាំ២០០៥ ផ្លូវក្រាលកំទេចថ្មM30 នៅភូមិក្រាំងអំពិល ប្រនៀងខ្ពស់ ប្រវែង១ ៨៥៥ម៉ែត្រ ចំណាយទឹកប្រាក់ចំនួន ២៨ ៤២៤ ៤០០រៀល
- ឆ្នាំ២០០៦ ផ្លូវក្រាលកំទេចថ្មផេះនៅភូមិកែវចំរើន ប្រវែង១ ៥៩៥ម៉ែត្រ ចំណាយអស់ទឹកប្រាក់ ៣៣ ៣៦៨ ៤០០រៀល
- ឆ្នាំ២០០៧ ជីកប្រឡាយភូមិត្រពាំងស្តុកប្រវែង១ ០៤១ម៉ែត្រចំណាយទឹកប្រាក់ចំនួន ៣១ ៥២៥ ០០០រៀល
- ឆ្នាំ២០០៨ ផ្លូវក្រាលកំទេចថ្មផេះ ភូមិអង់រវាយ និងភូមិសំបូរ ប្រវែង១ ៦១៩ម៉ែត្រ ចំណាយទឹកប្រាក់ចំនួន ៣៣ ៨៥៣ ៤០០រៀល
- ឆ្នាំ២០០៩ ផ្លូវលំក្រាលកំទេចថ្មផេះ ភូមិស្នួលខ្ពស់ ប្រវែង១ ១៣៦ម៉ែត្រ ចំណាយទឹកប្រាក់អស់ចំនួន ៣៧ ៣០០ ០០០រៀល
- ឆ្នាំ២០១០ ផ្លូវលំក្រាលកំទេចថ្មផេះភូមិត្រពាំងស្តុកប្រវែង១៤១០ម៉ែត្រ អស់ទឹកប្រាក់ចំនួន៥៥ ៤០៩ ៤០០រៀល
- ឆ្នាំ២០១១ ក្រាលកំទេចថ្មផេះផ្លូវលំនៅក្នុងភូមិត្រពាំងទា និងព្រៃចំបក់ប្រវែង ១ ១៦០ម៉ែត្រ ចំណាយអស់ ២៨ ៧៦៣ ៥០០រៀល
- ឆ្នាំ២០១២ ជីកប្រឡាយនៅភូមិក្រាំងចំរើន ជំរៅ និងកែវចំរើន ប្រវែង ១ ៧៣៨ម៉ែត្រ ចំណាយទឹកប្រាក់ចំនួន ៤១ ១៧០ ៩០៩រៀល
- ឆ្នាំ២០១៣ ជីកប្រឡាយភូមិកែវចំរើន និងអង់រវាយ ប្រវែង១៦៦៥ម៉ែត្រ ចំណាយទឹកប្រាក់ចំនួន ៦២ ១៦៧ ០០០រៀល
- ឆ្នាំ២០១៤ ជីកប្រឡាយភូមិរលួស ប្រវែង ១ ៦៦៥ម៉ែត្រ ចំណាយអស់ ២៤ ៩០០ ០០០រៀល
- ឆ្នាំ២០១៥ មន្ទីរអភិវឌ្ឍជនបទខេត្ត បានជួយសាងសង់ផ្លូវកៅស៊ូមួយខ្សែប្រវែង ៣ ៥០០ម៉ែត្រ តម្លៃ ៧៦ ៥៤២ ១០៥រៀល
- ឆ្នាំ២០១៥ ជីកប្រឡាយភូមិត្រពាំងទា និងរលួសប្រវែង១ ៦៨១ម៉ែត្រ ចំណាយអស់ ៦១ ៥០០ ០០០រៀល
- ឆ្នាំ២០១៦ ជីកប្រឡាយភូមិរលួស កែវចំរើន ប្រវែង១ ៧៩៨ម៉ែត្រ ចំណាយអស់ ៨០ ៥០១ ៧១៣រៀល
- ឆ្នាំ២០១៧ ក្រាលខ្សាច់ធម្មជាតិផ្លូវលំ នៅភូមិកែវចំរើន ប្រវែង១ ៤៦៣ម៉ែត្រ ចំណាយអស់ ៦១ ១៨៩ ៦២០រៀល
- ឆ្នាំ២០១៨ ក្រាលខ្សាច់ធម្មជាតិផ្លូវលំភូមិជំរៅ ប្រវែង ១ ០៣០ ម៉ែត្រ ចំណាយថវិកាចំនួន ១០ ១៦៧ ០០០រៀល
- ឆ្នាំ២០១៩ ជីកប្រឡាយភូមិត្រពាំងស្តុក ក្រាំងអំពិល ប្រវែង៨៣៥ម៉ែត្រ ចំណាយ ៣៤ ៣៩៦ ៤២៩រៀល

- ឆ្នាំ២០១៩ ក្រាលខ្សាច់ធម្មជាតិផ្លូវលំភូមិកែវចំរើន ជំរៅ និងក្រាំងចំរើន ប្រវែង១ ៤៤៧ម៉ែត្រ ចំណាយអស់ ៤៤ ៤៧៩ ៧៦៧រៀល
- ឆ្នាំ២០២០ សាងសង់ផ្លូវបេតុងអាមេ ភូមិជំរៅ ប្រវែង៣០៥ម៉ែត្រ ចំណាយអស់ ១៥៧ ០៤២ ៥៥៣រៀល
- ឆ្នាំ២០២១ សាងសង់ផ្លូវបេតុងអាមេ ភូមិជំរៅ ប្រវែង២៤៨ម៉ែត្រ ចំណាយទឹកប្រាក់ ១២២ ៧០០ ០០០រៀល
- ឆ្នាំ២០២១ ក្រាលខ្សាច់ធម្មជាតិផ្លូវលំភូមិព្រៃចំបក់ប្រវែង២ ០២០ម៉ែត្រចំណាយអស់ ៥០ ០០០ ០០០រៀល
- ឆ្នាំ២០២២ ជីកប្រឡាយ កាត់ភូមិត្រពាំងស្គុក រលួស ច្រនៀងខ្ពស់ ជំរៅ ប្រវែង ៥ ៥០០ម៉ែត្រ ចំណាយអស់ ១៦៤ ៩៤៤ ៤៤៤រៀល
- ឆ្នាំ២០២៣ សាងសង់ផ្លូវបេតុងអាមេភូមិព្រៃចំបក់ប្រវែង៩៣៤ម៉ែត្រ ចំណាយអស់ ២៦៨ ១៤១ ១៧៧រៀល
- ឆ្នាំ២០២៣ ក្រាលកំទេចថ្មM30ផ្លូវលំ ភូមិត្រពាំងស្គុក រលួស ដាក់លូ២កន្លែង ប្រវែង ១ ៤៩០ម៉ែត្រ ចំណាយអស់ ៨៦ ១០៥ ២៦៣រៀល ។[55]

[55] របាយការណ៍ស្តីពីការអភិវឌ្ឍមូលដ្ឋានឃុំតាំងយ៉ាបចាប់ពីឆ្នាំ២០០៣ ដល់២០២៣

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣

# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងពិនិត្យមើលយ៉ាងស៊ីជម្រៅទៅលើសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំរបស់ឃុំតាំងយ៉ាប និងការចុះអង្កេតផ្ទាល់នៅមូលដ្ឋានឃុំ ដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្ដែងរបស់ឃុំ ព្រមជាមួយការចុះសម្ភាសន៍ព័ត៌មានជាមួយអាជ្ញាធរឃុំ និងប្រជាពលរដ្ឋរួចមកយើងខ្ញុំបានអង្កេតឃើញថា មានបញ្ហាប្រឈមមួយចំនួនដែលឃាត់ឃាំងរាំងផ្លូវនាំឱ្យកកស្ទះដល់ការអភិវឌ្ឍឃុំឱ្យបានរីកចម្រើនក្នុងនោះរួមមានៈ

### ៣.១.១. ស្ថានភាពសេដ្ឋកិច្ច

សាលាឃុំតាំងយ៉ាបស្ថិតក្នុងភូមិកែវចំរើន ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ជាឃុំមួយក្នុងចំណោមឃុំទាំង១៣នៃស្រុកព្រៃកប្បាស ស្ថិតនៅប៉ែកខាងលិចឈៀងខាងជើងទីរួមស្រុកចម្ងាយ១៣គីឡូម៉ែត្រ។ ឃុំតាំងយ៉ាបមានភូមិទាំងអស់ចំនួន១២ ដែលគ្របដណ្ដប់លើផ្ទៃដី១ ៦០១ហិចតា មានប្រជាជនសរុបចំនួន៩ ៥២៨នាក់ ក្នុងនោះស្រីមានចំនួន ៤ ៩១៨នាក់។ ឃុំនេះមានផ្ទៃដីកសិកម្មចំនួន ៩៨៩ហិចតា ដែលប្រជាពលរដ្ឋចំនួន៩០%ជាកសិករនិងជាអាជីវករតម្បាញហូល ក្រៅពីនោះជាមន្ត្រីរាជការ និងជាអាជីវករលក់ដូរ។ល។ ឃុំនេះមានសក្ដានុពលទៅលើផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវលំ ក្រាលកៅស៊ូ ក្រាលបេតុង ក្រាលថ្មផេះ និងក្រាលខ្សាច់ធម្មជាតិខ្វាត់ខ្វែងងាយស្រួលក្នុងការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋពីភូមិមួយទៅភូមិមួយទៀត និងងាយស្រួលដឹកជញ្ជូនកសិផលដែលផលិតបានយកទៅដោះដូរនៅតាមទីផ្សារនានា មានប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពដែលទទួលបានពីអាងទឹកទួលលលក ក៏ប៉ុន្តែប្រព័ន្ធស្រោចស្រពទាំងនោះប្រើប្រាស់បានតែនៅរដូវមានភ្លៀង។ ការលំបាកកន្លងមកនោះគឺបញ្ហាទឹកជន់លិច ដោយសារគ្មានលូបញ្ជ្រាសទឹក ពេលទឹកស្រកទៅវិញយើងគ្មាននៃលទឹកសម្រាប់តម្កល់ទឹកទុកស្រោចស្រពពេលខ្វះខាត។ ខ្វះមេទឹកសម្រាប់សង្គ្រោះដោយសារប្រឡាយរាក់មិនមានលទ្ធភាពសម្រាប់ស្ដារ។

#### ៣.១.១.១. វិស័យកសិកម្ម

ក្នុងឃុំតាំងយ៉ាបមានប្រជាពលរដ្ឋចំនួន៩០ភាគរយប្រកបរបរជាកសិករ ពោលគឺការធ្វើស្រែជាចម្បង។ មួយវិញទៀត នៅតាមផ្ទះសំបែងរបស់ប្រជាពលរដ្ឋសង្កេតឃើញមានការចិញ្ចឹមសត្វបែបទ្រង់ទ្រាយតូចជាលក្ខណៈគ្រួសារដូចជាការចិញ្ចឹមជ្រូក គោ មាន់ ទា ព្រមទាំងមានការដាំដំណាំមិនថាជាដំណាំហូបផ្លែ ឬបន្លែបង្ការដែលរួមមាន ស្វាយ ដូង ល្ពៅ ត្រកួន ននោង សណ្ដែកគួ និងដំណាំផ្សេងៗជាច្រើនទៀត សម្រាប់ផ្គត់ផ្គង់ចំណីអាហារប្រចាំថ្ងៃ និងលក់ដូរបន្តិចបន្តួចនៅលើទីផ្សារ។

ស្របនឹងកត្តាអំណោយផលខាងលើ ឃុំតាំងយ៉ាបក៏នៅជួបប្រទះនូវការលំបាកមួយចំនួនទៅលើវិស័យកសិកម្មដែលរួមមាន ដីកាន់តែខ្សោះជីជាតិពីមួយឆ្នាំទៅមួយឆ្នាំបណ្តាលឱ្យការបង្កបង្កើនផលស្រូវទទួលបានទិន្នផលទាប ការប្រើប្រាស់ពូជនៅមិនទាន់បានសមស្របនៅឡើយ ខ្វះការស្រាវជ្រាវរកពូជស្រូវមានទិន្នផលខ្ពស់ស្របនឹងភូមិសាស្ត្រដីដោយខ្វះបច្ចេកទេស ពោលគឺខ្វះបច្ចេកទេសប្រើជី ប្រើពូជ ប្រើថ្នាំសម្លាប់សត្វល្អិតជាដើម។

**៣.១.១.២. ផ្នែកធារាសាស្ត្រ**

ឃុំតាំងយ៉ាបមានភូមិសាស្ត្រ ប៉ែកខាងលិចឈៀងខាងត្បូងជាប់នឹងអាងទឹកទួលលលកដែលភ្ជាប់ដោយប្រព័ន្ធធារាសាស្ត្រប្រឡាយមេរបស់ឃុំចំនួន ៤ខ្សែ ហើយប្រឡាយមេទាំងនោះក៏ភ្ជាប់បែកដោយប្រឡាយមធ្យមចំនួន៤ខ្សែទៀត ហើយក៏មានប្រឡាយកូនចំនួន១៣ខ្សែតភ្ជាប់ពីប្រឡាយមធ្យមដែលមានប្រវែងសរុបទាំងអស់ ២ ៧០០ម៉ែត្រ ដែលបានបង្កលក្ខណៈងាយស្រួលក្នុងការបង្កបង្កើនផលស្រូវ។

ប៉ុន្តែស្របនឹងកត្តាអំណោយផលខាងលើ ឃុំតាំងយ៉ាបក៏នៅជួបប្រទះនូវបញ្ហាទាក់ទងនឹងប្រព័ន្ធធារាសាស្ត្រដែលមានដូចជា ទឹកជន់លិចដោយសារគ្មានលូបញ្ច្រាសទឹក ហើយពេលទឹកស្រកទៅវិញគ្មាននលែលទឹកសម្រាប់តម្កល់ទឹកទុកស្រោចស្រពពេលខ្វះខាត និងកង្វះមេទឹកសម្រាប់សង្គ្រោះដោយសារប្រឡាយមានទំហំតូច និងរាក់មិនមានលទ្ធភាពក្នុងការស្តារនាំឱ្យមានការខ្វះខាតទឹកសម្រាប់ប្រជាពលរដ្ឋធ្វើស្រែបង្កបង្កើនផល។

**៣.១.១.៣. ផ្នែកអាជីវកម្ម**

ក្រៅពីមុខរបរសំខាន់គឺកសិកម្ម ប្រជាពលរដ្ឋក្នុងឃុំមានមុខរបរដ៏សំខាន់មួយទៀតផងដែរគឺ សិប្បកម្មត្បាញហូល។ នៅតាមផ្ទះរបស់ប្រជាពលរដ្ឋប្រហែល៩០ភាគរយសុទ្ធតែប្រកបរបរផ្នែកតម្បាញដែលមានតាំងពីយូលង់ណាស់មកហើយ។ របរមួយនេះបានផ្តល់ការងារប្រចាំថ្ងៃដល់ស្ត្រីមេផ្ទះភាគច្រើន ដែលគាត់មិនអាចចេញទៅធ្វើការងារឆ្ងាយពីផ្ទះសំបែងបាន។ ក្រៅពីនោះ ក៏មានប្រជាពលរដ្ឋមួយចំនួនប្រកបរបរជាអាជីវករលក់ដូរដូចជាទំនិញចាប់ហួយ បន្លែបង្ការ សម្ភារៈសំណង់ ការលក់ដូរគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ផ្សេងៗជាច្រើនទៀតផងដែរ។

ប៉ុន្តែឃុំតាំងយ៉ាបក៏បាននឹងកំពុងជួបប្រទះនូវបញ្ហាមួយចំនួនផងដែរ ដោយមុខរបរដ៏សំខាន់គឺសិប្បកម្មតម្បាញហូលរបស់ប្រជាពលរដ្ឋនោះ តឡូវហូលចុះថោក ខ្វះទីផ្សារសម្រាប់លក់ ពោលគឺថ្លៃលក់ហូលមិនស្របនឹងតម្លៃវត្ថុធាតុដើមបូកនឹងកម្លាំងពលកម្ម ។ ឯការលក់ដូរក្នុងទ្រង់ទ្រាយតូចរបស់ប្រជាពលរដ្ឋមួយចំនួន ហាក់ដូចជាទទួលបានផលចំណេញតិចតួចសឹងតែមិនអាចផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃបាន។

**៣.១.១.៤. ផ្នែកគមនាគមន៍**

ឃុំតាំងយ៉ាបមានផ្លូវសំខាន់ៗ៣ខ្សែប្រវែង១១.៨០០ម៉ែត្រ ដែលប្រៀបដូចជាសរសៃឈាមតភ្ជាប់ពីភូមិមួយទៅភូមិមួយ ពីឃុំមួយទៅឃុំមួយទៀត ងាយស្រួលក្នុងការធ្វើដំណើរ ក៏ដូចជាការដឹកជញ្ជូនទំនិញផ្សេងៗរបស់

ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ សណ្ឋានផ្លូវរបស់ឃុំមានលក្ខណៈជាផ្លូវលំក្រាលថ្មផេះ ឬខ្សាច់ធម្មជាតិដែលបានជួសជុលជារៀងរាល់ឆ្នាំ ព្រមទាំងមានសំណង់ស្ពាន ទ្វារទឹក និងលូ ជាដើម។

ប៉ុន្តែបញ្ហាប្រឈមផ្នែកគមនាគមន៍របស់ឃុំតាំងយ៉ាបឃើញថា ផ្លូវដែលបានជួសជុលហើយនោះ តែងឆាប់ខូចទៅវិញដោយសាររថយន្តដឹកលើសទម្ងន់ធ្វើចរាចរណ៍ ផ្លូវតាមភូមិតូចចង្អៀត មានសភាពទ្រុឌទ្រោមលិចទឹកនៅក្នុងរដូវវស្សា ដែលជាហេតុធ្វើឱ្យលំបាកក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។

#### ៣.១.១.៥. ផ្នែកសេវាកម្ម

ពីមួយថ្ងៃទៅមួយថ្ងៃប្រជាពលរដ្ឋដែលទទួលសេវាកម្មមានការកើនឡើងជាបណ្តើរៗ សេវាដឹកជញ្ជូនកម្មករទៅបម្រើការងារនៅតាមរោងចក្រឧស្សាហកម្មមួយចំនួន ប្រព័ន្ធអគ្គីសនី ប្រព័ន្ធទឹកស្អាត ការផ្តល់សេវាប្រាក់កម្ចីរបស់ធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការផ្តល់សេវាកម្មរបស់វិស័យឯកជនផ្សេងៗ។ បណ្តាញអគ្គីសនីក្នុងមូលដ្ឋានឃុំតាំងយ៉ាបត្រូវបានផ្គត់ផ្គង់ដោយសហគ្រាស អេឡិកទ្រីស៊ីធីស៊ែវ៉ា ដែលមានទីតាំងស្ថិតក្នុងភូមិសំបូរ ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ និងតំបន់ខ្លះទៀតត្រូវបានផ្គត់ផ្គង់ដោយសហគ្រាស អិន អឹម ក្តាញ់ ស្ថិតក្នុងភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ចំណែកបណ្តាញទឹកស្អាតវិញត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឡាយឡុងឌី គ្រុប ស្ថិតក្នុងភូមិព្រៃភ្លី ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ប៉ុន្តែផ្នែកសេវាកម្មក៏នៅមានបញ្ហាប្រឈមមួយចំនួនផងដែរដូចជា ប្រព័ន្ធអគ្គីសនីមិនសូវមានលក្ខណៈស្តង់ដារ មានការដាច់ចរន្តជាញឹកញាប់ ចរន្តអគ្គីសនីនៅតំបន់ខ្លះមានសភាពខ្សោយពិបាកក្នុងការប្រើប្រាស់។ ចំណែកបណ្តាញទឹកស្អាតហាក់ដូចជាមិនអាចបំពេញតម្រូវការប្រើប្រាស់បានគ្រប់ពេលវេលា ពោលគឺពេលខ្លះទឹកចេញមកខ្សោយ និងពេលខ្លះមានការដាច់ទឹកជាដើម។ រីឯការផ្តល់ប្រាក់កម្ចីរបស់ធនាគារ និងមីក្រូហិរញ្ញវត្ថុមួយចំនួនឃើញថាមានអត្រាការប្រាក់កម្រិតខ្ពស់ ដែលនៅតែជាសម្ពាធរបស់ប្រជាពលរដ្ឋ ប្រជាកសិករដែលមិនមានធនធានធ្វើដើមទុន ឬពង្រីកអាជីវកម្មបន្ថែម។

### ៣.១.២. ស្ថានភាពសង្គមកិច្ច

សង្គមកិច្ចគឺជាផ្នែកមួយដែលធ្វើការសិក្សាទៅលើលក្ខណៈប្រជាសាស្ត្រ ការផ្តល់សេវាសាធារណៈ សុវត្ថិភាពសង្គមរបស់ប្រជាពលរដ្ឋដូចជា ការអប់រំបណ្តុះបណ្តាល សុខុមាលភាពប្រជាពលរដ្ឋ យេនឌ័រ ភាពក្រីក្រ អំពើហិង្សា ការជួញដូរស្ត្រី និងកុមារ ការលើកកម្ពស់សិទ្ធិមនុស្ស ស្ថានភាពសាសនា វប្បធម៌ ប្រពៃណី។ ហេតុនេះយើងត្រូវវិភាគទៅលើខ្លឹមសារតាមវិស័យនីមួយៗដូចខាងក្រោមៈ

#### ៣.១.២.១. ស្ថានភាពអប់រំ

វិស័យអប់រំ គឺជាកត្តាចាំបាច់ដែលមិនអាចខ្វះបានសម្រាប់ពង្រឹងធនធានមនុស្សក្នុងការអភិវឌ្ឍខ្លួនឱ្យទទួលបាននូវចំណេះដឹងកាន់តែច្រើនព្រមទាំងទទួលបានបទពិសោធថ្មីៗបន្ថែមទៀត។ តាមរយៈការអនុវត្តគោលនយោបាយ

របស់រាជរដ្ឋាភិបាលស្តីពីការកែទម្រង់ប្រព័ន្ធអប់រំបែបសាលាជំនាន់ថ្មី ដោយដើរតាមបច្ចេកវិទ្យាឌីជីថល ដើម្បីអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យទទួលបាននូវគុណភាពប្រសើរជាងកាលអនុវត្តតាមកម្មវិធីចាស់។ ឃុំតាំងយ៉ាប មានសាលារៀនបឋមសិក្សា៣កន្លែង វិទ្យាល័យ១កន្លែង ដែលបង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្ស ដែលជាកូនចៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានបានសិក្សារៀនសូត្ររហូតដល់ចប់កម្រិតមធ្យមសិក្សា ។

ប៉ុន្តែបញ្ហាប្រឈមដែលកំពុងជួបប្រទះនោះគឺ សាលារៀនទាំងនោះខ្វះនូវឧបករណ៍ និងសម្ភារៈបម្រើការបង្រៀន និងរៀន ខ្វះថវិកាសម្រាប់កែលម្អសាលារៀនជាដើម។ ម្យ៉ាងវិញទៀតដោយប្រជាពលរដ្ឋមួយចំនួនមានជីវភាពខ្វះខាត ឬមិនបានយល់ដឹងពីសារៈប្រយោជន៍នៃចំណេះដឹងដែលបានពីការសិក្សានៅឡើយ ទើបបណ្តាលឱ្យកុមារមួយចំនួនមិនបានចូលរៀនបានចប់ចុងចប់ដើម ជាហេតុនាំឱ្យពួកគេមិនអាចមានអនាគតភ្លឺស្វាងបាន។

### ៣.១.២.២. ស្ថានភាពសុខាភិបាល

ឃុំតាំងយ៉ាបមានមណ្ឌលសុខភាព១កន្លែង ដែលបានបំពេញតួនាទីយ៉ាងសំខាន់សម្រាប់ជួយគាំពារដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋតាមរយៈការថែទាំសុខភាព និងព្យាបាលជំងឺ។

ប៉ុន្តែបញ្ហាប្រឈមដែលកំពុងកើតមានគឺនៅក្នុងមណ្ឌលសុខភាពពុំទាន់មានថ្នាំ និងឧបករណ៍បច្ចេកទេសគ្រាប់គ្រាន់ និងការបម្រើសេវាជូនប្រជាពលរដ្ឋក៏ពុំទាន់បានល្អប្រសើរនៅឡើយ។ នៅពេលដែលមានស្ត្រីឈឺពោះឆ្លងទន្លេមិនអាចសម្រាលតាមបែបធម្មជាតិបាន ខាងមណ្ឌលសុខភាពក៏មិនអាចមានលទ្ធភាពក្នុងការជួយវះកាត់សម្រាលបាន វាក៏អាចជាបញ្ហាប្រកបដោយគ្រោះថ្នាក់សម្រាប់ម្តាយ និងទារក។ មួយវិញទៀតសេវាព្យាបាលជំងឺក៏មិនទាន់ល្អប្រសើរនៅឡើយពោលគឺខាងមណ្ឌលសុខភាពពុំទាន់មានឧបករណ៍ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការព្យាបាលជំងឺជូនប្រជាពលរដ្ឋបានល្អប្រសើរនៅឡើយ។

### ៣.១.២.៣. ស្ថានភាពយេនឌ័រ

ស្ថានភាពយេនឌ័រមានការពាក់ព័ន្ធនៅគ្រប់វិស័យ និងត្រូវបានយកចិត្តទុកដាក់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានតាមរយៈការអនុវត្តកន្លងមក យើងអាចនិយាយបានថា ស្ត្រីត្រូវបានគិតគូរច្រើនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្ត្រីក្នុងជួរថ្នាក់ដឹកនាំតាមរយៈការអប់រំជាបណ្តើរៗ និងការបង្ក្រាបបញ្ហាយេនឌ័រទៅលើគ្រប់វិស័យ យើងឃើញថាមានសំឡេងស្ត្រីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តមានការកើនឡើងគួរឱ្យកត់សម្គាល់ ស្ត្រីត្រូវទទួលសេវាសាធារណៈប្រកបដោយសមធម៌។ ទន្ទឹមនឹងការរីកចម្រើនក្នុងវិស័យនេះផងដែរ ក៏មានបញ្ហាប្រឈមមួយចំនួនដូចជា ស្ត្រីនៅមានការទទួលបន្ទុកកិច្ចការផ្ទះច្រើនជាងបុរស ស្ត្រីនៅមានការលំបាកជាងបុរស និងស្វែងរកការងារធ្វើឆ្ងាយពីផ្ទះ។ ជាងនេះទៅទៀតបញ្ហាប្រឈមផ្នែកយេនឌ័រក្នុងសង្គមនាពេលបច្ចុប្បន្នមានអំពើហិង្សាក្នុងគ្រួសារ កុមារបោះបង់ការសិក្សា ស្ត្រីមេម៉ាយ ក្មេងកំព្រា ការរើសអើងអ្នកមានផ្ទុកមេរោគអេដស៍ សកម្មភាពទាំងអស់នេះហើយដែលត្រូវទាមទារឱ្យមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ និងដៃគូសហការអភិវឌ្ឍឃុំនានាក្នុងការគាំទ្រដល់កិច្ចអភិវឌ្ឍឃុំ ដើម្បីធានាឱ្យបានការគ្រប់គ្រងឃុំប្រកបទៅដោយស្ថិរភាពនិងនិរន្តរភាព។

## ៣.១.៣. ស្ថានភាពនៃការគ្រប់គ្រងធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

នៅក្នុងភូមិសាស្ត្រឃុំមានព្រៃឈើធ្វើអុសដុតច្រើនបង្គួរដែលស្ថិតនៅតាមទីទួលនីមួយៗ ឬតាមភ្លឺស្រែ សម្រាប់ឱ្យប្រជាពលរដ្ឋដោះស្រាយក្នុងការធ្វើអុសដុតបានមួយចំណែកធំ។ នៅតាមលំនៅដ្ឋាននីមួយៗប្រជាពលរដ្ឋបានដាំដុះឈើហូបផ្លែ ដើម្បីយកផលមកទុកបរិភោគ និងលក់ដូរបានខ្លះ ដែលបង្កលក្ខណៈឱ្យភូមិទៅជាភូមិពណ៌បៃតង។ ជាអំណោយផលពីធម្មជាតិផងដែរ ឃុំមានអូរមួយលាតសន្ធឹងតាមព្រំប្រទល់ផ្នែកខាងលិច ដែលផ្តល់ផលប្រយោជន៍នូវទឹកស្រោចស្រពដល់ដំណាំកសិកម្មបានមួយភាគ ហើយក៏ជាជម្រកត្រីសម្រាប់ឱ្យប្រជាពលរដ្ឋធ្វើនេសាទយកមកផ្គត់ផ្គង់ជីវភាពបានមួយកម្រិតផងដែរ ។

ទន្ទឹមនឹងចំណុចខ្លាំងខាងលើ ឃុំក៏មានការជួបនូវភាពលំបាកមួយចំនួនដែរដូចជា មានការកាប់បំផ្លាញព្រៃឈើដោយអនាធិបតេយ្យ ខ្វះការថែរក្សា និងដាំបន្ថែមទាំងឈើសម្រាប់ធ្វើអុសក៏ដូចជាឈើហូបផ្លែ។ ចំណែកអូរប្រឡាយកាន់តែរាក់ អស់ព្រៃលិចទឹក មច្ឆាជាតិថយចុះ នូវរដូវប្រាំងអូររីងស្ងួតហួតហែងខ្វះទឹកប្រើប្រាស់រាល់ស្ទើររាល់ឆ្នាំបង្កឱ្យធម្មជាតិស្ថិតស្រពោន ។

### ៣.១.៣.១. ការប្រើប្រាស់ដីធ្លី

ស្ថានភាពនៃការប្រើប្រាស់ដីធ្លីយើងមានដីលំនៅដ្ឋាន ដីស្រែ ដីចម្ការ ដីព្រៃក សម្រាប់ប្រើប្រាស់ធ្វើស្រូវ ដំណាំរួមផ្សំ និងជីវៈចម្រុះ មិនតែប៉ុណ្ណោះវាបម្រើ និងជួយដល់ការរស់រានមានជីវិតរបស់មនុស្សសត្វទៀតផង។ ការអនុវត្តកន្លងមកក្នុងការប្រើប្រាស់ដីទាំងនេះ មិនទាន់អាចទាញយកផលតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយ ដោយសារជួបប្រទះនូវបញ្ហាមួយចំនួនដូចជា ការសាងសង់លំនៅដ្ឋាននៅមានភាពអនាធិបតេយ្យ ដីស្រែចម្ការខ្វះជីវជាតិ ប្រព័ន្ធធារាសាស្ត្រមិនអាចប្រើប្រាស់បាន បឹងព្រៃករាក់ជួបប្រទះភាពរាំងស្ងួត និងទឹកជំនន់នៅរដូវវស្សា។ មិនតែប៉ុណ្ណោះភាពអនាធិបតេយ្យរបស់ប្រជាពលរដ្ឋក្នុងការកាន់កាប់លើដីសាធារណៈ ការផ្តល់ដីសម្បទានសង្គមកិច្ច និងការបង្កើនលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងមិនមានផែនការប្រើប្រាស់ដីធ្លី ធ្វើឱ្យការប្រើប្រាស់ដីទាំងនោះមិនចំគោលដៅ។ ម៉្យាងវិញទៀត ទោះបីជារដ្ឋផ្តល់ដីឱ្យពួកគាត់ដែលទទួលបានការចុះបញ្ជីដីធ្លីរួចដោយមន្ទីរសុរិយោដីក្រុង ស្រុក ខណ្ឌ ក្រោមការត្រួតពិនិត្យរបស់ក្រសួងដែនដីនគររូបនីកម្ម និងសំណង់ក៏ដោយ យើងសង្កេតឃើញថាបញ្ហាទំនាស់ដីធ្លីតែងតែកើតមានឡើងជាញឹកញាប់រវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ឬរវាងប្រជាពលរដ្ឋ និងរដ្ឋ។

### ៣.១.៣.២ ធនធានធម្មជាតិ

ថ្វីត្បិតតែភូមិសាស្ត្រមានតំបន់ខ្ពង់រាបភាគច្រើនក៏ពិតមែន ប៉ុន្តែការប្រើប្រាស់ធនធានទាំងនោះកំពុងជួបប្រទះបញ្ហាមួយចំនួនពាក់ព័ន្ធទៅនឹងការកកើតឡើងវិញ។ ដូច្នេះ ការទាញយកផលពីធម្មជាតិត្រូវតែគិតគូរពីការកកើតឡើងវិញ ហើយធ្វើការថែទាំឱ្យបានគង់វង្សជៀសវាងការប្រើប្រាស់យ៉ាងអនាធិបតេយ្យ ពោលគឺយើងត្រូវធ្វើការអភិរក្ស និងអភិវឌ្ឍឱ្យបានល្អប្រសើរដោយត្រូវដើរទន្ទឹមគ្នាមិនអាចខ្វះមួយណាបាន ជាពិសេសការអភិវឌ្ឍប្រកបដោយនិរន្តភាព និងចីរភាពក្នុងមូលដ្ឋានឃុំ។

### ៣.១.៣.៣. វិស័យបរិស្ថាន

ការអភិវឌ្ឍទាំងឡាយត្រូវឈរលើមូលដ្ឋានបរិយាកាសមួយអាចទទួលយកបានទាំងអស់គ្នា ពោលគឺអភិវឌ្ឍប្រកបទៅដោយចីរភាពនិរន្តភាពបរិស្ថាន។ ក្នុងករណីនេះទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការលើកគម្រោងអភិវឌ្ឍប្រចាំឆ្នាំកន្លងមករួមមាន ការបង្កើតសហគមន៍អភិរក្សព្រៃឈើ និងជួសជុលផ្លូវលំ ស្ពារប្រឡាយទឹក សុទ្ធតែគិតគូរដល់ផលប៉ះពាល់អវិជ្ជមានអំពីការអនុវត្តគម្រោងទាំងនោះ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅតែជៀសមិនផុតអំពីបញ្ហាប្រឈមទាំងនេះមានការហុយផ្សែងធូលី ការប៉ះពាល់ទឹក (ទឹកលើដី ទឹកក្រោមដី) ការបំពុលខ្យល់ ប្រជាពលរដ្ឋមួយចំនួនមិនទាន់មានការយល់ដឹងពីផលអវិជ្ជមាននៃការកាប់បំផ្លាញព្រៃឈើជាដើម។ល។

### ៣.១.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ក្នុងទីតាំងភូមិសាស្ត្រឃុំតាំងយ៉ាបពុំបានជួបប្រទះឧបសគ្គដូចជាគ្រោះមហន្តរាយពីធម្មជាតិ ប៉ះពាល់ដល់ជីវិតមនុស្ស សត្វ ដំណាំស្រូវ ផ្ទះសម្បែង និងសម្ភារៈសំខាន់ៗអ្វីឡើយ។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះគឺនៅរដូវភ្លៀងតែងតែមានខ្យល់កន្ត្រាក់ រន្ទះបាញ់ ដែលបង្កឱ្យមានការភ័យខ្លាច និងគួរឱ្យព្រួយបារម្ភពីសុវត្ថិភាពរបស់ប្រជាពលរដ្ឋ។

### ៣.១.៥. ស្ថានភាពគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ឃុំតាំងយ៉ាបមានអង្គភាពឃុំគឺក្រុមប្រឹក្សាឃុំសម្រាប់ដឹកនាំ គ្រប់គ្រង បំពេញភារកិច្ចជាអាជ្ញាធរដែនដីបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានបានតាមការកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ ដែលបានអនុម័តដោយរដ្ឋសភាពរួចរាល់ សំដៅអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនឱ្យមានភាពរីកចម្រើន។ នៅក្នុងមូលដ្ឋានឃុំតាំងយ៉ាបមានគ្រឹះស្ថានអប់រំគឺ សាលាបឋមសិក្សា និងវិទ្យាល័យ អនុវត្តលើវិស័យអប់រំបានល្អ បង្កលក្ខណៈឱ្យសិស្សានុសិស្សបានចូលរៀនគ្រប់ៗគ្នាដែលមានតាំងពីថ្នាក់មត្តេយ្យរហូតដល់មធ្យមសិក្សា។ យើងឃើញថាកុមារដែលមានអាយុពី៦ ដល់១៤ឆ្នាំបានចូលរៀន១០០ភាគរយ ។ នេះបញ្ជាក់ឱ្យឃើញថា ក្នុងមូលដ្ឋានមានការបណ្តុះបណ្តាលធនធានមនុស្សដែលជាទំពាំងស្នងឫស្សីនាពេលអនាគត។ ទន្ទឹមនោះឃុំតាំងយ៉ាបមានមណ្ឌលសុខភាព១កន្លែងសម្រាប់បម្រើសេវាសុខភាពជូនប្រជាពលរដ្ឋ។ មានប៉ុស្តិ៍នគរបាលសម្រាប់ការពារសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានបានយ៉ាងល្អគួរជាទីទុកចិត្តផងដែរ ។ យើងមានក្រុមប្រឹក្សាឃុំជាស្ត្រីទទួលបន្ទុកស្ត្រី និងកុមារសម្រាប់ជួយដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងស្ត្រី កុមារពេលជួបការលំបាកនានា ។

អ្វីជាបញ្ហានោះគឺឃុំមានក្រុមប្រឹក្សាដែលមានកម្រិតវប្បធម៌មិនស្មើគ្នា ការយល់ដឹងរបស់ពួកគាត់នូវមានកម្រិត ការបម្រើសេវាជូនប្រជាពលរដ្ឋនៅមានការខ្វះចន្លោះដោយសារការយល់ដឹងនៅមានកម្រិត។ សាលារៀនមានការខ្វះខាតសម្ភារៈបង្រៀន សិស្សនៅក្រៅសាលាពុំសូវបានរៀនសូត្រដោយសារការជួយធ្វើការងាររបស់ឪពុកម្តាយ និងដោយសារកត្តាជីវភាពខ្វះខាត។ មណ្ឌលសុខភាពមានការខ្វះខាត ថ្នាំសម្រាប់ព្យាបាលជំងឺជូនប្រជាពលរដ្ឋ

មន្ត្រីក្នុងមណ្ឌល ការទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងការផ្ដល់សេវាមិនទាន់ទទួលបាននូវទំនុកចិត្តពីសំណាក់ប្រជាពលរដ្ឋ។ ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសង្គមនៅមានកម្រិតដោយសារស្ត្រីខ្លួនឯងពុំទាន់មានភាពជឿជាក់លើសមត្ថភាពខ្លួននៅឡើយដោយហេតុថាស្ត្រីមានការងារច្រើនក្នុងគ្រួសារ។

## ៣.២. ដំណោះស្រាយ

### ៣.២.១. ពង្រឹងវិស័យសេដ្ឋកិច្ច

ដើម្បីសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍក្នុងផ្នែកសេដ្ឋកិច្ច ឃុំបានរៀបចំជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាគន្លឹះសំខាន់ៗដោយការគិតគូរគ្រប់ជ្រុងជ្រោយ និងថ្លឹងថ្លែងសមស្របជាមួយវិស័យនានាស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ច។ យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចមានដូចខាងក្រោម៖

#### ៣.២.១.១. វិស័យកសិកម្ម

ក្នុងឃុំតាំងយ៉ាប ប្រជាពលរដ្ឋភាគច្រើនត្រូវពឹងផ្អែកទៅលើការធ្វើស្រែចម្ការជាចម្បង ហើយមុខរបរធ្វើស្រែចម្ការនេះវាពិតជាមានសារៈសំខាន់សម្រាប់ចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះដើម្បីដោះស្រាយបញ្ហាក្នុងវិស័យកសិកម្ម ក្រុមប្រឹក្សាឃុំបានរៀបចំកែលម្អប្រព័ន្ធធារាសាស្ត្រ និងមធ្យោបាយស្រោចស្រពតាមរយៈការស្តារប្រឡាយឱ្យបានធំ និងជ្រៅជាងមុន ដើម្បីជួយសម្រួលដល់បញ្ហាកង្វះខាតទឹកធ្វើស្រែរបស់ប្រជាពលរដ្ឋ។ មួយវិញទៀតឃុំបានកែលម្អផលិតកម្មដំណាំស្រូវតាមរយៈការបណ្ដុះបណ្ដាលបច្ចេកទេស និងការប្រើប្រាស់ពូជក្នុងគោលបំណងពង្រីកការយល់ដឹងទៅកាន់ប្រជាពលរដ្ឋឱ្យបានស្វែងយល់កាន់តែច្បាស់ទាក់ទងនឹងការធ្វើឱ្យទទួលបានទិន្នផលខ្ពស់។ ពិសេសជាងនេះឃុំបានធ្វើការកែលម្អការប្រើប្រាស់ដីកសិកម្មដូចជា របៀបធ្វើឱ្យដីមានជីជាតិល្អតាមបែបធម្មជាតិ និងការបង្កើនចំនួនដងនៃការបង្កបង្កើនផលជាដើម។[56]

#### ៣.២.១.២. ផ្នែកធារាសាស្ត្រ

ជាការពិតណាស់ ទឹកគឺជាធនធានដ៏សំខាន់សម្រាប់ជីវិតភាវរស់ទាំងអស់នៅលើផែនដី យ៉ាងណាមិញចំពោះរបរកសិកម្មគេក៏ត្រូវការទឹកជាចាំបាច់ផងដែរសម្រាប់ស្រោចស្រពលើដំណាំព្រោះថា កាលណាគ្មានទឹកនោះដំណាំនឹងមិនអាចរស់រានមានជីវិតបានឡើយ។ ស្របជាមួយបញ្ហាកង្វះខាតទឹកប្រើប្រាស់ក្នុងការងារស្រែចម្ការដោយសារប្រឡាយទឹកមានទំហំតូច និងរាក់មិនអាចស្តុកទឹកបានគ្រប់គ្រាន់។ ដូច្នេះឃុំតាំងយ៉ាបបានដាក់ចេញនូវយុទ្ធសាស្ត្រកែលម្អប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធស្រោចស្រពដែលមានទីតាំងនៅតាមភូមិនានាដូចជាការស្តារប្រឡាយ សង់សំណង់ទ្វារទឹក រៀបចំបង្កើត និងពង្រឹងសមត្ថភាពសហគមន៍ក្នុងការប្រើប្រាស់ទឹក ជួយដឹកនាំដល់កសិករប្រើប្រាស់បានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសជាពិសេសគឺត្រូវមានសម្ភារៈ និងមធ្យោបាយសម្រាប់ជួយអន្តរាគមន៍នៅពេលរដូវប្រាំងរាំងស្ងួតហួតហែងម្តងៗ។

[56] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៨

**៣.២.១.៤. ផ្នែកគមនាគមន៍**

ប្រព័ន្ធគមនាគមន៍ ជាផ្នែកមួយយ៉ាងសំខាន់ពុំអាចខ្វះបាន ហើយវាប្រៀបដូចជាសរសៃឈាមនៃចរន្តសេដ្ឋកិច្ច ដែលផ្សារភ្ជាប់ទៅគ្រប់ច្រកល្ហកទាំងអស់នៅទូទាំងប្រទេសសម្រាប់ជួយសម្រួលដល់មធ្យោបាយដឹកជញ្ជូនទំនិញគ្រប់ប្រភេទទៅកាន់ទីផ្សារ ព្រមទាំងផ្តល់ជូនប្រជាពលរដ្ឋនូវការធ្វើដំណើរសម្រាប់ការទំនាក់ទំនងក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ដើម្បីជាការអភិវឌ្ឍលើវិស័យគមនាគមន៍ ឃុំតាំងយ៉ាបបានដាក់ចេញនូវយុទ្ធសាស្ត្រកែលម្អរចនាសម្ព័ន្ធក្នុងឃុំតាមរយៈការជួសជុលផ្លូវ ការថែទាំ ការពង្រីកផ្លូវ រៀបចំប្រព័ន្ធលូ និងរីហ្គាបង្ហូរទឹក ព្រមទាំងធ្វើការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកពាក់ព័ន្ធនឹងការដឹកទំនិញលើសទម្ងន់ជាដើម។ ជាក់ស្តែងក្នុងនីតិកាលទី៥ កាលពីអំឡុងឆ្នាំ២០២៣កន្លងទៅ ឃុំតាំងយ៉ាបបានស្ថាបនាផ្លូវបេតុងអាមេមួយខ្សែស្ថិតនៅក្នុងភូមិព្រៃចំបក់ មានប្រវែង៩៣៤ម៉ែត្រ ដោយចំណាយទឹកប្រាក់ចំនួន ២៦៨ ១៤១ ១៧៧រៀល។ ក្នុងឆ្នាំជាមួយគ្នានេះដែរ ក៏មានការក្រាលកំទេចថ្មM30ក្នុងភូមិត្រពាំងស្គុក និងភូមិរលួស ប្រវែង១ ៤៩០ម៉ែត្រ ព្រមទាំងដាក់លូ២កន្លែង ដោយចំណាយទឹកប្រាក់សរុបរហូតដល់ ៨៦ ១០៥ ២៦៣រៀល។[57]

**៣.២.១.៥. ផ្នែកសេវាកម្ម**

ដើម្បីលើកកម្ពស់ផ្នែកសេវាកម្មឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំបានរៀបចំអនុវត្តនូវវិធានការ និងសកម្មភាពមួយចំនួនក្នុងការជួយកាត់បន្ថយបញ្ហាលំបាកដូចជា ការពង្រឹងទីផ្សារ ពង្រឹងបណ្តាញផ្គត់ផ្គង់អគ្គីសនី និងប្រព័ន្ធទឹកស្អាតបន្ថែមនៅតាមភូមិទាំងអស់ឱ្យបានគ្រប់គ្រាន់ និងប្រើប្រាស់នៅតាមទីប្រជុំជន និងទីកន្លែងសំខាន់ៗផ្សេងៗទៀត។[58]

**៣.២.២. ពង្រឹងវិស័យសង្គមកិច្ច**

**៣.២.២.១. វិស័យអប់រំ**

វិស័យអប់រំ គឺជាវិស័យមួយដែលជួយពង្រឹងការអប់រំនៅក្នុងមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការនៃការសិក្សារបស់សិស្សានុសិស្សក្នុងការរៀនសូត្រ និងដើម្បីអភិវឌ្ឍខ្លួនឱ្យក្លាយទៅជាមនុស្សដែលមានសមត្ថភាពដែលសង្គមត្រូវការ។ ក្នុងឃុំតាំងយ៉ាប អត្រានៃការអប់រំកុមារមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់ កុមារដែលមានអាយុចាប់ពី៣ដល់៥ឆ្នាំបានចូលរៀនចំនួន៧៥% កុមារពីអាយុ៦ឆ្នាំដល់១១ឆ្នាំបានចូលរៀនចំនួន១00% កុមារអាយុ១២ឆ្នាំដល់១៤ឆ្នាំបានចូលរៀន១00% អ្នកចេះអក្សរអាយុពី១៥ដល់១៧ឆ្នាំមានចំនួន១00% អ្នកចេះអក្សរអាយុពី១៨ដល់៤៥ឆ្នាំមានចំនួន៩៩%។[59]

[57] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៨

[58] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៨

[59] តារាងសង្ខេបទិន្នន័យចម្បងរបស់ឃុំតាំងយ៉ាប ឆ្នាំ២០២៣

អាជ្ញាធរមូលដ្ឋានថ្នាក់ឃុំត្រូវបានសហការគ្នាជាមួយមន្ទីរអប់រំស្រុក ដែលចំណុះឱ្យមន្ទីរអប់រំខេត្តដែលខ្លួនកាន់កាប់ដើម្បីស្វែងរកបញ្ហា នឹងឆ្លើយតបទៅតាមតម្រូវការទីផ្សារពលកម្មការងារ យើងបានគិតគូរទៅលើចំណុចសកម្មភាពសំខាន់ៗសម្រាប់អនុវត្តដូចជា បង្កើនការប្រមូលកុមារចូលរៀនថ្នាក់មត្តេយ្យ និងថ្នាក់បឋម។ បង្កើនការអប់រំចំណេះដឹងទូទៅ អប់រំក្រៅប្រព័ន្ធ និងថ្នាក់អក្ខរកម្ម។ រៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីជាភាពងាយស្រួលដល់សិស្សានុសិស្សធ្វើដំណើរទៅសាលា។ ជាពិសេសគឺការកែលម្អអាគារសិក្សា ទីចាត់ការ បណ្ណាល័យ និងបំពាក់ឧបករណ៍សម្ភារៈ ជាពិសេសគឺបង្កើនការដឹកនាំគ្រប់គ្រងដល់មន្ត្រីអប់រំ។[60]

**៣.២.២.២. វិស័យសុខាភិបាល**

ការថែទាំសេវាសុខាភិបាល និងការលើកកម្ពស់ផ្នែកសុខភាពវាពិតជាមានសារៈសំខាន់ណាស់ចំពោះប្រជាពលរដ្ឋនៅក្នុងឃុំសម្រាប់សម្រាកព្យាបាលពេលមានជំងឺផ្សេងៗ។ ជាក់ស្តែងចំពោះសេវាសុខាភិបាល អាជ្ញាធរមូលដ្ឋានត្រូវតែខិតខំប្រឹងប្រែង និងស្វែងរកដំណោះស្រាយ ព្រមទាំងសហការគ្នាជាមួយមន្ទីរសុខាភិបាលខេត្ត ដែលចំណុះឱ្យក្រសួងសុខាភិបាលដើម្បីជំរុញ និងបង្កើតឱ្យមានមណ្ឌលសុខភាពមួយសម្រាប់ឃុំ ងាយស្រួលដល់ប្រជាពលរដ្ឋត្រូវការផ្នែកសេវាថែទាំសុខភាព មិនចាំបាច់ទៅទទួលសេវាកម្មក្នុងឃុំផ្សេងៗដែលធ្វើឱ្យខាតពេលវេលាពិបាកធ្វើដំណើរទៅមក។ យើងត្រូវយកចិត្តទុកដាក់បំផុត និងជាអាទិភាពទៀតផងព្រោះបើគ្មានសុខភាពល្អ គឺគ្មានអ្វីៗទាំងអស់ហេតុនេះឃុំបានកំណត់ចេញជាយុទ្ធសាស្ត្របន្ថែមទៀតមានដូចជា ការបង្កើនការផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឱ្យមកពិនិត្យផ្ទៃពោះ និងទទួលបានថ្នាំជាតិដែក។ បង្កើនការផ្សព្វផ្សាយ និងពង្រឹងវិធានការការពារចំពោះជំងឺឆ្លងគ្រប់ប្រភេទ។ មួយវិញទៀតគឺការបង្កើនការចាក់វ៉ាក់សាំងការពារជំងឺឆ្លងផ្សេងៗដល់កុមារតូច។[61]

**៣.២.២.៣. ផ្នែកយេនឌ័រ**

ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនការយល់ដឹងអំពីយេនឌ័រ បច្ចុប្បន្នយើងសង្កេតឃើញថាស្ត្រីមិនត្រឹមតែទទួលបន្ទុកថែទាំគ្រួសារប៉ុណ្ណោះទេ តែថែមទាំងបានរួមចំណែកជាច្រើនក្នុងការកសាង និងអភិវឌ្ឍសង្គមជាតិផងដែរទាំងផ្នែកនយោបាយ ការងារសង្គម និងសេដ្ឋកិច្ច ដោយសារស្ត្រីមានប្រាជ្ញាស្មារតី និងតស៊ូអត់ធ្មត់ក្នុងការដោះស្រាយបញ្ហាបានគ្រប់កាលៈទេសៈទាំងអស់។ ជាការពិតណាស់ ឃុំតាំងយ៉ាបបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះផ្នែកយេនឌ័រ ហើយក្រុមប្រឹក្សាឃុំបានបង្កើតឱ្យមានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ដោយមានសមាជិកក្រុមប្រឹក្សាឃុំម្នាក់ជាស្ត្រីផងដែរ។ លើសពីនេះទៅទៀតឃុំបានពង្រឹងដល់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ មន្ត្រីទទួលបន្ទុកសេវាសង្គម និងបានជួយគាំទ្រដល់សកម្មភាពស្ត្រី និងកុមារ

[60] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៨

[61] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៨

ការចុះសំបុត្រកំណើត អំពីសុខភាពអនាម័យ តម្លៃស្ត្រី និងគ្រួសារខ្មែរក្នុងការលើកកម្ពស់សីលធម៌ ជាពិសេសវិធានការអប់រំ និងដាក់ពិន័យដល់ជនបង្កហិង្សាមានស្ថានទម្ងន់ទោសក្នុងបទល្មើសមជ្ឈិម ឬបទឧក្រិដ្ឋ។[62]

### ៣.២.៣. ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

#### ៣.២.៣.១. ការប្រើប្រាស់ដីធ្លី

ដើម្បីការពារ និងការប្រើប្រាស់ដីធ្លីឱ្យបានស្របច្បាប់ យើងត្រូវដោះស្រាយជាបន្ទាន់ទៅលើបញ្ហាទាំងអស់នេះទៅតាមគោលការណ៍ណែនាំអំពីការរៀបចំកែលម្អសម្រាប់ជាមូលដ្ឋានគតិយុត្តក្នុងការដោះស្រាយទំនាស់ដីធ្លី។ នៅក្នុងន័យនេះក្រុមប្រឹក្សាឃុំបានផ្តោតយ៉ាងសំខាន់ទៅលើប្រព័ន្ធនៃការគ្រប់គ្រងការប្រើប្រាស់ដីធ្លីធានាឱ្យបាននូវសុវត្ថិភាពជូនប្រជាពលរដ្ឋ លើកគម្រោងកំណត់បោះបង្គោលព្រំប្រទល់ឱ្យបានច្បាស់លាស់ ចុះបញ្ជីដីធ្លីចេញប័ណ្ណកម្មសិទ្ធិលក្ខណៈជាប្រព័ន្ធ និងដាច់ ដោយរៀបចំប្លង់គោលសម្រាប់ប្រើប្រាស់ដីធ្លី និងផ្សព្វផ្សាយច្បាប់ភូមិបាល។ បង្កើតការខិតខំដោះស្រាយវិវាទដីធ្លី លុបបំបាត់អ្នកកាន់កាប់ដីអនាធិបតេយ្យដែលកើតមានដើម្បីឱ្យប្រជាពលរដ្ឋប្រកបរបរ និងមានប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីច្បាស់លាស់សម្រាប់ប្រើប្រាស់តាមតម្រូវការ។[63]

#### ៣.២.៣.២. ធនធានធម្មជាតិ

ឃុំតាំងយ៉ាប ជាឃុំមួយដែលអំណោយផលដល់ផ្នែកធនធានធម្មជាតិជាច្រើនដែលហ៊ុំព័ទ្ធដោយបរិស្ថានប្រឡាយ អូរ សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់អាស្រ័យផលទៅតាមតម្រូវការចាំបាច់ដូចជាស្រោចស្រពស្រែចម្ការដំណាំដាំដុះជាដើម។ ក្រុមប្រឹក្សាឃុំត្រូវតែពង្រឹងរក្សាការពារធនធានធម្មជាតិ និងធ្វើការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់ដឹង និងចេះថែរក្សាដូចជា ត្រូវបង្កើតឱ្យមានសហគមន៍សម្រាប់ដឹកនាំប្រជាពលរដ្ឋ បង្កើនការដាំដើមឈើរក្សាការពារមិនឱ្យមានភ្លើងឆេះព្រៃ ជៀសវាងកាប់គាស់រានព្រៃ និងលុបបំបាត់ការនេសាទខុសច្បាប់ក្នុងរដូវត្រីពង។[64]

#### ៣.២.៣.៣. វិស័យបរិស្ថាន

សម្រាប់វិស័យបរិស្ថានវិញក៏ជាផ្នែកមួយយ៉ាងសំខាន់ផងដែរ ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋគ្រប់រូបដើម្បីទទួលបាននូវផាសុកភាព និងសុខុមាលភាពក្នុងក្រុមគ្រួសារ។ ឃុំបានដាក់ចេញនូវគោលការណ៍ផ្សព្វផ្សាយច្បាប់ស្តីពីការបំពុលបរិស្ថានដល់ប្រជាពលរដ្ឋ និងផ្សព្វផ្សាយដល់ពួកគាត់ទាក់ទងនឹងការយកកាកសំណល់ទៅចោលដល់ទីលានទុកដាក់សំរាមឱ្យបានត្រឹមត្រូវជាដើម។[65]

[62] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៩

[63] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៩

[64] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៩

[65] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៩

### ៣.២.៤. ពង្រឹងការគ្រប់គ្រងគ្រោះមហន្តរាយ

ដើម្បីជាការពង្រឹងការគ្រប់គ្រងគ្រោះមហន្តរាយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ឃុំតាំងយ៉ាប បានបង្កើនការការពារ និងការដាំកូនឈើឡើងវិញ សម្រាប់ទុកជារនាំងបាំងនូវខ្យល់ព្យុះនារដូវធ្លាក់ភ្លៀងក្នុង គោលបំណងបញ្ចៀសនូវរាល់បញ្ហាទាំងឡាយដែលអាចកើតមានមកលើប្រជាពលរដ្ឋដូចជាការបាក់រលំផ្ទះ និង ការខូចខាតដំណាំជាដើម។ ម្យ៉ាងវិញទៀតដើមឈើក៏បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនទៀតផងដែរដូចជាការ ផ្តល់ម្លប់ ជួយស្រូបយកឧស្ម័នកាបូនិច បង្កើតឧស្ម័នអុកស៊ីសែន ការពារគ្រោះទឹកជំនន់ ជួយទប់ស្កាត់ការប្រែប្រួល អាកាសធាតុ និងធ្វើឱ្យមានភាពស្រស់ស្អាតបែបធម្មជាតិបៃតងជាដើម។ល។ លើសពីនេះឃុំបានបង្កើនការស្តារ ប្រឡាយ និងបឹងធម្មជាតិដើម្បីសម្រួលដល់បញ្ហាកង្វះខាតទឹកសម្រាប់ប្រើប្រាស់របស់ប្រជាពលរដ្ឋនៅរដូវប្រាំង។[66]

### ៣.២.៥. បង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍ ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានលក្ខណៈល្អប្រសើរ ឃុំបានរៀបចំជាយុទ្ធសាស្ត្រអភិវឌ្ឍជាគន្លឹះសំខាន់ៗដោយមានការគិតគូរគ្រប់ជ្រុងជ្រោយ និងថ្លឹងថ្លែងសមស្របជាមួយផ្នែកនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈដែលបានរៀបរាប់ ក្នុងជំពូកទី១។ យុទ្ធសាស្ត្រអភិវឌ្ឍលើការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនេះមានដូច ខាងក្រោម៖

**ការគ្រប់គ្រងរដ្ឋបាល៖** សម្រាប់ការគ្រប់គ្រងរដ្ឋបាល ឃុំបានបង្កើនការយកចិត្តទុកដាក់ក្នុងការចុះបញ្ជី អត្រានុកូដ្ឋានដល់ប្រជាពលរដ្ឋ។ ពង្រឹងដល់ការងារធ្វើលិខិតបទដ្ឋានគតិយុត្ត និងថែរក្សាឱ្យបានគង់វង្ស។ ពង្រឹង និងពង្រីកប្រព័ន្ធព័ត៌មានវិទ្យា បង្កើនការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហា និងទំនាស់នានាជូនប្រជាពលរដ្ឋ។

**សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ៖** ឃុំបានបង្កើនការគ្រប់គ្រងមុខសញ្ញាគ្រប់ប្រភេទ។ បង្កើនការ គ្រប់គ្រងអាវុធជាតិផ្ទុះ គ្រឿងញៀន និងក្មេងទំនើង។ ពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព។ ជាពិសេសឃុំតាំងយ៉ាប បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តតាមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព មានដូចខាងក្រោម៖

១. ការផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបាន ជំនឿទុកចិត្ត
២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍
៤. គ្មានអំពើអានាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មាន ក្មេងទំនើង

[66] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ,៩

៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព

៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ

៧.ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។[67]

ការអនុវត្តបាននូវវិធានការគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពទាំង៧ចំណុចនេះហើយជាហេតុដែលនាំឱ្យការគ្រប់គ្រងនៅក្នុងឃុំតាំងយ៉ាបមានការអភិវឌ្ឍប្រកបដោយសុខសន្តិភាពរបៀបរៀបរយសណ្តាប់ធ្នាប់សាធាណៈ និងមានអភិបាលកិច្ចល្អសម្រាប់ប្រជាជនរស់ក្នុងមូលដ្ឋានទទួលបាននូវសេចក្តីសុខ និងសេចក្តីចម្រើនក្នុងគ្រួសារ។

## ៣.៣. ទិសដៅនាពេលអនាគត

ការងារតាមវិស័យក្នុងឃុំតាំងយ៉ាប ផ្អែកតាមផែនការអភិវឌ្ឍឃុំបានសម្រេចលទ្ធផលវិជ្ជមានមួយចំនួនសំខាន់ជាងគេគឺផ្លូវថ្នល់ និងធារាសាស្ត្រ ក្រៅពីនោះរួមមានការចុះសំបុត្រអត្រានុកូលដ្ឋាន ការដោះស្រាយទំនាស់ក្នុងគ្រួសារ ការទទួលបានមូលនិធិសប្បុរសជន និងអង្គការសង្គមស៊ីវិលកន្លងមកសម្រាប់បម្រើលើវិស័យកសិកម្ម សុខាភិបាល និងអនាម័យជាដើម។ ប៉ុន្តែទន្ទឹមនឹងនោះការងារមួយចំនួនក៏ពុំបានសម្រេចជាដុំកំភួននៅឡើយ ជាពិសេសគឺបញ្ហាបរិស្ថាន បញ្ហាសន្តិសុខ និងបញ្ហាធនធានមនុស្ស។

ក្នុងទិសដៅជំរុញការផ្តល់សេវាសាធារណៈរបស់ឃុំ រួមទាំងការអភិវឌ្ឍឱ្យមានភាពល្អប្រសើរទៅថ្ងៃអនាគត អាជ្ញាធរឃុំ ព្រមទាំងអាជ្ញាធររដ្ឋបាលថ្នាក់ជាតិ និងស្ថាប័នពាក់ព័ន្ធគួរពិចារណាលើចំណុច៣ពិសេសរួមមាន៖ ទី១.ការបណ្តុះបណ្តាលធនធានមនុស្ស ទី២.ការបង្កើនថវិកាឃុំ និងទី៣.ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ។

### ៣.៣.១. ការបណ្តុះបណ្តាលធនធានមនុស្ស

បច្ចុប្បន្ន ថ្វីត្បិតតែយើងត្រូវការការគ្រប់គ្រងមូលដ្ឋានដោយតំណាងដែលកើតឡើងពីសំឡេងគាំទ្ររបស់ប្រជាពលរដ្ឋដើម្បីសបញ្ជាក់ពីប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានក៏ពិតមែន ប៉ុន្តែបុគ្គលដែលត្រូវបានជ្រើសរើសទាំងនេះពុំទាន់មានសមត្ថភាពពេញលេញក្នុងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងដែនដីរបស់ខ្លួននៅឡើយ។ ជាក់ស្តែងអ្នកឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ច្បាប់ពុំចាំបាច់តម្រូវឱ្យជននោះមានចំណេះដឹងកម្រិតសញ្ញាបត្រខ្ពង់ខ្ពស់នោះទេ យ៉ាងហោចណាស់ត្រឹមអាចអាន និងសរសេរភាសាខ្មែរបានគឺគ្រប់គ្រាន់។ ដូច្នេះ ជាទិសដៅខ្លីទៅមុខរដ្ឋបាលថ្នាក់ជាតិដែលមានក្រសួងមហាផ្ទៃជាអ្នកដឹកនាំការងារនេះគួរបើកវគ្គបណ្តុះបណ្តាលសមត្ថភាពដល់ក្រុមប្រឹក្សាឃុំលើការប្រមូលចំណូល និងគ្រប់គ្រងចំណាយ ការរៀបចំបញ្ជីសារពើភណ្ឌ ការរៀបចំគម្រោងថវិកា គម្រោងអភិវឌ្ឍន៍ គម្រោងវិនិយោគប្រចាំឆ្នាំជាដើម។ល។ រីឯទិសដៅរយៈពេលវែងវិញ គឺធ្វើការកែប្រែ

[67] គោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

ច្បាប់ដោយកំណត់លក្ខខណ្ឌតម្រូវបេក្ខជនឈរឈ្មោះជាក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានសញ្ញាបត្រអាចត្រឹមមធ្យមសិក្សាទុតិយភូមិ ឬអាចទៅដល់សញ្ញាបត្របរិញ្ញាបត្រដែលមានជំនាញពាក់ព័ន្ធនឹងរដ្ឋបាលសាធារណៈ សេដ្ឋកិច្ច និងការទូតជាដើម។

### ៣.៣.២. ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ

ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តទៅតាមគោលនយោបាយវិមជ្ឈការ មានន័យថាឃុំ សង្កាត់ទទួលបាននូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងការចាត់ចែងការងារនៅមូលដ្ឋានឃុំ តែមានលក្ខណៈមួយគឺផ្តល់ផលប្រយោជន៍ដែលប្រជាពលរដ្ឋត្រូវការដែលជាគោលការណ៍របស់ថ្នាក់ជាតិបានដាក់គោលដៅដើម្បីផ្តល់ការងាយស្រួល និងនាំប្រយោជន៍សម្រាប់ជាតិទាំងមូល។ ប៉ុន្តែ បើតាមភាពជាក់ស្តែងយើងសង្កេតឃើញថាភាពជាម្ចាស់ និងការទទួលខុសត្រូវទាំងនេះហាក់នៅមានកម្រិតនៅឡើយដោយហេតុថាឃុំ សង្កាត់ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបន្ទុកលើការងាររបស់ខ្លួនបូករួមទាំងភាពស្ទាក់ស្ទើរនៃការផ្ទេរវិមជ្ឈការអំណាចពីថ្នាក់ជាតិ។ ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងធ្វើឱ្យការផ្តល់សេវាសាធារណៈនៅថ្នាក់ឃុំ សង្កាត់កាន់តែមានភាពល្អប្រសើរ។ ដូច្នេះ សម្រាប់ជាមធ្យោបាយនាពេលអនាគតដ៏ប្រសើរក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចេះពង្រឹងសមត្ថភាពរបស់ខ្លួនតាមរយៈការសិក្សាស្វែងយល់ពីច្បាប់ និងលិខិតបទដ្ឋាននានាដើម្បីបង្ហាញពីសមត្ថភាពនៃការទទួលខុសត្រូវផ្នែករដ្ឋបាលចំពោះការងាររបស់ខ្លួន។ ជាមួយគ្នានេះផងដែរ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ក៏ត្រូវជំរុញយន្តការនៃការបែងចែកភារកិច្ចជាក់លាក់រវាងរដ្ឋបាលថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដើម្បីកំណត់ឱ្យកាន់តែច្បាស់អំពីភាពជាម្ចាស់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័ននៅថ្នាក់ជាតិគួរធ្វើកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ក្នុងការផ្ទេរភារកិច្ចក្នុងកម្រិតណាមួយលើក្រុមប្រឹក្សាឃុំ សង្កាត់នៅវិស័យដែលជាប់ពាក់ព័ន្ធផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋដូចជាវិស័យកសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល និងវិស័យសង្គមកិច្ចជាដើម ដើម្បីឱ្យឃុំ សង្កាត់អាចផ្តល់នូវសេវាទាំងនោះប្រកបដោយការទទួលខុសត្រូវនៅក្នុងមូលដ្ឋានរបស់ខ្លួន។

### ៣.៣.៣. ការបង្កើនថវិកាឃុំ

យោងតាមអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា២០ បានចែងថា ឃុំ សង្កាត់មានប្រភពធនធានមកពីភូមិទាំងអស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ឃុំ សង្កាត់ផ្សេងៗ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល ជំនួយឥតសំណងពីអង្គការជាតិ អន្តរជាតិ និងអង្គការនានានៅមូលដ្ឋាន ផ្នែកឯកជន និងសប្បុរសជននានាជាដើម។ ថ្វីត្បិតមើលទៅប្រភពធនធានរបស់ឃុំ សង្កាត់ហាក់ដូចជាច្រើនប៉ុន្តែបើតាមការជាក់ស្តែងចំណូលថវិការបស់ឃុំ សង្កាត់

ជាទូទៅបានមកពីការឧបត្ថម្ភធនធានពីរាជរដ្ឋាភិបាល និងកម្រៃសេវារដ្ឋបាលផ្សេងៗដូចជាការងារអត្រានុកូលដ្ឋាន និងការចេញលិខិតអនុញ្ញាតនានាដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ។ បច្ចុប្បន្នថវិការបស់ឃុំ សង្កាត់អាចត្រឹមតែធានាបានពីប្រក្រតីភាពនៃដំណើរការរដ្ឋបាលរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែនៅពុំទាន់អាចឆ្លើយតបចំពោះកិច្ចការអភិវឌ្ឍនៅមូលដ្ឋានឱ្យបានពេញលេញនៅឡើយទេព្រោះតម្រូវការអភិវឌ្ឍន៍របស់ប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងការស្តារ និងកសាងប្រឡាយទឹក និងជួសជុលផ្លូវ ស្ពាន ត្រូវចំណាយថវិកាខ្ពស់ហួសពីសមត្ថភាពជាក់ស្តែងរបស់ឃុំ សង្កាត់ទៅទៀត។ ដូច្នេះដើម្បីអាចធានាបានពីការអភិវឌ្ឍឱ្យបានពេញលេញនៅថ្នាក់មូលដ្ឋាន រាជរដ្ឋាភិបាលគួរពិនិត្យលទ្ធភាពក្នុងការបង្កើនថវិកាបន្ថែមសម្រាប់ឃុំ សង្កាត់ទោះជាផ្តល់ក្នុងរូបភាពឧបត្ថម្ភធនធាន និងការផ្តល់ជំនួយលើគម្រោងនានាក្តី ។

សរុបជារួមមក ទន្ទឹមនឹងការរីកចម្រើនរុងរឿងរបស់ឃុំតាំងយ៉ាបក្នុងការគ្រប់គ្រង ដឹកនាំ និងការអភិវឌ្ឍ ឃុំនៅមានបញ្ហាច្រើនណាស់ទាំងលើផ្នែកសំខាន់ៗដូចជា ផ្នែកអប់រំ កសិកម្ម គមនាគមន៍ ទឹកស្អាត ថាមពល សុខាភិបាល បញ្ហាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ បញ្ហាគ្រឿងញៀនដែលជាឧបសគ្គសម្រាប់ឃុំ និងការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតជាដើម ហើយទាំងអស់នេះសុទ្ធសឹងតែជាបញ្ហាដែលធ្វើឱ្យបញ្ហាទាំងនោះរីករាលដាលក្លាយទៅជាគ្រឿងរាំងខ្ទប់ដល់ដំណើរការអភិវឌ្ឍរបស់ឃុំ។ ហេតុដូចនេះហើយទើបបានជាអាជ្ញាធរឃុំតាំងយ៉ាបគ្រប់លំដាប់ថ្នាក់កំពុងខិតខំប្រឹងប្រែងខ្នះខ្នែងព្យាយាមទប់ស្កាត់ស្វែងរកដំណោះស្រាយដោយបានចុះទៅធ្វើអង្គប្រជុំផ្សព្វផ្សាយបញ្ហាប៉ះពាល់ពីឥទ្ធិពលនៃគ្រឿងញៀនតាមវិធីសាស្ត្រផ្សេងៗ ព្រមទាំងធ្វើការដោះស្រាយដោយផ្ទាល់ខ្លួនឯងផង និងដោយសុំគោលការណ៍សម្រេចពីថ្នាក់លើក៏មាន។ ការដោះស្រាយបញ្ហាចំពោះមុខពិតជាសំខាន់ប៉ុន្តែជាការចាំបាច់ជាងនេះទៅទៀតនោះគឺអាជ្ញាធរឃុំ គួរតែពិនិត្យមើលលទ្ធភាពក្នុងការរៀបចំផែនការការងារសម្រាប់អនុវត្តក្នុងពេលខាងមុខ ដើម្បីធ្វើជាត្រីវិស័យចង្អុលបង្ហាញទិសដៅឆ្ពោះទៅរកភាពរីកចម្រើនប្រកបដោយការអភិវឌ្ឍ និងគ្រប់គ្រងភូមិឃុំឱ្យស្របទៅតាមការដឹកនាំបែបវិមជ្ឈការដែលជាគោលការណ៍របស់រាជរដ្ឋាភិបាលថ្នាក់ជាតិប្រកបដោយនិរន្តរភាពពិតប្រាកដ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមការសិក្សាស្វែងយល់ក្នុងការស្រាវជ្រាវទៅលើប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាបតាមបែបវិមជ្ឈការ"រួចមក យើងខ្ញុំអាចធ្វើសេចក្តីសន្និដ្ឋានទៅលើប្រធានបទ ក្នុងសកម្មភាពគ្រប់គ្រងរដ្ឋបាលរបស់ឃុំតាំងយ៉ាបពិតជាមានភាពល្អប្រសើរដោយបានអនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញដើម្បីសហការបម្រើដល់ប្រជាពលរដ្ឋឱ្យបានកក់ក្តៅជាទីទុកចិត្តសម្រាប់ពលរដ្ឋនៅតាមជនបទ ជាពិសេសការអនុវត្តគោលនយោបាយ វិមជ្ឈការក្នុងការគ្រប់គ្រងឃុំ សង្កាត់នៅតាមមូលដ្ឋានដែលជារដ្ឋបាលថ្នាក់ក្រោមជាតិមួយដ៏សំខាន់ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងសកម្មភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួនដែលនេះជាដំណើរការជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅក្នុងមូលដ្ឋានភូមិ ឃុំ។

ផ្អែកទៅតាមការសិក្សាស្រាវជ្រាវទៅលើទ្រឹស្តី និងការចុះទៅដល់ទីតាំងផ្ទាល់ក្នុងមូលដ្ឋានឃុំ យើងខ្ញុំសង្កេតឃើញថានៅក្នុងមូលដ្ឋាននេះមានការរីកចម្រើន និងមានវឌ្ឍនភាព គឺការអភិវឌ្ឍជឿនលឿនពីមួយអាណត្តិទៅមួយអាណត្តិដែលជាសញ្ញាសបញ្ជាក់ឱ្យឃើញថា ការគ្រប់គ្រងរដ្ឋបាលឃុំតាមបែបវិមជ្ឈការពិតជាទទួលបានអត្ថប្រយោជន៍សម្រាប់ប្រជាជនគួជាទីពេញចិត្ត ការចូលរួមនេះជួយឱ្យឃុំ សង្កាត់ស្វែងយល់ពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយជាងនេះទៅទៀតការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់នេះក៏ជាមូលដ្ឋានគ្រឹះដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរីកចម្រើន និងមានស្ថិរភាពផងដែរ។

ជាក់ស្តែងនៅឃុំតាំងយ៉ាបយើងតាំងពីអាណត្តិទី១ មកដល់អាណត្តិទី៥នេះបានអភិវឌ្ឍខ្លួនយ៉ាងឆាប់រហ័សពីឃុំដែលមានការអភិវឌ្ឍតិចតួចប្រែក្លាយទៅជាឃុំមួយដែលមានការអភិវឌ្ឍលើគ្រប់វិស័យមានដូចជាផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ បណ្តាញអគ្គិសនី មន្ទីរពេទ្យ ទីផ្សារ សាលារៀន ដែលសុទ្ធសឹងតែជាសរសៃឈាមនៃការអភិវឌ្ឍមូលដ្ឋាន។ មិនតែប៉ុណ្ណោះ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ ក្នុងអាណត្តិនេះយើងសង្កេតឃើញថាក្រុមប្រឹក្សាឃុំបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ក្នុងការបម្រើប្រជាពលរដ្ឋ តាមរយៈការផ្តល់សេវាកម្មសាធារណៈផ្សេងៗព្រមទាំងធ្វើការដោះស្រាយរាល់បញ្ហាប្រឈមនឹងការលំបាកជូនដល់ប្រជាពលរដ្ឋបានទាន់ពេលវេលា និងមានប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពលរដ្ឋដែលនេះបង្ហាញយ៉ាងច្បាស់ថា ការទទួលខុសត្រូវរបស់អាជ្ញាធរឃុំក្នុងកិច្ចដំណើរការគ្រប់គ្រងឃុំប្រព្រឹត្តទៅបានយ៉ាងរលូន។

សរុបសេចក្តីមក ដូចយើងបានដឹងរួចមកហើយថា ឃុំដែលស្ថិតនៅក្រោមការដឹងនាំតាមបែបវិមជ្ឈការជារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនៅកៀកកិតជិតជាប់ជាមួយប្រជាពលរដ្ឋដោយផ្ទាល់ និងបានអនុវត្តការគ្រប់គ្រងឃុំ សង្កាត់ជាគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍនៅតាមមូលដ្ឋានឃុំ សង្កាត់ រស់នៅរបស់ប្រជាពលរដ្ឋ។ ការលើកកម្ពស់ប្រជាធិបតេយ្យ វិមជ្ឈការត្រូវបានចាត់ទុកថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុង

ការជុំរុញអភិបាលកិច្ចល្អ ជាពិសេសការចូលរួមចំណែកដ៏សំខាន់ក្នុងការបង្កើនល្បឿននៃការអភិវឌ្ឍសង្គមជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនយើង។

ជាសក្ខីភាពការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលដឹកនាំដោយក្រុមប្រឹក្សាឃុំក្នុងអាណត្តិទី៥នេះ ពិតជាមានលក្ខណៈល្អប្រសើរដែលសម្រេចនូវសមិទ្ធផលជាច្រើនសម្រាប់ការអភិវឌ្ឍនៅក្នុងឃុំទាំងមូល និងបានដោះស្រាយការលំបាកគ្រប់យ៉ាងដែលជាបញ្ហាចោទសម្រាប់មូលដ្ឋានធ្វើឱ្យមានការពេញចិត្តពីសំណាក់ប្រជាជននៅក្នុងឃុំ និងពលរដ្ឋរស់នៅក្នុងភាពកក់ក្ដៅដែលមន្ត្រីថ្នាក់ក្រោមជាតិបានអនុវត្តន៍តាមអនុសាសន៍ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងការធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវទៅលើប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាបតាមបែបវិមជ្ឈការ" រួចមកយើងខ្ញុំយល់ឃើញថាមិនទាន់មានលក្ខណៈល្អប្រសើរគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារនៅមានភាពចន្លោះប្រហោង ខុសឆ្គងចំណុចណាមួយមិនខានដែលរដ្ឋាភិបាលគួរយកចិត្តទុកដាក់បន្ថែមទៀត និងបំពេញនូវចំណុចខ្វះខាតទាំងនោះឱ្យបានគ្រប់ជ្រុងជ្រោយ ហើយយើងខ្ញុំ សូមធ្វើការចូលរួមចំណែកជាគំនិតយោបល់ខ្លះៗក្នុងការផ្តល់ជាអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលឃុំតាំងយ៉ាប ដូចខាងក្រោម៖

- រាជរដ្ឋាភិបាលគួរតែបង្កើនខ្ទង់ថវិកាអភិវឌ្ឍឃុំ សង្កាត់ឱ្យបានសមស្របទៅតាមតម្រូវការ ជាពិសេសគឺមូលដ្ឋានឃុំ សង្កាត់ណាដែលក្រីក្រ និងដាច់ស្រយាលដើម្បីជំរុញការអភិវឌ្ឍឱ្យបានឆាប់រហ័ស
- រាជរដ្ឋាភិបាលគួរតែបន្តធ្វើវិមជ្ឈការថវិកាបន្ថែម ជូនទៅថ្នាក់រដ្ឋបាលក្រោមជាតិ ដើម្បីគាំទ្រដល់ការកែលម្អការផ្តល់សេវាសាធារណៈ
- រាជរដ្ឋាភិបាលគួរតែបើកវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិកឃុំឱ្យបានច្រើនដើម្បីបង្កើនសមត្ថភាពការងារជាពិសេសផ្នែកបច្ចេកទេសទៅកាន់ពួកគាត់
- រាជរដ្ឋាភិបាល គួរតែបង្កើនសមាសភាពមន្ត្រីរាជការឱ្យបានសមស្របទៅតាមទំហំឃុំ និងចំនួនប្រជាជនដើម្បីងាយស្រួលធ្វើការបានលឿនទាន់ពេលវេលា និងទាន់តម្រូវការរបស់ប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ គួរយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យផ្ទៃក្នុងទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ឃុំ ដើម្បីធានាបាននូវគណនេយ្យភាព និងតម្លាភាព
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែត្រួតពិនិត្យ និងវាយតម្លៃទៅលើការបំពេញការងាររបស់បុគ្គលិកឃុំ អំពីការសាកសួរព័ត៌មានផ្សេងៗ
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរចុះជួបប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យបានញឹកញាប់ដើម្បីដឹងសុខទុក្ខ និងតម្រូវការរបស់ប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ សង្កាត់គប្បីធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរាល់ការអនុវត្តផែនការ កម្មវិធីគម្រោង និងការផ្តល់សេវានានាប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់
- បន្ថែមលើនេះទៀតប្រជាពលរដ្ឋនៅតាមមូលដ្ឋានគួរមានការយល់ដឹងខ្លះៗអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងការងាររបស់មន្ត្រីថ្នាក់ឃុំ សង្កាត់របស់ខ្លួនផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ➢ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- អនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ស្ដីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ១៣២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្ដីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់
- ប្រកាសលេខ៣៨៦០ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំនៃឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ
- គោលនយោបាយស្ដីពីភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ ។

## ➢ សៀវភៅតែងនិពន្ធ

- សម្ដេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពលើកទី៥ឆ្នាំ១៩៦៧ *វចនានុក្រមខ្មែរ ភាគ១ និង២*
- សៀវភៅ *សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់* ខែមីនា ឆ្នាំ២០១៧
- សៀវភៅ *សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់* ខែមីនា ឆ្នាំ២០១៧
- ក្រសួងមហាផ្ទៃ ខែកក្កដា ឆ្នាំ២០១៧ *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ*
- ក្រសួងមហាផ្ទៃ បោះពុម្ពឆ្នាំ២០២២ *សៀវភៅណែនាំស្ដីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់*
- លោក ធន សុងឃុយ *មេរៀនស្ដីពីនីតិរដ្ឋបាលទូទៅ* បណ្ណាល័យច្បាប់។

- **ឯកសារផ្សេងៗ**
  - សេចក្ដីសម្រេចលេខ០០៤/២២ សសរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការទទួលស្គាល់មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារឃុំតាំងយ៉ាប សម្រាប់អាណត្តិទី៥
  - សេចក្ដីសម្រេចលេខ០៣/២០២៣ ស.ជ.ណ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈកម្មការលទ្ធកម្ម ឃុំតាំងយ៉ាប
  - សេចក្ដីសម្រេចលេខ០២/២៣ ស.ស.រ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំតាំងយ៉ាប
  - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ
  - កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២២-២០២៤) ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ
  - អនុស្សរណៈស្ដីពីគម្រោងថវិកាឃុំតាំងយ៉ាបឆ្នាំ២០២៤ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣
  - អនុស្សរណៈស្ដីពីគម្រោងថវិកាឃុំតាំងយ៉ាបឆ្នាំ២០២៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២
  - តារាងស្ថិតិផ្ទៃដីក្នុងឃុំតាំងយ៉ាប ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៤
  - តារាងសង្ខេបទិន្នន័យចម្បងរបស់ឃុំតាំងយ៉ាប គិតត្រឹមថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣
  - របាយការណ៍ស្ដីពីការអភិវឌ្ឍមូលដ្ឋានឃុំតាំងយ៉ាបចាប់ពីឆ្នាំ២០០៣-២០២៣។

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ឧបសម្ព័ន្ធទី៣៖** ប្រកាសលេខ៣៨៦០ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំនៃឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

**ឧបសម្ព័ន្ធទី៤៖** សេចក្តីសម្រេចលេខ ០២/២៣ សសរ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំតាំងយ៉ាប

**ឧបសម្ព័ន្ធទី៥៖** សេចក្តីសម្រេចលេខ ០០៩/២២ សសរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារឃុំតាំងយ៉ាបសម្រាប់អាណត្តិទី៥

**ឧបសម្ព័ន្ធទី៦៖** សេចក្តីសម្រេចលេខ ០៣/២០២៣ ស.ជ.ណ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការលទ្ធកម្ម ឃុំតាំងយ៉ាប

**ឧបសម្ព័ន្ធទី៧៖** សេចក្តីសម្រេចលេខ ០៤/២៣ ស.ស.រ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ(២០២៣-២០២៧)

**ឧបសម្ព័ន្ធទី៨៖** សេចក្តីសម្រេចលេខ ០១៣/២២ សសរ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២២-២០២៤)

**ឧបសម្ព័ន្ធទី៩៖** ផែនទីឃុំតាំងយ៉ាប។

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធទី២

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិក ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យ ប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ ..**

ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ ត្រូវបានកែប្រែនិងដំឡើងដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់ឧបត្ថម្ភ(រៀល) |
|---|---|---|
| ១ | ប្រធានក្រុមប្រឹក្សារាជធានី<br>ប្រធានក្រុមប្រឹក្សាខេត្ត | ១ ៦៥០ ០០០ |
| ២ | សមាជិកក្រុមប្រឹក្សារាជធានី<br>សមាជិកក្រុមប្រឹក្សាខេត្ត | ១ ២៤៥ ០០០ |
| ៣ | ប្រធានក្រុមប្រឹក្សាក្រុង<br>ប្រធានក្រុមប្រឹក្សាស្រុក<br>ប្រធានក្រុមប្រឹក្សាខណ្ឌ | ១ ៣៦៥ ០០០ |
| ៤ | សមាជិកក្រុមប្រឹក្សាក្រុង<br>សមាជិកក្រុមប្រឹក្សាស្រុក<br>សមាជិកក្រុមប្រឹក្សាខណ្ឌ | ១ ០២០ ០០០ |

| | | |
|---|---|---|
| ៥ | មេឃុំ ចៅសង្កាត់ | ១ ៣២០ ០០០ |
| ៦ | ជំទប់ទី១<br>ចៅសង្កាត់រងទី១<br>ជំទប់ទី២<br>ចៅសង្កាត់រងទី២ | ៩៨០ ០០០ |
| ៧ | សមាជិកក្រុមប្រឹក្សាឃុំ<br>សមាជិកក្រុមប្រឹក្សាសង្កាត់ | ៨៧០ ០០០ |
| ៨ | មេភូមិ | ៥៥០ ០០០ |
| ៩ | អនុប្រធានភូមិ | ៤៣០ ០០០ |
| ១០ | សមាជិកភូមិ | ៤០០ ០០០ |

**មាត្រា២** .-

ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ត្រូវបានកែប្រែនិងដំឡើងដូចខាងក្រោម៖

| ល.រ | **បរិយាយ** | ប្រាក់ឧបត្ថម្ភ(រៀល) |
|---|---|---|
| ១ | ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី<br>ប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត | ១ ៦៥០ ០០០ |
| ២ | អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី<br>អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត | ១ ២៤៥ ០០០ |
| ៣ | ប្រធានការិយាល័យប្រជាពលរដ្ឋក្រុង<br>ប្រធានការិយាល័យប្រជាពលរដ្ឋស្រុក<br>ប្រធានការិយាល័យប្រជាពលរដ្ឋខណ្ឌ | ១ ៣៦៥ ០០០ |

**មាត្រា៣** .-

ប្រាក់ឧបត្ថម្ភដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ តទៅ។

**មាត្រា៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែមេសា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហ៊ុន ម៉ានី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៣០៤ ២០២២ ប្រក

# ប្រកាស

## ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឃុំតាំងយ៉ាប លេខកូដ ២១-០៥៧ នៃខេត្តតាកែវ (ទម្រង់បែបបទ១១១៨) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២

## សម្រេច

**ប្រការ១.-**

ទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ស៊ី វុទ្ធី | ជាប្រធានក្រុមប្រឹក្សាឃុំ |
| ២- | លោក | ងន សេងអាយ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៣- | លោក | មៀច ស្រ៊ាន | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៤- | លោក | សុខ ញ៉ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៥- | លោក | សុខ គីឡុង | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៦- | លោកស្រី | ម៉ែន សុជា | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៧- | លោក | ឈិត ណាត | ជាសមាជិកក្រុមប្រឹក្សាឃុំ។ |

**ប្រការ២.-**

ទទួលស្គាល់សមាសភាពជាមេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ស៊ី វុទ្ធី | ជាមេឃុំ |
| ២- | លោក | ងន សេងអាយ | ជាជំទប់ទី១ |
| ៣- | លោក | មៀច ស្រ៊ាន | ជាជំទប់ទី២។ |

**ប្រការ៣.-**

ការអនុវត្តការងារប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំតាំងយ៉ាប ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៣រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អង្គភាពប្រឆាំងអំពើពុករលួយ
  - "ដើម្បីជូនជ្រាប"
- រដ្ឋបាលខេត្ត ស្រុក ឃុំ សាមី
- ដូចប្រការ១
  - "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត តាកែវ**
**ស្រុក ព្រៃកប្បាស**
**ឃុំ តាំងយ៉ាប**
លេខ ០២ /២៣សសរ

## សេចក្តីសំរេច

## ស្តីពីការបង្កើតគណកម្មាធិការកសាងផែនការ និងថវិកា

## ឃុំ តាំងយ៉ាប

. យោងតាមព្រះរាជក្រមលេខ នស/ រកម/ ០៣០១ ចុះថ្ងៃទី១៩ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

. យោងអនុក្រិត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

. យោងអនុក្រិត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី០២ខែមេសា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ឃុំ សង្កាត់ ។

. យោងប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការលេខ ២៤២៣ប្រ.កចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

. យោងប្រកាសលេខ៨៨៨៣ ប្រ.កចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ ជំទប់ទី២ ឃុំតាំងយ៉ាប ។

. យោងស្មារតីប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាឃុំតាំងយ៉ាប កាលពីថ្ងៃទី០៧ / កក្កដា / ឆ្នាំ២០២៣

**សំរេច**

ប្រការ ១. បង្កើតគណកម្មាធិការកសាងផែនការ និងថវិកាឃុំ ព្រៃផ្តៅ រួមមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១ . លោក ស៊ី វ៉ុទ្ធី | មេឃុំ | ប្រធាន |
| ២ . លោក ងន សេងអាយ | ជំទប់ទី១ | សមាជិកអចិន្ត្រៃយ៍ |
| ៣. លោក មៀច ស្រ៊ាន | ជំទប់ទី២ | សមាជិក |
| ៤. លោក សុខ គីឡុង | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក |
| ៥. លោក ឈិត ណាត | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក |
| ៦. កញ្ញា ម៉ែន សុធា | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក |
| ៧. លោក ហាក់ ស្រៀង | ចាស់ព្រឹទ្ធាចារ្យ | សមាជិក |
| ៨. លោក ខូច ស្រ៊ីម | ចាស់ព្រឹទ្ធាចារ្យ | សមាជិក |
| ៩. លោក ខូច សំអ៊ីន | ស្មៀនឃុំ | លេខាកត់ត្រា |
| ១០ _លោក ម៉ឹង ផ្លុន | មេភូមិត្រពាំងទា | សមាជិក |
| ១២_ លោក ឡៀប នៃ | មេភូមិព្រៃចំបក់ | សមាជិក |

| | | |
|---|---|---|
| ១៣_លោក គង់ សាព្រ | ភូមិក្រពាំងស្អក | សមាជិក |
| ១៤_លោក បេន រៃន | ភូមិស្នួលខ្ពស់ | សមាជិក |
| ១៥_ លោក សុខ វ៉ុង | ភូមិក្រាំងអំពិល | សមាជិក |
| ១៥_ លោកស្រី សែម អាន | ភូមិក្រាំងចំរើន | សមាជិក |
| ១៦_ កញ្ញា ផាន ពុទ្ធា | ភូមិដំរៅ | សមាជិក |
| ១៨_ លោក ម៉ុក សុខ | ភូមិកែវចំរើន | សមាជិក |
| ១៩_ លោក មាស សួស | ភូមិសំបូរ | សមាជិក |
| ២០_ លោក មុំ វេត | ភូមិអង្គ រោយ | សមាជិក |
| ២១_ លោក ហ៊ីង ង៉ែត | ភូមិប្រនៀងខ្ពស់ | សមាជិក |
| ២២_ លោក ថៅ ហុងលី | ភូមិរលួស | សមាជិក |

ប្រការ២គណកម្មាធិការកសាងផែនការនិងថវិកាឃុំដូចមានចែងក្នុងប្រការ១ខាងលើមានតួនាទីនិងភារកិច្ចជួយលោកមេឃុំ៖

. ក្នុងដំណើរកសាងផែនការអភិវឌ្ឍន៏ឃុំ និងកម្មវិនិយោគឃុំអោយស្របតាមខ្លឹមសារស្មារតីប្រកាសរបស់អន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការ លេខ២៤២៣ប្រ.កចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៏ ឃុំ សង្កាត់ និងកម្មវិនិយោគឃុំ សង្កាត់ ។

. ពិនិត្យ ពិភាក្សារៀបចំកសាងផែនការថវិកាឃុំ អោយស្របតាមខ្លឹមសារស្មារតីអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ឃុំ សង្កាត់ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលបានកំណត់ ។

ប្រការ ៣សេចក្តីសំរេចស្តីពីការបង្កើតគណកម្មាធិការកសាងផែនការនិងថវិកាឃុំតាំងយ៉ាបដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ អស់លោក លោកស្រីដែលមានឈ្មោះចែងក្នុងប្រការ ១ ខាងលើ ត្រូវសហការអនុវត្តាមសេចក្តីសំរេចនេះ អោយទទួលបានលទ្ធផល ល្អដែលមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

តាំងយ៉ាប ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣

មេឃុំតាំងយ៉ាប

តាំងយ៉ាប

ចម្លងជូន

. សាលាខេត្តតាកែវ

. សាលាស្រុកព្រៃកប្បាស

( ដើម្បីជូនជ្រាប )

. សាម៉ីខ្លួនដូចមានចែងក្នុងប្រការ១

( ដើម្បីអនុវត្ត )

. ឯកសារ.កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត តាកែវ**
**រដ្ឋបាលស្រុក ព្រៃកប្បាស**
**រដ្ឋបាលឃុំ តាំងយ៉ាប**
**លេខ:០០៩ \២២ ស ស រ**

## សេចក្តីសំរេច
## ស្តីពីការទទួលស្គាល់មន្ត្រី ទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សំរាប់អាណត្តិទី៥

## មេឃុំតាំងយ៉ាប

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។
- យោងអនុក្រឹត្យលេខ២២ អនក្រ ចុះថ្ងៃទី២៥ មិនា ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាចតួនាទី និងភារៈកិច្ចទៅអោយក្រុមប្រឹក្សាឃុំ។
- យោងប្រកាសលេខ៣៨៦០ ប្រក ចុះថ្ងៃទី២៧ មិថុនា ២០២២ ស្តីពីការទទួលស្គាល់សមាសភាពក្រុម ប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ ជំទប់ទី២ នៃរដ្ឋបាលឃុំតាំងយ៉ាប។
- យោងតាមការពិភាក្សាសំរេច ក្នុងលទ្ធផលសម័យប្រជុំពេញអង្គក្រុមប្រឹក្សាឃុំ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់គណ:កម្មាធិការទទួលបន្ទុកកិចការនារី និងកុមារឃុំ។

## សម្រេច

**ប្រការ១៖** បង្កើតគណ:កម្មាធិការទទួលបន្ទុក កិច្ចការនារីនិងកុមារឃុំតាំងយ៉ាប រួមមានសមាសភាពដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១.លោក | ស៊ី | វុទ្ធី | មេឃុំតាំងយ៉ាប | ប្រធាន |
| ២.លោក | មៀច | ស្រ៊ាន | ជំទប់ទី២ | អនុប្រធាន |
| ៣.កញ្ញា | ម៉ែន | សុធា | ទទួលបន្ទុកកិច្ចការនារីឃុំ | សមាជិកអចិន្រ្តៃយ៍ |
| ៤.លោក | ទូច | សំអ៊ីន | ស្មៀនឃុំតាំងយ៉ាប | សមាជិក |
| ៥.លោក | ស៊ិន | សាភ៉ក់ | នាយប៉ុស្តិ៍រដ្ឋបាល | សមាជិក |
| ៦.លោក | ណៃ | ធី | នាយកបឋមសិក្សាភ្នំចចក | សមាជិក |
| ៧.លោក | សន | សំបូរ | ប្រធានមណ្ឌលសុខភាព | សមាជិក |
| ៨.លោក | ម៉ឹង | ជ្រុន | ប្រធានភូមិត្រពាំងទា | សមាជិក |
| ៩.លោក | ឌៀប | វិន | ប្រធានភូមិព្រៃចំបក់ | សមាជិក |
| ១០.លោក | គង់ | សាវុធ | ប្រធានភូមិត្រពាំងស្អក | សមាជិក |

| | | | |
|---|---|---|---|
| ១១.លោក បេន វិន | | ប្រធានភូមិស្នួលខ្ពស់ | សមាជិក |
| ១២.លោក សុខ រ៉ុង | | ប្រធានភូមិក្រាំងអំពិល | សមាជិក |
| ១៣.លោកស្រី សែម អាន | | ប្រធានភូមិក្រាំងចំរើន | សមាជិក |
| ១៤.លោក កាន់ ហឿ | | ប្រធានភូមិជំរៅ | សមាជិក |
| ១៥.លោក ម៉ុក សុខ | | ប្រធានភូមិកែវចំរើន | សមាជិក |
| ១៦.លោក ទេព សំអាន | | ប្រធានភូមិសំបូរ | សមាជិក |
| ១៧.លោក មុំ រ៉េត | | ប្រធានភូមិអង្គ រវាយ | សមាជិក |
| ១៨.លោក ហ៊ុង ង៉ែត | | ប្រធានភូមិច្រនៀងខ្ពស់ | សមាជិក |
| ១៩.លោក ថៅ ហុងលី | | ប្រធានភូមិរលួស | សមាជិក |

**ប្រការ២៖** គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ មានតួនាទី និងភារៈកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវ ក្នុងកិច្ចការនារី និងកុមារ ត្រូវបានផ្តល់សិទ្ធិអោយចូលរួមកាល់កិច្ចការពិភាក្សា រី ប្រជុំ គណៈកម្មការនានា និងប្រជុំរបស់ក្រុមប្រឹក្សា
- ជំនួយការអោយក្រុមប្រឹក្សា លើកិច្ចការនារី និងកុមារឃុំ
- ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធស្តីពី លទ្ធផលការងារប្រចាំខែដែលអនុវត្តបាន។

**ប្រការ៣៖** សិទ្ធិអំណាចការគ្រប់គ្រងការងារកិច្ចការនារី និងកុមារ រាល់ការអនុវត្តន៍ភារៈកិច្ចត្រូវមានការឯកភាពពីក្រុមប្រឹក្សា និងមេឃុំជាមុន។

**ប្រការ៤៖** លោកស្រីដែលមានឈ្មោះក្នុងប្រការ១ មានភារៈកិច្ចនិងអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិ ភាពចាប់ពីចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

តាំងយ៉ាប ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

**មេឃុំ**

ស៊ុំ-ម៉ុនី

**កន្លែងទទួល**

- គណៈកម្មាធិការប្រតិបត្តិ នៃគ អ ជ ខ
  "ជូនជ្រាប"
- មន្ទីរកិច្ចការនារិ និងយុទ្ធជនខេត្ត
  "ដើម្បីជូនជ្រាប"
- ការិយាល័យកិច្ចការនារីស្រុក
- មេភូមិគ្រប់ភូមិក្នុងឃុំ
- ដូចប្រការ១
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត:តាកែវ
ស្រុក:ព្រៃកប្បាស
ឃុំ:តាំងយ៉ាប
លេខ:០៣/២០២៣ ស.ជ.ណ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណ:កម្មធិការលទ្ធកម្ម ឃុំតាំងយ៉ាប

-យោងព្រះរាជក្រមលេខ នស.រកម០៣០១.០៥ ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

-យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

-យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ។
យោងប្រកាសអន្តរក្រសួងលេខ ០៩៨ ប្រ.ក ចុះថ្ងៃទី០៧ ខែកុម្ភ: ឆ្នាំ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ ។

-យោងប្រកាសលេខ: ៣៤៦០ ប្រ.ក ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់សមាសភាព សមាជិកក្រុម ប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ ជំទប់ទី២ ឃុំតាំងយ៉ាប

-យោងស្មារតីប្រជុំក្រុមប្រឹក្សាឃុំ តាំងយ៉ាប ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ ។

## សម្រេច

ប្រការ១ បង្កើតគណ:កម្មាធិការលទ្ធកម្ម ឃុំ តាំងយ៉ាប ដែលមានសមាសភាព ដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១. លោក | ស៊ឺ | ទ្រី | តួនាទី | ប្រធាន |
| ២.លោក | ងន សេងអាយ | | តួនាទី | សមាជិកអចិន្ត្រៃ |
| ៣. លោក | សុខ | គីឡុង | តួនាទី | សមាជិក |
| ៤.លោក | ឈិត | ណាត | តួនាទី | ជាសមាជិក |
| ៥.លោក | ទូច | សំអ៊ីន | តួនាទី | លេខាធិការ |

ប្រការ ២ គណ:កម្មាធិការលទ្ធកម្ម ឃុំ មានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម:

-ជួយមេឃុំក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់ឃុំ ត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ

-ត្រូវអនុវត្តវិធីសាស្ត្រកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងគំរោងថវិកាប្រចាំឆ្នាំរបស់ឃុំ តាមអភិក្រមមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ

-ជួយមេឃុំក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់ឃុំ ។

ប្រការ៣ សមាសភាពដែលមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>ចម្លងជូន</u>

-សាលាខេត្តតាកែវ
-សាលាស្រុកព្រៃកប្បាស
"ដើម្បីជូនជ្រាប"
-ដូចមានចែង

ថ្ងៃពុធ១រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
តាំងយ៉ាប,ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣
**មេឃុំតាំងយ៉ាប**

# ឧបសម្ព័ន្ធទី៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត:តាកែវ**
**ស្រុក:ព្រៃកប្បាស**
**រដ្ឋបាលឃុំ:តាំងយ៉ាប**
លេខ:០៨/២៣ ស.ស.I

## សេចក្តីសម្រេច

ស្តីពីការដាក់អោយប្រើប្រាស់សៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ(២០២៣ . ២០២៧)

-យោងតាមព្រះរាជក្រឹត្យលេខ នស/រកម/០៣០១/៩០៣ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

-យោងអនុក្រឹត្យ ២២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច អោយទៅក្រុមប្រឹក្សាឃុំ សង្កាត់។

-យោងប្រកាសអន្តរៈក្រសួងមហាផ្ទៃនិងក្រសួងផែនការលេខ ២៤៣២ ប្រ.កចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

-យោងប្រកាសលេខ ៣៨៦០ ប្រ.ក ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និងជំទប់ទី២ឃុំតាំងយ៉ាប។

-យោងស្មារតីប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាឃុំតាំងយ៉ាបកាលពីថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០២២។

-យោងលិខិតអនុលោមភាពពីឯកឧត្តម អភិបាលខេត្តលេខ៖៣៣៥/២៣ស.ជ.ណ ចុះថ្ងៃពុធ៥កើតខែជេស្ឋ ឆ្នាំថោះបញ្ច ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

## សម្រេច

ប្រការ១.ដាក់អោយប្រើប្រាស់សៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០២៣.២០២៧) ក្នុងអណត្តិទី៥នៃក្រុមប្រឹក្សាឃុំតាំយ៉ាប ឆ្នាំ២០២២។

ប្រការ២.គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំក្រុមប្រឹក្សាឃុំនិងអ្នកពាក់ពន្ធ័ត្រូវអនុវត្តការងារអភិវឌ្ឍន៍ឃុំតាំងយ៉ាបទៅតាមផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់ឃុំអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ប្រការ៣.សេចក្តីសម្រេចណាដែលមានខ្លឹមសារផ្ទុយនិងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

ថ្ងៃចន្ទ១៥រោចខែបឋមសាឍ ឆ្នាំថោះចត្វាស័ក ព.ស២៥៦៧
តាំងយ៉ាប ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣

**មេឃុំតាំងយ៉ាប**

**ចម្លងជូន**
-សាលាខេត្តតាកែវ
-សាលាស្រុកព្រៃកប្បាសដើម្បីជូនជ្រាប
-ក្រុមប្រឹក្សាឃុំ គ.ផ.ថ ដើម្បីអនុវត្ត
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តតាកែវ

ស្រុកព្រៃកប្បាស

ឃុំតាំងយ៉ាប

លេខ ០១៣./២២សសរ

**សេចក្តីសម្រេច**

**ស្តីពីការដាក់អោយប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល**

**(២០២២- ២០២៤)**

-យោង: តាមព្រះរាជក្រមលេខ ០៣០១ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ២០០១ដែលប្រកាសអោយប្រើ ច្បាប់ស្តី ពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ។

-យោងអនុក្រិតលេខ ២២អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាលស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទីនិងភារៈកិច្ចទៅអោយ ក្រុមប្រឹក្សាឃុំ សង្កាត់ ។

-យោងប្រកាសអន្តៈក្រសួងមហាផ្ទៃនិងក្រសួងផែនការលេខ ២៤៣២ប្រក ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

-យោងប្រកាសលេខ ៣៨៦០ប្រក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ ជំទប់ទី២ ឃុំតាំងយ៉ាប

- យោងស្មារតីអង្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាឃុំព្រៃកប្បាសថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២

**សម្រេច**

**ប្រការ១៖** សម្រេចដាក់អោយប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២២-២០២៤) ក្នុង អាណត្តិទី៥ នៃក្រុមប្រឹក្សឃុំតាំងយ៉ាប

**ប្រការ២៖** គណកម្មាធិការកសាងផែនការ និងថវិកាឃុំ ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តការងារអភិវឌ្ឍន៍ ឃុំតាំងយ៉ាបទៅតាមសៀវភៅនេះរបស់ឃុំ អោយមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ៣៖** សេចក្តីសម្រេចណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជា និរាករណ៍។

ថ្ងៃចន្ទ១៤រោច ខែកត្តិក ឆ្នាំខាលស័ក ពស ២៥៦៦

តាំងយ៉ាបថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២

**ចម្លងជូន:**

-សាលាខេត្តតាកែវ

-សាលាស្រុកព្រៃកប្បាស (ដើម្បីជូនជ្រាប)

-ក្រុមប្រឹក្សាឃុំគជថ(ដើម្បីអនុវត្ត)

-ឯកសារកាលប្បវត្ត

មេឃុំតាំងយ៉ាប

ឃុំ តាំងយ៉ាប

ស៊ុំ . ឫទ្ធិ

# ឧបសម្ព័ន្ធទី៦


21021301
21021304
21021306
21021307
21021308
21021302
W
E
1:26,297
21061301
21060707
21061302
21060705
21061309
21061303
21060704
21060706
21061310
21060703
21061304
21061305
21061311
21061306
21060702
21061307
21061308
21061312
21060701
21061109
21061110
21061108
21061107
21060305